01034570

E1/244.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Nov-2014, 10:59
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការ
# នីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ(វគ្គពីរ)

**សាធារណៈ**

សំណុំរឿងលេខ ០០២-០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤**

**ម៉ោង ០៩: ០៣នាទី**

**កិច្ចប្រជុំរៀបចំសវនាការ**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក គេន រ៉ូប៊ឺតស៍ *(Mr. Ken ROBERTS)*

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

កញ្ញា សូហ្វី ម៉ូរ៉ាយស៍ *(Ms. Sophie MAURICE)*

លោក រូស្សែល ហប់គីនស៍
*(Mr. Russell HOPKINS)*

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena GHEZZI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក សាលីម ណាកចាវ៉ានី *(Mr.Salim Nakhjavani)*

លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី *(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ការិយាល័យរដ្ឋបាល៖**

លោក ក្រាញ់ តូនី

លោក ឃ្នុត រ៉ូសាន់ហោក *(Mr. Knut ROSANDHHAUG)*

លោក ឆាលស៍ ហ្សាម៉ា*(Mr. Charles ZAMA)*

លោក អ៊ីសាក់ អ៊ីនដឺលី *(Mr. Isaac ENDELEY)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ឃ្មុត រ៉ូសាន់ហោក | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក លោក អ៊ីសាក់ អ៊ីនដឺលី | អង់គ្លេស |
| លោក ខៀវ សំផន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ថ្ងៃនេះក្នុងឋានៈខ្ញុំជាប្រធាន និងក្នុងនាមជាចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមស្វាគមន៍ចំពោះសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្ដីទាំងអស់។ ខ្ញុំសូមស្វាគមន៍ចំពោះឯកឧត្ដមប្រធានស្ដីទីការិយាល័យរដ្ឋបាលនិងលោកអនុប្រធាន និង បុគ្គលិកដទៃទៀតដែលមកពីការិយាល័យរដ្ឋបាល។ អនុលោមតាមវិធាន៧៩(៧)នៃវិធានផ្ទៃក្នុង ក្នុងពេលនេះកិច្ចប្រជុំរៀបចំសវនាការត្រូវបានធ្វើជាអសាធារណៈ។ ផ្នែកមួយចំនួននៃកិច្ចប្រជុំរៀបចំសវនាការនេះ អាចនឹងត្រូវបានប្រកាសជាសាធារណៈនៅពេលក្រោយ។

លោកចៅក្រម យូរ ឧត្ដរា បានជូនដំណឹងថា នៅថ្ងៃនេះគាត់មានធុរៈមិនអាចចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនេះបាន។ អនុលោមតាមវិធាន៧៩(៤) នៃវិធានផ្ទៃក្នុង បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងចៅក្រមដទៃទៀត ខ្ញុំបានសម្រេចចាត់តាំងលោកចៅក្រម ធូ មណី ជាចៅក្រមបម្រុងខាងភាគីជាតិ ដើម្បីជំនួសកន្លែងចៅក្រម យូរ ឧត្ដរា សម្រាប់កិច្ចប្រជុំថ្ងៃនេះ។

តទៅនេះ សូមអញ្ជើញលោកស្រី សែ កុលវឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះបានកោះអញ្ជើញ និងបង្គាប់ឲ្យចូលខ្លួននៅក្នុងកិច្ចប្រជុំរៀបចំសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់កិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់ និងបុគ្គលដែលអង្គជំនុំជម្រះបានអញ្ជើញឲ្យចូលរួមមានវត្តមាន។ កត់សម្គាល់ដោយឡែក ជនជាប់ចោទខៀវ សំផន បានមានវត្តមាននៅក្នុងកិច្ចប្រជុំនេះដែរ។ ដោយឡែកលោក នួន ជា បានជូនដំណឹងមកថាគាត់មិនមានបំណងនៅក្នុងការចូលរួមនៅក្នុងកិច្ចប្រជុំនេះទេ។ សូមអរគុណប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវឌ្ឍី។

កាលពីសប្តាហ៍មុន នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការមួយ ដើម្បីពិភាក្សាអំពីបញ្ហាធនធានដែលត្រូវបានផ្តល់ជូនដោយការិយាល័យរដ្ឋបាលពាក់ព័ន្ធទៅនឹងការលើកឡើងក្នុងពេលថ្មីៗនេះរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ហើយនិងពិភាក្សាអំពីផលវិបាកផ្លូវច្បាប់ និងការអនុវត្តជាក់ស្តែងនៃការបង្ហាញឯកសារថ្មីដែលស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ។

អង្គជំនុំជម្រះសាលាដំបូង បានអញ្ជើញឯកឧត្តមប្រធានស្តីទី និង លោកអនុប្រធានការិយាល័យរដ្ឋបាល និងអ្នកតំណាងដទៃទៀតមកពីការិយាល័យរដ្ឋបាលឲ្យផ្តល់ជូននូវព័ត៌មានពាក់ព័ន្ធទៅនឹងធនធានដែលមានសម្រាប់ភាគី។ ទោះបីជាទទួលបានការបង្គាប់ចូលរួមនៅក្នុងកិច្ចប្រជុំខាងលើនេះក្តី ក៏ក្រុមមេធាវីការពារក្តីទាំងពីរក្រុម បានខកខានក្នុងការបង្ហាញខ្លួនដោយគ្មានផ្តល់មូលហេតុសមស្របអ្វីឡើយ។ ហេតុដូច្នេះហើយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញការព្រមានចំពោះក្រុមមេធាវីការពារក្តីទាំងពីរក្រុម ដោយអនុលោមតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង។ នៅក្នុងអនុស្សរណៈដដែលនោះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីទាំងអស់ចូលរួមក្នុងកិច្ចប្រជុំរៀបចំកិច្ចសវនាការនៅថ្ងៃនេះ ដើម្បីឲ្យអង្គជំនុំជម្រះអាចយល់ដឹងបានទាំងស្រុង អំពីបញ្ហាខ្វះខាតធនធានដែលមេធាវីការពារក្តី ខៀវ សំផន បានលើកឡើង។ អាស្រ័យហេតុ -- ដោយមូលហេតុនេះហើយ ទើបអង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញប្រធាន ឯកឧត្តមប្រធានស្តីទីនិងលោកអនុប្រធានការិយាល័យរដ្ឋបាល និងអ្នកតំណាងដទៃទៀតមកពីផ្នែករដ្ឋបាលឲ្យចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនេះជាថ្មីម្តងទៀត។

[០៩:០៨:០២]

អង្គជំនុំជ្រះសូមរំឭកក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ថា នេះជាឱកាសចុងក្រោយដើម្បីពិភាក្សាអំពីបញ្ហាធនធានជាមួយនឹងអង្គជំនុំជម្រះ។ អនុស្សរណៈនេះ អនុស្សរណៈក៏បានជូនដំណឹងដល់ភាគីដទៃទៀតដែរថា អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱកាសឲ្យភាគីដើម្បីពិភាក្សាលើសំណើសុំរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងមេធាវីបម្រុង និងសុំពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ ហើយអង្គជំនុំជម្រះបានចែកច្បាប់ចម្លងនៃសំណើនេះជូនភាគីរួចហើយ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤។

ជាទីបញ្ចប់ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់តាមអ៊ីម៉ែលកាលពីថ្ងៃម្សិលមិញថា ក្នុងកិច្ចប្រជុំរៀបចំសវនាការនេះ ពួកគាត់មានឱកាសឆ្លើយតបទៅនឹងសំណើ នីតិវិធីប្រើប្រាស់ឯកសារសម្ងាត់មួយចំនួនដែលស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដែលត្រូវបានដាក់ក្នុង

សំណុំរឿងកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤។ ឥឡូវនេះ ដើម្បីបានយល់ច្បាស់ ខ្ញុំសូមជូនវេទិកាទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរមួយចំនួនចាំបាច់ចំពោះមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហាធនធាន។ សូមអញ្ជើញលោកចៅក្រម ឡាវែន៍!

[០៩:០៩:៣៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរ ជាពិសេសទៅកាន់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ សំណួរទី១របស់ខ្ញុំ ពាក់ព័ន្ធទៅនឹងការសុំឲ្យបំភ្លឺអំពីការណែនាំរបស់ជនជាប់ចោទ ខៀវ សំផន ទៅកាន់មេធាវីរបស់ខ្លួន។ ខ្ញុំសូមរំឭកអំពីសេចក្តីថ្លែងការណ៍មួយចំនួនរបស់លោក ខៀវ សំផន នៅក្នុងសវនាការ នៅថ្ងៃទី១៧ ខែតុលា កន្លងទៅនេះ។ ជាពិសេសគឺខ្ញុំសុំដកស្រង់នៅទំព័រ៨៨-៨៩ នៃប្រតិចារឹកព្រាង។ នៅក្នុងសវនាការនោះ ជនជាប់ចោទ ខៀវ សំផន បានប្រកាសថាគាត់ចង់អនុវត្តសិទ្ធិប្តឹងសាទុក្ខរបស់គាត់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានប្រកាសនៅថ្ងៃទី០៧ តុលា ហើយនឹងអាចប្រើប្រាស់ទឡ្ហីករណ៍ទាំងមូលរបស់ខ្លួននៅចំពោះមុខតុលាការកំពូល។ ហើយនៅក្នុងសវនាការនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ នោះគាត់បានប្រកាសដូចតទៅ៖ “មេធាវីរបស់ខ្ញុំបានប្រាប់ខ្ញុំថា ពួកគាត់មិនអាចចូលរួមនៅក្នុងសវនាការ គឺសវនាការលើអង្គសេចក្តីពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ ហើយនិងត្រៀមរៀបចំបណ្តឹងសាទុក្ខឲ្យបានសមស្របនោះទេ គឺមានន័យថា បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលបានចេញនៅថ្ងៃទី០៧ ខែតុលា --(សុំទោស) ០៧ សីហា”។ គាត់បានបញ្ជាក់ថា៖ “ហេតុនេះហើយបានជាខ្ញុំត្រូវប្រាប់ឲ្យមេធាវីរបស់ខ្ញុំឲ្យផ្តោតទៅលើតែបណ្តឹងសាទុក្ខ។ មេធាវីមិនអាចចូលរួមសវនាការនៅសំណុំរឿង០០២/០២ នោះទេពីព្រោះថា ប្រសិនបើពួកគាត់ចូលរួមនៅក្នុងនីតិវិធីនាពេលនេះនោះ ពួកគាត់មិនអាចត្រៀមរៀបចំបណ្តឹងសាទុក្ខបានទេ”។ គាត់ក៏បានប្រកាសដែរថា៖ “បន្ទាប់ពីបានរិះគិតយ៉ាងល្អិតល្អន់ និងបន្ទាប់ពីបានពិគ្រោះជាមួយនឹងមេធាវីរបស់ខ្ញុំ ខ្ញុំសម្រេចចិត្តជ្រើសរើសយកបណ្តឹងសាទុក្ខ ពីព្រោះថា នីតិវិធីបច្ចុប្បន្ននេះវាមានសារៈសំខាន់តិចជាងបណ្តឹងសាទុក្ខទេ”។

[០៩:១២:២៣]

ខ្ញុំសូមបន្តការដកស្រង់ទៀត៖ “ដូច្នេះខ្ញុំសូមជម្រាបដល់អង្គជំនុំជម្រះដោយសេចក្តីគោរពថា នៅពេលដែលខ្ញុំ និងមេធាវីការពារក្តីរបស់ខ្ញុំរៀបចំបណ្តឹងសាទុក្ខក្នុងរយៈពេលតម្រូវបានពេញលេញហើយ

នោះ យើងនឹងរីករាយក្នុងការចូលរួមក្នុងសវនាការ០០២/០២”។ ហើយខ្ញុំមិនមានចាំលេខអំពីបណ្ដឹងជិតចិត្តទៅកាន់អង្គជំនុំ -- ទៅកាន់ -- បណ្ដឹងសាទុក្ខសាលាដំបូងនោះទេ។

ខ្ញុំសូមរំឭកផងដែរអំពីសំណើមួយដែលបានដាក់ជូនអង្គជំនុំជម្រះ ដោយអនុប្រធានការិយាល័យរដ្ឋបាល ដែលជាសំណើចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៤ សំណើនេះត្រូវបានដាក់ជូនដោយផ្នែកគាំទ្រការការពារក្ដី ដាក់ជូនទៅអនុប្រធានរដ្ឋបាល។ សំណើនេះសំដៅទទួលបាននូវការចាត់ចែងមូលនិធិឡើងវិញ ហើយនិងការបង្កើនជាបណ្ដោះអាសន្ននូវប្រាក់ដែលត្រូវផ្ដល់ជូនក្រុមមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន សម្រាប់រយៈពេលចាប់ពីថ្ងៃទី០១ ខែតុលា រហូតទៅដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។

តាមអ្វីដែលបានបញ្ជាក់ជូននៅក្នុងឯកសារដែលយើងបានទទួលនោះ ផ្នែកគាំពារការពារក្ដីបានបញ្ជាក់ថា សំណើនេះបន្តពីអនុស្សារណៈ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ដែលចុះហត្ថលេខារួមដោយសហមេធាវីការពារក្ដីលោក នួន ជា និងសហមេធាវីការពារក្ដីលោក ខៀវ សំផន។ នៅក្នុងអនុស្សរណៈនោះមានការស្នើសុំឲ្យមានការបង្កើនចំនួនម៉ោងធ្វើការ និងការបង្កើនប្រាក់បៀវត្សរ៍សម្រាប់ក្រុមការពារក្ដី។ យុត្តិកម្មដែលបានលើកឡើងដើម្បីគាំទ្រដល់សំណើនេះ គឺថាការបង្កើននេះគឺមានភាពចាំបាច់ណាស់ដើម្បីឲ្យពួកគាត់អាចទទួលរងនូវបន្ទុកការងារបន្ថែមទៀត នៅក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។ ដែលក្នុងរយៈពេលប៉ុន្មានខែខាងមុខនោះ។ ពួកគាត់ត្រូវធ្វើភារកិច្ចពីរយ៉ាងសំខាន់បំផុតទន្ទឹមគ្នាគឺ ទី១ ការរៀបចំសារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមថ្ងៃទី០៧ ខែសីហា និងមួយទៀតគឺ ការចូលរួមឲ្យបានពេញលេញទៅក្នុងសវនាការនៅក្នុងសំណុំរឿង០០២/០២។

[០៩:១៥:៣៤]

លោក ខៀវ សំផន ខ្ញុំមានសំណួរផ្ទាល់ទៅកាន់លោក។ តើលោកអាចបញ្ជាក់បានទេថាតើលោកដឹងអំពីសំណើសុំហិរញ្ញវត្ថុ ដែលបានដាក់ជូនដោយមេធាវីការពារក្ដីរបស់លោកទៅកាន់អនុប្រធានការិ-យាល័យរដ្ឋបាល? ហើយប្រសិនបើលោកដឹងថា សំណើនេះគឺ សំណើហិរញ្ញវត្ថុនេះ គឺមានមូលដ្ឋានទៅលើភាពចាំបាច់ក្នុងការធានាបាននូវការរៀបចំសារណាបណ្ដឹងសាទុក្ខ និងការចូលរួមនៅក្នុងសវ-នាការសំណុំរឿង០០២/០២។ លោក ខៀវ សំផន តើលោកយល់សំណួររបស់ខ្ញុំទេ?

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រម។ ខ្ញុំបានដឹងច្បាស់អំពីថា ទាំងអស់គ្នាកំពុងតែខំប្រមូលផ្ដុំធ្វើសារណាបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំ។ នេះក៏តាមសំណូមពររបស់ខ្ញុំ ហើយគឺខំធ្វើទាំង

យប់ទាំងថ្ងៃ នេះខ្ញុំដឹងច្បាស់ ពីព្រោះខ្ញុំទាក់ទងជាមួយក្រុមការពារក្តីរបស់ខ្ញុំនេះជាប់សឹងតែរាល់ថ្ងៃ។ អស់លោកអញ្ជើញទៅមើលក្នុងបញ្ជីទាក់ទងទូរស័ព្ទក៏ឃើញដែរ។ ខ្ញុំដឹងរឿងនេះច្បាស់ ពិតមែនតែខ្ញុំមិនដឹងពីរឿងល្អិតផ្សេងទៀត ដែលគេអត់ត្រូវការប្រាប់ខ្ញុំទេ។ គេដឹងតែប្រាប់ខ្ញុំតែពីរឿងថា គេខំប្រមូលផ្តុំតាមសំណូមពររបស់ខ្ញុំ តែប៉ុណ្ណឹង។ បាទ អស់លោកសូមជម្រាបប៉ុណ្ណឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ខ្ញុំគិតថាប្រហែលជាមានភាពមិនស៊ីសង្វាក់គ្នា រវាងការដែលនិយាយថា យើងមិនអាចចូលរួមក្នុងសវនាការនៃសំណុំរឿង០០២/០២ និងរៀបចំបិទសារណាបណ្តឹងសាទុក្ខ។ ហើយបន្ទាប់មកមានការដាក់សំណើដើម្បីសុំបង្កើនថវិកា ដើម្បីអាចចូលរួមនៅក្នុងសវនាការ។ ដូច្នេះ ខ្ញុំផ្តល់វេទិកានេះជូនទៅមេធាវីការពារក្តីដើម្បីឲ្យបំភ្លឺទៅលើបញ្ហានេះ។

[០៩:១៨:១៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ឡាវែន! ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំគិតថា មានការមិនយល់គ្នារវាងអង្គជំនុំជម្រះទៅលើទឡ្ហីករណ៍របស់យើងខ្ញុំ។ មុននឹងឆ្លើយទៅកាន់សំណួរ ខ្ញុំសុំរំឭកថាអ្វីដែលយើងបាននិយាយមកដល់ពេលនេះ គឺមិន -- គឺថាវាពាក់ព័ន្ធទៅនឹងគោលការណ៍ធំ គឺវាពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់លោក ខៀវ សំផន ផ្ទាល់ក្នុងការចូលរួមឲ្យបានពេញលេញនៅក្នុងការការពារខ្លួនរបស់គាត់។ ពាក់ព័ន្ធទៅនឹងអនុស្សរណៈនោះ ខ្ញុំគិតថាខ្ញុំត្រូវតែព្រីនមើលសិន ព្រោះថាយើងឥឡូវយើងមានបញ្ហាព្រីនហើយ។ ខ្ញុំគិតថា ពួកយើងមិនបានចុះហត្ថលេខាដែលបញ្ជាក់ថាយើងអាចចូលរួមនៅក្នុងសវនាការ០០២/០២ ហើយរៀបចំបណ្តឹងសាទុក្ខនោះទេ។ ដូច្នេះ អ្វីដែលយើងបានបញ្ជាក់ជូនទៅខាងការិយាល័យរដ្ឋបាលនោះគឺថា យើងបានលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះគឺបានកំណត់សវនាការ០០២/០២ ហើយនៅពេលដែលមានការចេញសាលក្រមនោះ គឺយើងត្រូវតែធ្វើការពីរទន្ទឹមគ្នាគឺ យើងមានសំណើ មានការឆ្លើយតបទៅនឹងសំណើ ទោះបីជាមិនទាន់មានសវនាការលើបណ្តឹងសាទុក្ខក៏ដោយ។ ដូច្នេះខ្ញុំចង់ឆ្លើយផងដែរថា ខ្ញុំគិតថា ទោះបីជាមិនមែនជាខ្លឹមសារសំខាន់នៃការស្នើសុំរបស់យើងក៏ដោយ ក៏យើងឆ្លើយតបថា កាលពីថ្ងៃទី២១ តុលា កន្លងទៅនេះ មានការស្នើ -- ខ្ញុំមិនដឹងថា តើខ្ញុំគួរប្រើពាក្យអីឲ្យច្បាស់លាស់នោះទេ គឺថាមានការលើកឡើងអំពីសំណើសុំធនធានបន្ថែម ដោយសារតែមានការងារពីរទន្ទឹមគ្នា។ ដូច្នេះខ្ញុំសូមរំឭកថា ប្រហែលជាអង្គជំនុំជម្រះមិន

ច្បាស់។ ដូច្នេះខ្ញុំសូមរំឭកថា ចំពោះរដ្ឋបាលគឺគាត់ច្បាស់ហើយ គឺថាមិនទាន់ -- កាលណាមិនទាន់មានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដែលបញ្ជាក់អំពីកាលបរិច្ឆេទនៃការចាប់ផ្ដើមដំណើរការ០០២/០២ នោះ យើងមិនអាចគ្រោងចង់បានធានធានបន្ថែមនោះទេ។ នេះជាចំណុចទី១។

[០៩:២០:៣៩]

អនុស្សរណៈដែលយើងបានធ្វើឡើងកាលពីខែតុលា ឆ្នាំ២០១៤នោះ គឺជាការឆ្លើយតបទៅនឹងខាងគាំពារការពារក្ដីដែលលើកឡើងពាក់ព័ន្ធទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះ។ ហើយឥឡូវនេះយើងមានកាលបរិច្ឆេទរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការចាប់ផ្ដើមសវនាការ០០២/០២ រួចហើយ។ ដូច្នេះខាងអង្គភាពគាំពារការពារក្ដីបានបញ្ជាក់ថា -- ដូច្នេះខាងមេធាវីអាចធ្វើសំណើសុំហិរញ្ញវត្ថុបន្ថែមបាន។ ដូច្នេះអនុស្សរណៈរបស់យើងកាលពីខែតុលានោះ គឺមិនសំដៅទៅលើការស្នើសុំហិរញ្ញវត្ថុបន្ថែមសម្រាប់ការចូលរួមសវនាការ០០២/០២ ទេ គឺជាការធ្វើពាក់ព័ន្ធទៅនឹងនីតិវិធីនៃសវនាការ នៃសំណុំរឿង០០២/០១ ពីព្រោះយើងក៏ដូចជាសាធារណជននោះក៏ថា មិនគិតថា យើងមិនស្នើសុំឲ្យមានការបន្ថែមទ្វេដងនោះទេ ប៉ុន្ដែដោយសារតែវាមានបន្ទុកបន្ថែមសម្រាប់យើងធ្វើបណ្ដឹងសាទុក្ខ។ ដូច្នេះការយើងធ្វើនេះ គឺវាត្រូវការពេលវេលាច្រើនណាស់សម្រាប់បណ្ដឹងសាទុក្ខនេះ។ ហើយក្នុងសំណុំរឿង០០២/០១ នៅពេលដែលយើងធ្វើការ ធ្វើសារណាបញ្ចប់ការពិភាក្សាដេញដោលនោះ យើងទទួលបានថវិកាបន្ថែមសម្រាប់ការធ្វើនោះ។ ដូច្នេះអនុស្សរណៈកាលពីខែតុលា ឆ្នាំ២០១៤ នោះ គឺថាមានន័យដូចគ្នាអ៊ីចឹង យើងមិនមែនថាសុំធនធានបន្ថែមនោះទេ។ ដូច្នេះអង្គជំនុំជម្រះអាចគិតហើយថាតាំងពីដើមមក គឺរយៈពេលដែលបណ្ដឹងសាទុក្ខនោះ គឺគិតរួចមកហើយ ហើយយើងចាប់ផ្ដើមធ្វើការ យើងបែងចែកការងារគ្នា ការងារធ្វើ។ ហើយមិនមែនថាទាល់តែដល់ប៉ុន្មានអាទិត្យ នៅពេលដាក់សារណាបណ្ដឹងសាទុក្ខនោះ ដែលយើងអាចរៀបចំធ្វើការជ្រើសរើសបុគ្គលិកបន្ថែមយកមកធ្វើទេ ព្រោះថាយើងបានរៀបចំការងាររបស់យើងរួចទៅហើយ ដោយផ្អែកទៅលើព័ត៌មានដែលយើងត្រូវការនោះ។

ឥឡូវនេះ ខ្ញុំមានអនុស្សរណៈជាភាសាអង់គ្លេសនៅចំពោះមុខខ្ញុំគឺលោក ឡាវេន៍, នៅកថាខណ្ឌ ១៦។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស សូមអភ័យទោសផងលោកចៅក្រម។ នេះជាការលើកឡើងនៅក្នុងអនុស្សរណៈ។

[០៩:២៣:២២]

(អានភាសាអង់គ្លេស៖) "--ទាំងពីរដែលបានលើកឡើងរវាងខែតុលា និងខែធ្នូ ឆ្នាំ២០១៤ រឿង

ក្តី០០២ នៃមេធាវីការពារក្តីនោះ តម្រូវឲ្យអនុវត្តនូវការងារដ៏សំខាន់ គឺថាច្រើនជាងការងារធម្មតារបស់ខ្លួន។ ជាពិសេសនៅក្នុងរយៈពេលនេះ រឿងការពារក្តី រឿងក្តី០០២ ហ្នឹង ត្រូវពង្រឹងបន្ថែមបណ្តឹងសាទុក្ខទៅលើរឿងក្តី ០០២/០១។ នេះជាកាលៈទេសៈដ៏ពិសេសដែលថាវាមានលក្ខណៈស្មុគស្មាញ សំខាន់ដែលត្រូវការប្រើកិច្ចប្រឹងប្រែងខ្លាំងជាងមុន”។

កថាខណ្ឌ១៨ ខ្ញុំសូមអានជាភាសាអង់គ្លេសបន្តទៀត។

“ការការពារក្តីរឿងក្តី០០២/០២ តម្រូវ គឺថាត្រូវការបង្កើនគឺមានយុត្តិកម្ម គឺថាផ្អែកលើមូលដ្ឋានជាសំខាន់ ដែលការងារត្រូវការដើម្បីបញ្ចប់រឿងក្តី០០២/០១ ហើយជាពិសេសនៅលើបណ្តឹងសាទុក្ខសារណាបណ្តឹងសាទុក្ខដែលមានមូលហេតុថា ទាល់តែមានការបង្កើនថវិការវាងពីខែសីហា បន្តទៅរហូតដល់ខែធ្នូ ឆ្នាំ២០១៤ នោះ។ ទោះយ៉ាងនេះក្តី នៅក្នុងករណីនេះ រឿងក្តី០០២ ក៏ត្រូវតម្រូវការងារដ៏បន្ថែមទៀតទៅលើបណ្តឹងសាទុក្ខលើសាលក្រមនោះ។ ការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងរឿងក្តី ០០២/០២”។

លោកចៅក្រម ដូច្នេះហើយយើងបញ្ជាក់ហើយថាយើងបានរៀបចំពេលវេលាមួយចំនួនសម្រាប់សវនាការសំណុំរឿង០០២/០២។ ខ្ញុំសូមបន្តដកស្រង់ជាភាសាអង់គ្លេសទៀត។

“គួរតែសង្កត់ធ្ងន់ថា ការត្រៀមរៀបចំនេះ គឺត្រូវតែអនុវត្តរវាងខែតុលា រហូតដល់ខែធ្នូ ឆ្នាំ២០១៤ ដោយមិនគិតថាសវនាការលើអង្គសេចក្តីសំណុំរឿង០០២/០២ នេះគឺថាត្រូវបង្អង់រហូតដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤ នោះ”។ (បញ្ចប់ការអានជាភាសាអង់គ្លេស)

[០៩:២៦:០១]

លោកចៅក្រម ឡាវែន៍ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោក គឺយើងបានគ្រោងការរៀបចំសវនាការ ទោះបីជាមិនមានការគ្រោងទុកជាមុនសម្រាប់ខែតុលាក៏ដោយ ព្រោះថាច្បាស់ណាស់ នេះជាបញ្ហារបស់យើង ទោះបីជាយើងផ្តោតទៅលើការងារបណ្តឹងសាទុក្ខ និងការរៀបចំសារណាបណ្តឹងសាទុក្ខដែលមានលក្ខណៈស្មុគស្មាញក៏ដោយ ក៏វាមានសំណើ។ ដូច្នេះយើងត្រូវតែឆ្លើយតបទៅនឹងសំណើព្រោះថារយៈនៃបណ្តឹងសាទុក្ខ វាគិតទៅហើយ។ ដូច្នេះយើងមិនអាចនិយាយថា -- យើងមិនអាចយកអនុស្សរណៈនេះ ដែលហើយយកមកនិយាយថាយើងចង់បានមូលនិធិបន្ថែមពិសេសនោះទេ។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ថា សំណើដែលបានធ្វើឡើងនេះ គឺវាដូចគ្នាទៅនឹងសំណើមុនដែរ ដូចសំណើមុនកាលនៅក្នុងសវនាការ០០២/០១ ផងដែរ ព្រោះថាមានការបង្កើត៧០ភាគរយ។

ដូច្នេះ ខ្ញុំលើកឡើងនេះដើម្បីឲ្យភាគីទាំងអស់ និងអង្គជំនុំជម្រះយល់ច្បាស់។ ខ្ញុំឆ្លើយតបទៅនឹងសំណួរនេះ ពីព្រោះថាវាជាបញ្ហាដែលបានពិភាក្សារួចមកហើយនៅក្នុងសវនាការជាសាធារណៈ ហើយដែលអង្គជំនុំជម្រះយល់ឃើញថា វាសំខាន់ ក៏ប៉ុន្តែនៅក្នុងទស្សនីករណ៍របស់យើង គឺថាយើងគិតថាមានអ្វីផ្សេងទៀតដែលសំខាន់ ដែលយើងមិនត្រូវភ្លេចនោះទេ។ គឺនៅក្នុងដំណាក់កាលនេះ ឥឡូវនេះយើងថ្ងៃទី ២៨ តុលា ២០១៤ ហើយកាលកំណត់គិតទៅហើយ ហើយលោក ខៀវ សំផន គាត់បានចូលរួមក្នុងការការពារក្តីគាត់ជារៀងរាល់ថ្ងៃ។ ដូច្នេះនៅពេលដែលជនជាប់ចោទត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារមួយជីវិតនោះ គាត់ត្រូវតែចូលរួមក្នុងការការពារក្តីរបស់គាត់ឲ្យបានពេញលេញជារៀងរាល់ថ្ងៃជាមួយពួកយើង។

[០៩:២៨:០៥]

លោកចៅក្រម មុននឹងផ្តល់វេទិកានេះជូនមេធាវីការពាក្តី នួន ជា ប្រហែលជាគាត់ចង់និយាយ។ ខ្ញុំយល់ហើយ គឺថាខាងរដ្ឋបាលមិនបានគ្រោងក្នុងការផ្តល់ថវិកាបន្ថែម ឬក៏ថវិកាបន្ថែមសម្រាប់ពួកយើងទេ គឺពួកគាត់មិនបានគ្រោងទុកនោះទេ រហូតទាល់តែមានសេចក្តីសម្រេចច្បាស់លាស់របស់អង្គជំនុំជម្រះក្នុងការកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការ០០២/០២។ ដូច្នេះ នេះជាការយល់ឃើញរបស់មេធាវីការពារក្តី ហើយខាងអង្គភាពគាំពារការពារក្តីក៏បានបញ្ជាក់មកដល់យើងពីចំណុចនេះដែរ។ ដូច្នេះដូចដែលខ្ញុំបានដូចបញ្ជាក់អ៊ីចឹង ទាល់តែថ្ងៃទី១៩ ខែកញ្ញា បានខាងអង្គភាពការពារក្តីបញ្ជាក់មកថា អូ៎!អាចស្នើសុំបន្ថែមបាន អាចសាកល្បងធ្វើទៅ។ ដូច្នេះវាហួសពេលទៅហើយ ដែលយើងទើបតែលើកឡើងនៅពេលនោះៗ។ ដូច្នេះខ្ញុំសូមបញ្ជាក់ម្តងទៀតថា ថ្ងៃនេះយើង២៨ តុលា ទៅហើយ ការកំណត់សម្រាប់ការដាក់បណ្តឹងសាទុក្ខគឺវាគិតទៅមុខរហូត ហើយមានបញ្ហាស្មុគស្មាញជាច្រើនដែលយើងត្រូវដោះស្រាយ។

[០៩:២៩:១៧]

ដូច្នេះខ្ញុំត្រូវតែឲ្យមានការយោគយល់អំពីខាងអង្គជំនុំជម្រះ ដែលយើងនិយាយអំពីការធ្វើរឿងពីរទន្ទឹមគ្នាដំណាលគ្នានោះ។ ដូច្នេះខ្ញុំសូមបញ្ជាក់អំពីឆន្ទៈរបស់លោក ខៀវ សំផន ក្នុងការចូលរួមនៅក្នុងការការពារក្តីរបស់គាត់ ហើយគាត់ធ្វើការនៅក្នុងសំណុំរឿងរបស់គាត់ ក្នុងឋានៈគាត់ជាជនជាប់ចោទ។ ដូច្នេះយើងស្នើសុំឲ្យមានការយោគយល់អំពីអង្គជំនុំជម្រះ ពីព្រោះកាលពីសវនាការឆ្នាំ២០១៣នោះ លោកចៅក្រម ឡាវ៉ែន៍ ក៏លោកបានបញ្ជាក់ផងដែរថា នៅពេលដែលខាងសហព្រះរាជអាជ្ញាស្នើឲ្យមានការរៀបចំសវនាការ០០២/០២នោះ លោកចៅក្រមក៏បានបញ្ជាក់ថា លោកមិនអាចរៀបចំណាយពេល

សម្រាប់សរសេរសាលក្រមផង ហើយមកធ្វើសវនាការ០០២/០២ ផងបានទេ។ ដូច្នេះ ខ្ញុំសូមលើកឡើងនូវឯកសារមួយដែលលោកចៅក្រមលោកបាននិយាយ។ លោកថា "ចំពោះខ្ញុំផ្ទាល់" លោកចៅក្រមបាននិយាយអ៊ីចឹង។ "គឺថានៅពេលដែលយើងមានសវនាការ វាជាការលំបាកណាស់ក្នុងការផ្តោតទៅលើសវនាការផង ហើយក្នុងពេលតែមួយហ្នឹង ត្រូវសរសេរសាលក្រមផងនោះ។ ដូច្នេះ នេះជាបញ្ហាបច្ចេក-ទេស យើងពិបាកធ្វើការទាំងពីរណាស់។ យើងត្រូវតែធ្វើយកផ្លូវមួយណាដើរ។ ដូច្នេះយើងមិនមែនថាជារឿងត្រូវការបុគ្គលិកបន្ថែមទេ។ ចំពោះចៅក្រម គឺយើងត្រូវធ្វើយ៉ាងម៉េចឲ្យមានលទ្ធភាពក្នុងការផ្តោតយ៉ាងស៊ីជម្រៅទៅលើបញ្ហាចម្រូងចម្រាស ហើយវាត្រូវការឲ្យមានពេលវេលាក្នុងការពិចារណា។

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ជាក់ជូនថា ខាងមេធាវីការពារក្តីយើងក៏ត្រូវការការផ្តោតអារម្មណ៍ទៅលើបញ្ហាចម្រូងចម្រាសដូចគ្នាហ្នឹងដែរ។ យើងត្រូវការពេលវេលាច្រើន។ ដូច្នេះការសរសេរបណ្តឹងសាទុក្ខហ្នឹង គឺយើងត្រូវការផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហាចម្រូងចម្រាស ហើយវាត្រូវការពេលវេលាច្រើន។ ហើយចំពោះ -- ដែលចង់ដឹងថា ម្យ៉ាងវិញទៀតនោះលោកចៅក្រម លោក លោកស្រីចៅក្រម លោកប្រធាន! លោក ខៀវ សំផន គាត់បានចូលរួមក្នុងការការពារក្តីរបស់គាត់យ៉ាងសកម្ម។ គាត់បានឆ្លើយតបទៅនឹងបញ្ហាជាច្រើននៅក្នុងសវនាការនេះ ហើយគាត់ធ្វើការយ៉ាងសហការគ្នាជាមួយនឹងមេធាវីរបស់គាត់។ ហើយគាត់បានជម្រាបជូនអង្គជំនុំជម្រះហើយថា គាត់មិនអាចធ្វើរឿងពីរក្នុងពេលទន្ទឹមគ្នាតែមួយទេ។ ពេលនេះ គឺជាពេលសំខាន់ណាស់។ ដូច្នេះ អង្គជំនុំជម្រះលើកឡើងបញ្ហានេះ ដូចជាបញ្ហាដាក់អន្ទាក់យើងអ៊ីចឹង។

[០៩:៣២:០៥]

លោក ខៀវ សំផន ក៏បានបញ្ជាក់ជូនលោក លោកស្រីចៅក្រមហើយ គាត់ក៏អាចបញ្ជាក់នៅទីនេះម្តងទៀតដែរ ព្រោះគាត់ថាមានវត្តមាននៅទីនេះហើយ។ គាត់បានបញ្ជាក់ហើយថាគាត់ -- បើសិន -- មិនអាចចូលរួមបានទេ។ ក៏ប៉ុន្តែបើលោក លោកស្រីចៅក្រមបង្ខំឲ្យគាត់ចូល គាត់ចូល។ ក៏ប៉ុន្តែគាត់នៅតែប្រាប់ឲ្យមេធាវីរបស់គាត់ឲ្យត្រៀមខ្លួន ធ្វើម៉េចគិតតែទៅលើបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ ខ្ញុំដឹងច្បាស់ហើយថា ចំណុចនេះប្រហែលជានឹងអាចកើតឡើងទៀត។

ខ្ញុំសូមរំឭកថា យើងស្ថិតនៅក្នុងសវនាការដែលមានជនជាប់ចោទពីររូប ហើយជាសវនាការច្រើនមិនមែនជាការការពារក្តីរួមគ្នាតែមួយទេ។ យើងការពារក្តីដាច់ដោយឡែកពីគ្នា គឺយើងភាគី -- យើងក្រុមទាំងពីរ គឺថាយើងនៅដាច់ដោយឡែកពីគ្នា យើងអាចជ្រើសរើសយុទ្ធសាស្ត្ររៀងៗខ្លួនក្នុងការការពារក្តី

របស់កូនក្តីរបស់យើង។ យើងមិនមែនធ្វើការរួមគ្នា ចូលរួមតែមួយនោះទេ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ថាសំណើនោះបានធ្វើរួចមកហើយ ដែលមានបញ្ជាក់ជូននូវទឡ្ហីករណ៍មួយចំនួន វាមិនមែនតែបញ្ហាហិរញ្ញវត្ថុនោះទេ។ វាមានបញ្ហាក្នុងការ -- នៃលទ្ធភាពរបស់លោក ខៀវ សំផន នៅក្នុងការចូលរួមឲ្យបានពេញលេញក្នុងការការពារខ្លួនរបស់គាត់ គឺនៅក្នុងអនុស្សរណៈ E314/5/1 គឺចុះខែតុលា ឆ្នាំ២០១៤។ យើងបានបញ្ជាក់នៅក្នុងឯកសារនោះរួចហើយថា វាគឺជាការសំខាន់ណាស់សម្រាប់លោក ខៀវ សំផន ក្នុងការធ្វើការ។ ហេតុអីបានជាអង្គជំនុំជម្រះមិនពិនិត្យមើលសេចក្តីសម្រេចរបស់ខ្លួនក្នុងការដំណើរការសវនាការនោះ? បញ្ហា គឺថានៅទីនេះហើយ យើងចង់ យើងត្រូវដឹងថា យើងមកទីនេះមិនមែនមកដើម្បីតែអង្គុយលេងទេ គឺថាយើងមកទីនេះដើម្បីការពារក្តីឲ្យល្អ ហើយពេញលេញដូចអ្វីដែលយើងចង់បាន។ ដូចយើងបានជម្រាបជូនអង្គតុលាការហើយ គឺថាហេតុអ្វីបានជាការធ្វើដំណើរការការពារក្តី -- ធ្វើដំណើរការពីរជាមួយគ្នានេះ ធ្វើឲ្យការការពារក្តីគាត់មិនល្អទេ ពីព្រោះថាការងារនៅក្នុងវាមានសំណុំរឿង០០២/០២ផង ហើយនិងមានការកំណត់ច្បាស់លាស់ ហើយជាន់គ្នាជាមួយ០០២/០១ ផង។ ដូច្នេះ វាពិបាកណាស់។ ហើយនៅតុលាការយូហ្គោស្លាវីនោះគេនិយាយដែរថាគាត់ត្រូវតែមានសិទ្ធិចូលរួមសវនាការ ឬការពារខ្លួនឲ្យបានគ្រប់គ្រាន់។ លោក ខៀវ សំផន គាត់មានពន្យល់ដែរ គឺថាគាត់មានជំងឺផងដែរ ហើយគាត់ធ្វើការយ៉ាងសកម្ម ហើយប្រចាំ ហើយមួយថ្ងៃៗទាល់ល្ងាច គាត់ធ្វើការនៅមុខកុំព្យូទ័ររាល់តែថ្ងៃ។

[០៩:៣៥:១១]

លោក អស់លោកស្រីចៅក្រម គិតថាប្រហែលជាមិនសំខាន់ ឬក៏អាចបំភ្លេចបាន ក៏ប៉ុន្តែចំពោះគាត់ជារឿងសំខាន់ណាស់ ហើយកុំភ្លេចថាយើងកាត់ទោសគាត់ឲ្យជាប់ទោសមួយជីវិតហើយ។ អ៊ីចឹងគាត់ត្រូវតែបំពេញការងាររបស់គាត់ ការពារខ្លួនគាត់ឲ្យបានពេញលេញ ដោយផ្តោតទៅលើការសរសេរសារណាបណ្តឹងឧទ្ធរណ៍។ លោក ខៀវ សំផន មិនដែលបាននិយាយថា គាត់មិនចង់ការពារខ្លួនឲ្យបានពេញលេញនោះទេ។ លោក ខៀវ សំផន ក៏មិនដែលបាននិយាយថា គាត់មិនចង់ចូលរួមសវនាការ ០០២/០២ នេះទេ ក៏ប៉ុន្តែធ្វើយ៉ាងណា បើសិនជាគាត់ចូលរួមកុំឲ្យប៉ះពាល់ដល់ការរៀបចំសារណាឧទ្ធរណ៍របស់គាត់។

ខ្ញុំសូមបញ្ជាក់ផងដែរថា វាមិនមែនជារឿងឆ្មើកឆ្មងអីនោះទេ ដែលត្រូវយល់ពីលោក ខៀវ សំផន ផង។ តើជនជាប់ចោទដែលត្រូវបានគេកាត់ទោសឲ្យជាប់គុកមួយជីវិតហើយនោះ គាត់នៅធ្វើពន្យារ

ពេលដល់ណាទៀត? ព្រោះថា រយៈពេលប្តឹងឧទ្ធរណ៍នេះ គេមិនអាចដោះលែងគាត់នោះទេ។ អ៊ីចឹង ទោះបីយ៉ាងក៏គាត់នៅតែជាប់ទោសមួយជីវិតហើយ។ អ៊ីចឹងគាត់ត្រូវតែផ្តោតទៅលើសារណាបណ្តឹងឧទ្ធរណ៍របស់គាត់។

[០៩:៣៦:២៧]

ឥឡូវនេះខ្ញុំសូមបកទៅនិយាយអំពីធនធានមនុស្សវិញ។ ខ្ញុំស្តាប់អំមិញហាក់ដូចជាយល់ថា មើលតែពួកខ្ញុំហ្នឹងកំពុងតែមិនបំពេញការងារខ្លួនឯងឲ្យបានល្អ។ យើង -- អស់រយៈពេលពីរបីឆ្នាំហើយយើងបានការពារក្តីនៅទីនេះ។ ខ្ញុំសួរថា តើតុលាការដែលយល់ឃើញថា យើងហ្នឹងប្រហែលបំពេញការងារមិនបានល្អ ធ្វេសប្រហែសអីជាដើមនេះ។ មានមូលដ្ឋានអីទេ ដែលលើកឡើងយ៉ាងដូច្នេះ ដើម្បីថាក្នុងន័យថា យើងនេះធ្វើនេះដើម្បីតែរំខានគេនេះ។ ព្រោះយើងគ្រាន់តែចង់ធ្វើ -- ការពារកូនក្តីយើងឲ្យបានល្អទេ។ យើងទទួលការណែនាំពីគាត់។ យើងមានអីក្រៅពីទទួលការប្រឹក្សារបស់គាត់។ សហភាតារបស់ខ្ញុំក៏បាននិយាយដែរ, លោក ខៀវ សំផន ក៏បាននិយាយដែរ ព្រោះថាបណ្តឹងឧទ្ធរណ៍នេះសំខាន់ណាស់។ ហើយលោក លោកស្រីចៅក្រមនឹងកាត់ក្តីសំណុំរឿង០០២/០២បន្តទៀត ហើយបើសិនជាបណ្តឹងឧទ្ធរណ៍យើងនេះ មានលទ្ធផលមិនបានដូចដែលយើងចង់បាន។

ឆ្លើយតបទៅនឹងបញ្ហាធនធាននេះ យើងមិនត្រូវគិតពីរឿងមិនសូវមានប្រយោជន៍នោះទេ។ រឿងបន្ទាប់បន្សំ។ ពីមុនយូរមកហើយ កាលណោះយើងមិនអាចសុំខាងធនធាននេះបន្ថែមបានទេ។ កាលរដ្ឋបាល កាលណោះគេឆ្លើយថា មិនអាចធ្វើបានទេ។ ឥឡូវនេះ យើងមានជនជាប់ចោទមួយដែលថាគេកាត់ទោសឲ្យគាត់ជាប់ទោសនៅតុលាការសាលាដំបូងហើយ។ អ៊ីចឹងយើង -- គាត់មានតែរំពឹងចាំសេចក្តីសម្រេចរបស់តុលាការកំពូលទេ។

[០៩:៣៨:៣២]

នៅពេលដែលយើងនិយាយថា យើងសុំលទ្ធភាពថាមិនចូលរួមសវនាការនេះ បើសិនជាអស់លោក លោកស្រីចៅក្រម នៅតែបន្តបើកសវនាការ យើងមិនអាចចូលរួមបានទេ ព្រោះថាមានការកំណត់ចំពោះរូបយើងទាំងអស់គ្នា ដើម្បីតាក់តែងសារណាបណ្តឹងសាទុក្ខ យើងត្រូវតែបញ្ចប់ជាភាសាបារាំងនៅខែធ្នូ ថ្ងៃ២៩ ធ្នូ យ៉ាងយូរបំផុត។ នេះជាអ្វីដែលយើងបានទទួលបានពីតុលាការកំពូល។ ហើយដូចដែលយើងបានលើកឡើងហើយកាលពីថ្ងៃទី១៧ មេសា យើងមិនចង់ធ្វើអូសពន្លាយពេលវេលាពន្យារនីតិវិធីអីទេ។ បើសិនជាអស់លោក លោកស្រីចង់បង្ខំឲ្យលោក ខៀវ សំផន មកចូលរួមសវនាការ

នេះ គាត់ដឹងតែមកទីនេះហើយ គាត់គ្មានជម្រើសទេ គឺថាមកទាំងបង្ខំចិត្ត គាត់មិនអាចធ្វើការអំពីបណ្ដឹងសាទុក្ខរបស់គាត់បានទេ។ ហើយបើសិនជាយើងខ្ញុំជាមេធាវីនោះអាចបង្ខំយើងបានដែរ ប៉ុន្តែថាយើងមិនអាចបំពេញការងារយើងក្នុងការតាក់តែងសារណាបណ្ដឹងសាទុក្ខ។ ហើយខ្ញុំគិតថាគួរតែគិតអំពីសារៈសំខាន់នៃការ -- រយៈពេលនេះជារយៈពេលសំខាន់ណាស់សម្រាប់ការការពារលោក ខៀវ សំផន។ ខ្ញុំសោកស្ដាយណាស់ដែលភាគី ក៏ដូចជាចៅក្រមមិនយល់ពីគោលជំហរយើង។ អ៊ីចឹងត្រូវយល់ពីចំណុចសំខាន់នេះ គឺថារយៈពេលសំខាន់ណាស់ យើងគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់យើង។ អស់លោក លោកស្រីចៅក្រមមិនអាចបង្ខំយើងបានទេ ត្រង់ចំណុចនេះ។

ខ្ញុំគិតថា នៅពេលដែលអស់លោក លោកស្រីចៅក្រមចង់និយាយថា បញ្ហាត្រង់ថាជាបញ្ហាធនធានមនុស្ស បញ្ហាចង់ ឬមិនចង់ចូលរួមសវនាការនេះ ខ្ញុំគិតថានេះមិនមែនជាបញ្ហាសំខាន់ទេ។ បញ្ហាសំខាន់គឺជារឿងអាយុជីវិតលោក ខៀវ សំផន។ ហើយយើងយល់ នៅពេលដែលលោក លោកស្រីចៅក្រមសុំឱ្យយើងមកចូលរួមសវនាការប្រជុំរៀបចំសវនាការនេះ យើងអាចមកបាន ក៏ប៉ុន្តែកាលណាយើងមកប្រជុំនៅទីនេះ គឺថាយើងខកខានមិនបានសរសេរសារណាប្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផនហើយ។ ហើយដែលយើងគិតថា ការប្រមូលផ្ដុំផ្ចង់អារម្មណ៍ទៅលើការតាក់តែងសារណាបណ្ដឹងសាទុក្ខនេះគឺសំខាន់ជាងចំពោះលោក ខៀវ សំផន។

[០៩:៤១:៣៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រី ហ្គីសសេ សំណួររបស់ខ្ញុំតូចជាងហ្នឹងទេ។ ខ្ញុំសួរសំណួរអំមិញនេះខុសពីហ្នឹងទេ ខ្ញុំបានស្ដាប់លោកស្រីដោយយកចិត្តទុកដាក់ ហើយខ្ញុំសង្ឃឹមថាលោកស្រីនឹងឆ្លើយនឹងសំណួរខ្ញុំបានច្បាស់ជាងនេះបន្ទាប់មកទៀត។

ពេលដែលថាការតតាំងចុងក្រោយហើយនោះ រហូតដល់ពេលចេញសាលក្រមនេះ តើមានធ្វើអីទៀតទេក្នុងចន្លោះពេលហ្នឹង? ដូចជាក្រុម នួន ជា ដែរ គឺថាលោកស្រីបានមានទទួលធនធានហិរញ្ញវត្ថុធ្វើយ៉ាងណា ដើម្បីឱ្យបានទទួលប្រាក់បៀវត្សរ៍ពេញខែ ដូចក្រុមការពារក្ដីផ្សេងទៀតដែរ។ អ៊ីចឹង ខ្ញុំសួរថា តើចន្លោះពេលហ្នឹងនេះ! ចង់១០ខែហ្នឹង តើលោកស្រីបានធ្វើអីខ្លះ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ឡាវែន៍ នេះដូចខាង ឌី.អេស.អេស បានពន្យល់ហើយគឺថា យើងនៅធ្វើការនៅ

ទីនេះ គឺថាយើងបង្ហាញពីបរិមាណការងារយើងជាប្រចាំថ្ងៃ។ ការងារយើងនៅត្រៀមលក្ខណៈសំណុំរឿង០០២/០២ នេះគឺថាដូចកាលពីសវនាការបឋមនេះ ថាមានការកំណត់នូវចំនួនដែលផ្តល់ទៅភាគីថាឲ្យបញ្ជីឈ្មោះសាក្សី បញ្ជីឯកសារភស្តុតាងអីជាដើម។ ថាក្រុម ខៀវ សំផន កាលនោះបានជាក្រុមតែមួយទេ ដែលគោរពការកំណត់អង្កាល់នោះៗ។ ហើយយើងបានបំពេញការងារនោះ ដែលស៊ីពេលជាច្រើនខែនៅក្នុងសំណុំរឿង០០២/០២នេះ ជាការពិនិត្យលើភស្តុតាងឯកសារជាច្រើន ដើម្បីត្រៀមលក្ខណៈបណ្តឹងឧទ្ធរណ៍។ ហើយទាក់ទងទៅនឹងបញ្ហាច្បាប់នានា ដូចជាក្រុមការពារក្តីផ្សេងៗផងដែរលោកចៅក្រម គេក៏ធ្វើអ៊ីចឹងដែរ។

ខ្ញុំគិតថា យើងត្រូវតែ -- ខ្ញុំគិតថាធ្វើយ៉ាងណាកុំឲ្យក្រុមការពារក្តីនោះបែរខ្នងដាក់ចៅក្រម ព្រោះថាយើងក្រុម នួន ជា ក៏គាត់ធ្លាប់បានលើកឡើងដែរគឺថា នៅពេលមានការកាត់បន្ថយ ហើយនិងការប្រឹងប្រែងជាខ្លាំងនោះ ក៏ប៉ុន្តែកុំភ្លេចថាក្រុមការពារក្តីយើងទាំងពីរនេះ ទោះបីយ៉ាងណាក្តីយើងមានយុត្តិសាស្ត្រផ្សេងៗគ្នា។ ព្រោះលោក អស់លោក លោកស្រីចៅក្រមកំពុងធ្វើ សរសេរសាលក្រម ហើយពេលនោះក្រុមការពារក្តីគេកំពុងតែសិក្សាអំពីនេះដែរ អំពីត្រៀមលក្ខណៈរឿងប្តឹងឧទ្ធរណ៍អីដែរ។ ខ្ញុំមិន -- ខាងក្រុម ខៀវ សំផន នេះនៅពេលដែលសរសេរចេញសាលក្រមមកហើយនេះ យើងឃើញថាពេលដែលនិយាយអំពីរឿងថា លោក ខៀវ សំផន ចូលរួមក្នុងការជម្លៀសប្រជាជនអីជាដើមនេះ អ៊ីចឹងហើយបានជាយើងចំណាយពេលជាច្រើនដើម្បីធ្វើសារណាប្តឹងឧទ្ធរណ៍។ អ៊ីចឹងកាលណាដែលយើងគិតថារយៈពេលទាំងប៉ុន្មានខែនោះ ក្រុមការពារក្តីមិនបានធ្វើអ្វីទាំងអស់នោះ ក៏ដូចជាមិនត្រឹមត្រូវទេ។ ខ្ញុំគិតថា យើងត្រូវតែគោរពខាងការពារក្តីផងដែរ ពីព្រោះថាយើងបំពេញការងារជាបន្តបន្ទាប់មកដែរ។

[០៩:៤៥:៥២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកស្រីបានលើកឡើងថា បញ្ហាធនធានមនុស្សមិនមែនជាបញ្ហាតែមួយទេ។ អ៊ីចឹងហើយបានជាលោកស្រីមិនចង់ចូលសវនាការ ក៏ប៉ុន្តែខ្ញុំឃើញថា ហាក់ដូចជាបញ្ហាដែលខាងការពារក្តីលើកឡើងទេ មិនមែនជាបញ្ហារបស់តុលាការទេ។ ខ្ញុំមិនដឹងថាឆ្លើយតបទៅនឹងសំណើរបស់លោកស្រីយ៉ាងម៉េចទេ គឺថាស្នើទៅខាងរដ្ឋបាលតាមរយៈ ឌី.អេស.អេស តើលោកស្រីអាចជម្រាបជូនបានទេថាចម្លើយ ការឆ្លើយតបល្អ វិជ្ជមាននោះ មានផលប៉ះពាល់យ៉ាងម៉េច? តើលោកជាមេធាវីនេះ អាចមានពេលទំនេរជាងហ្នឹង ឬក៏លោកស្រីជាប់ការពារក្តីកន្លែងផ្សេងៗទៀត ឬក៏យ៉ាងម៉េច?

**កញ្ញា អង់តា ហ្គីសសេះ**

ដូចខ្ញុំបានលើកឡើងអម្បាញ់មិញហើយ បើសិនជាមានការតម្លើង ១៦ភាគរយនោះ គឺថាបើមានសារណានៅក្នុងសំណុំរឿង០០២/០២ នេះគេអាចធ្វើការបានលឿនជាងហ្នឹង កុំឲ្យធ្វើការលើសម៉ោងរហូត។ ហើយធ្វើយ៉ាងនេះដើម្បីឲ្យយើងអាចការពារសិទ្ធិរបស់លោក ខៀវ សំផន បានព្រោះថា គ្មានកាលកំណត់ជាច្រើន។ ខ្ញុំមិនដឹងថា លោក ខៀវ សំផន ហ្នឹងអាចគាត់នៅពេលនៅក្នុងមន្ទីរឃុំឃាំង ហើយគាត់ធ្វើការលើបណ្ដឹងសាទុក្ខផង មកសវនាការផង បើសិនជាយើងត្រូវបើកសវនាការ ០០២/០២ នេះ គឺថាយើង -- ខ្ញុំមិនដឹងថាអានេះវាលក្ខណៈគណិតវិទ្យាទៅហើយ តក្កវិទ្យាទៅហើយ កាលណាចូលមកសវនាការផង ធ្វើសារណាសាទុក្ខផង ពិបាកណាស់។

[០៩:៤៧:៤៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំសង្កេតឃើញថាកាលខែតុលា -- ១៧ តុលា ពុំមានសវនាការអីទេ។ ប៉ុន្តែសវនាការលើអង្គសេចក្ដីប្រហែលជាចាប់ផ្ដើមនៅថ្ងៃទី១២ វិច្ឆិកា។ អង្គជំនុំជម្រះនឹងចាប់ផ្ដើម គ្រាន់តែនឹងធ្វើតែបីថ្ងៃក្នុងមួយសប្ដាហ៍ទេ អ៊ីចឹងបានន័យថា សម្រាប់ខែវិច្ឆិកានេះ គឺយើងធ្វើតែប្រាំបួនថ្ងៃទេ។ ខែធ្នូ មានការសម្រាកប្រចាំឆ្នាំ អង្គជំនុំជម្រះចង់បើកសវនាការតែ ប្រាំបួនថ្ងៃដែរគឺ បីសប្ដាហ៍ – មួយសប្ដាហ៍បីថ្ងៃ។

ឥឡូវនេះ ខ្ញុំសូមសំណួរមួយ គឺថាតើលោកស្រីមានគំនិតយោបល់អីទេ ទាក់ទងទៅនឹងថ្ងៃបើកសវនាការទាំងអស់នេះ?

**កញ្ញា អង់តា ហ្គីសសេះ**

បើសិនជាសុំគំនិតពីខ្ញុំ បើសិនជាតុលាការគិតថាចំនួនថ្ងៃប៉ុន្មានថ្ងៃនេះថាតិច ប៉ុន្តែចំពោះពួកយើងគឺថាច្រើនណាស់ ពីព្រោះយើងត្រូវការសរសេរសារណា។ បើសិនជាយើងអាចសុំឲ្យតុលាការកំពូលផ្ដល់ពេលឲ្យយើងប្រាំបួនថ្ងៃ មកទៀតមករយៈពេលដែលធ្វើសវនាការនេះ មកយើងអាចធ្វើបាន។ យើងមកទីនេះ យើងមិនមែនមកដើរ មកឈរឲ្យគេថត ឃើញដូចតួកុនអីទេ យើងមកការពារក្ដី។ អ៊ីចឹងមកអង្គុយហើយ អត់មានអារម្មណ៍នៅក្នុងខ្លួន ការពារមិនកើត ក៏អត់កើតដែរ។ អ៊ីចឹងបើ អង្គាល់លោកស្រី ខាតវ៉ាយថ៍ នៅទីនេះគឺថា គាត់និយាយថាមកក្នុងសវនាការនេះគឺមកគ្រាន់តែ -- បើអ៊ីចឹងគឺថាប្រសិនជាអស់លោក លោកស្រីចៅក្រម បូកពេលវេលាហ្នឹងបន្ថែមមកឲ្យយើងខ្ញុំ អាចធ្វើបាន។ ក៏ប៉ុន្តែការត្រៀមលក្ខណៈសរសេរសារណាបណ្ដឹងឧទ្ធរណ៍នេះ មួយថ្ងៃៗសំខាន់ណាស់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកស្រីមេធាវី តើលោកស្រីអាចសួរថា តើអាចមានពេលទំនេរជាងហ្នឹង ឬក៏មានការពារក្ដីកន្លែងផ្សេងទៀតទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

សព្វថ្ងៃនេះ ដោយសារខ្ញុំធ្វើការឲ្យការពារលោក ខៀវ សំផន នេះ ខ្ញុំគ្មានការងារនៅកន្លែងណាផ្សេងទៀតទេលោកចៅក្រម។ ខ្ញុំបញ្ឈប់អស់ហើយ។

[០៩:៥០:៥៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ទាក់ទងនឹងពេលវេលា ទាក់ទងនឹងកាលបរិច្ឆេទ ក្រុម ខៀវ សំផន ថាចាប់ពីពេលណាអាចចូលរួមសវនាការ០០២បាន? ខ្ញុំសូមរំឭកថា ភាគីបានដាក់សារណារបស់ -- បណ្ដឹងឧទ្ធរណ៍របស់ខ្លួនថ្ងៃទី២៩ ខែកញ្ញា ហើយនេះបន្ទាប់ពីពេលការដាក់នេះ ក្រោយពីពេលដែលបានពន្យារពេលវេលាឲ្យហើយ។ បើតាមវិធាន១០៧/៤ ដែលថា សារណាបណ្ដឹងឧទ្ធរណ៍ត្រូវតែដាក់នៅក្នុងរយៈពេល៦០ថ្ងៃក្រោយការដាក់ ក្រោយសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ គឺគិតទៅមុនថ្ងៃទី២៨ វិច្ឆិកា ខាងមុខ។ ក៏ប៉ុន្តែភាគីបានសុំពន្យារពេលដើម្បីដាក់សារណាបណ្ដឹងឧទ្ធរណ៍។ ភាគីដឹងឮទាំងអស់គ្នាហើយ សហព្រះរាជអាជ្ញា ហើយនិងក្រុម នួន ជា សុំពន្យារពេលរហូតដល់ថ្ងៃទី២៩ ធ្នូ ខាងមុខនេះ។ ខ្ញុំដឹងថា ក្រុម ខៀវ សំផន សុំការពន្យារពេលដើម្បីឲ្យគាត់ដាក់សារណាគាត់នៅក្នុងរយៈពេល ១៧៤ថ្ងៃ ចាប់គិតពីកាលនៅថ្ងៃជូនដំណឹងអំពីបណ្ដឹងសាទុក្ខ គឺថាគាត់អាចចូលរួមត្រឹមចុងខែ៣ ខែមីនា ឆ្នាំ២០១៥ទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោក លោកស្រី ចៅក្រម ខ្ញុំបានឆ្លើយរួចទៅហើយនូវចម្លើយនេះៗ ទៅនឹងសំណួរនេះៗ។ ហ្នឹងទាក់ទងទៅនឹងកាល ពេលវេលាសុំនៅក្រុម នួន ជា ហើយនិងក្រុមខៀវ សំផន នេះគឺថា ក្នុងការសុំពេលវេលាយើងនេះ យើងគិតតាំងពីពេលបកប្រែផង ហើយការឆ្លើយតបទៅក្រុម -- នៅក្រុម នួន ជា អត់បានគិតដូចខ្ញុំទេ។ ហើយ១៧៤ថ្ងៃនេះ គឺថាយើងគិតការសរសេរជាភាសាដែលយើងប្រើប្រាស់។ អ៊ីចឹង ការដែលយើងមិនមានពេលទំនេរ គឺថាដោយសារយើងគិតពីរឿងសារណានេះ គឺថារហូតដល់ពេលយើងសរសេរសារណានេះចប់នៅថ្ងៃទី២៩ ធ្នូ។ អ៊ីចឹង ការខុសគ្នារវាងក្រុមទាំងពីរនេះគឺថាពាក់ព័ន្ធនឹងពេលវេលាការបកប្រែដែរ ហើយនិងការឆ្លើយតបទៅនឹងខាងសហព្រះរាជអាជ្ញា។ ហើយក៏ប៉ុន្តែទោះ

យ៉ាងណាក្តី យើងយល់ស្របថាយើងនឹងសរសេរចប់នៅថ្ងៃទី២៩ ធ្នូ ចំពោះសារណាបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន នេះ។

[០៩:៥៤:០៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹង ថ្ងៃទី២៩ ធ្នូ គឺជាថ្ងៃដែល ដែលអស់លោក លោកស្រីគិតថាអាចចូលរួមសវនាការសំណុំរឿង០០២បាន?

**កញ្ញា អង់តា ហ្គីសសេ៖**

ប្រហែលជា ថ្ងៃសរសេរ -- សរសេរចប់ហ្នឹង វា២៩មែន ក៏ប៉ុន្តែគិតថាខែ -- ដើមខែ១ ឆ្នាំ២០១៥ ប្រហែលជាសមរម្យជាង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំសុំសេចក្តីបំភ្លឺមួយ។ ខ្ញុំគិតថាប្រហែលជាមានចម្លើយរបស់សហព្រះរាជអាជ្ញា ការឆ្លើយតបពីព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ហ្នឹងហើយ។ ក៏ប៉ុន្តែតើនៅពេលលោក លោកស្រី គិតថាឆ្លើយតបទៅនឹងសារណាតបរបស់ភាគីផ្សេងៗនេះ តើលោកស្រីគិតថាមានការប៉ះពាល់ដែរទេក្នុងការចូលរួមក្នុងសំណុំរឿង០០២នោះ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាមិនសំខាន់ទេ ពីព្រោះថាអ្វីដែលសំខាន់ជាងគេបំផុតចំពោះយើង គឺថាយើងគ្រាន់តែសរសេរសារណា យកពេលសរសេរសារណាបណ្តឹងឧទ្ធរណ៍ឲ្យអស់ទេ ហើយនៅពេលក្រោយៗទៀតបន្តបន្ទាប់នោះ គឺយើងគិតថាការបរិមាណការងារឆ្លើយតបនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអីនោះវាៗ -- ខ្ញុំគិតថាមិនជាការងារសំខាន់ ឬក៏ធំដុំប៉ុន្មានទេ ពីព្រោះថាវាអាស្រ័យលើទឡ្ហីករណ៍របស់ភាគីបន្តិចបន្តួចតែប៉ុណ្ណឹងទេ។ ក៏ប៉ុន្តែការសរសេរសារណាបណ្តឹងសាទុក្ខគាត់នេះសំខាន់ណាស់ ហើយតុលាការកំពូលលោកបានកំណត់កាលបរិច្ឆេទពេលវេលាឲ្យយើងច្បាស់លាស់។

[០៩:៥៦:១១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោក លោកស្រីគិតថាលោកបានធ្វើសំណើទៅខាងរដ្ឋបាលនៅពេលហ្នឹង តើជាផ្លូវការលោកបានស្នើសំណើអីខ្លះទៅរដ្ឋបាលអ្វីខ្លះ? ហើយដែល -- ហើយលោកស្រីទើបតែ -- ពីមុនមកមិនដែលបាន

ប្រាប់យើងទេ។ តើបានស្នើអីខ្លះ? ឧទាហរណ៍ៗ ផ្នែកធនធាន ផ្នែកបកប្រែអីជាដើមនេះ។ តើត្រូវការដែរទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

កាលពីសប្តាហ៍មុនលោក ឆាលស៍ ហ្សាម៉ា បានពន្យល់អំពីការយឺតយ៉ាវផ្នែកបកប្រែជាដើមនេះ ខ្ញុំ អង្កាល់នោះ ខ្ញុំគិតថាមានការជ្រើសរើសបុគ្គលិកថែម។ ខ្ញុំគិតថាក្រុមយើងនេះតែងតែដាក់សារណាទៅដើម្បីឲ្យបកប្រែជាអត្ថិភាព ព្រោះបើសិនជាផ្នែកបកប្រែនេះគាត់ថាបញ្ហាហ្នឹងមិនអាចដោះស្រាយបាន ខ្ញុំនឹងខ្ញុំមិនជឿគាត់ដែរ។ ក៏ប៉ុន្តែលោក ហ្សាម៉ា–ឆាលស៍ ហ្សាម៉ា បានពន្យល់កាលសវនាការលើកមុនមកហើយ ថាបើមាន -- ក៏មានការកំណត់អត្ថិភាពការបកប្រែជាដើមដែរ ហើយឥឡូវនេះមានបញ្ហាមួយចំនួនដែលថាយើងមិនទាន់ដោះស្រាយហើយ។ គឺថាខាងផ្នែកបកប្រែនេះគេបានបកប្រែឲ្យយើង ក៏ប៉ុន្តែថាវាពេលខ្លះហ្នឹងយើងចាំយូរ មានបញ្ហាច្រើនដែរ យើងសង្ឃឹមថានឹងមានការពន្លឿនល្បឿន ហើយជាការសំខាន់ណាស់ព្រោះថាពេលសរសេរសារណា ឬសំណើជាដើមត្រូវការបកប្រែ។ ភាគីខ្លះហ្នឹងគេ ភាគីខ្លះគេប្រែជាភាសាអង់គ្លេស ហើយយើងសរសេរសារណាជាភាសាបារាំង ពេលខ្លះគេមិនអាចទទួលព័ត៌មានបាន គេមិនដឹងថាយើងសរសេរៗអ្វីខ្លះនោះទេ។

[០៩:៥៨:៥០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រីចង់ -- មិនចង់សម្រុះសម្រួលជាមួយអង្គជំនុំជម្រះទេ លើកលែងតែចាប់ផ្តើមសវនាការ០០២/០២នេះ នៅដើមឆ្នាំក្រោយនោះទេ បើមិនអ៊ីចឹងទេគឺថាលោកស្រីនឹងមិនមានវត្តមានទេពីពេលនេះទៅដល់ពេលដាច់ឆ្នាំ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោក លោកស្រី បើសិន -- នៅពេល -- ដរាបណាដែលយើងគិតថាបើផលប្រយោជន៍របស់លោក ខៀវ សំផន គឺត្រូវតែសរសេរសារណាសាទុក្ខនោះឲ្យចប់នោះ អ៊ីចឹងគឺក្នុងករណីហ្នឹងគឺយើងមិនអាចចូលរួមបានទេលោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមកត់ត្រាទុក។ ខ្ញុំមិនបានប្រើពាក្យ“*កុំប្រមឹស្បុង*”ទេអំមិញនេះ គឺខ្ញុំប្រើពាក្យ“*កុំប្រមឹស៍*”។

បាទ ខ្ញុំលែង -- ខ្ញុំអស់សំណួរអ្វីសួរទៅកាន់ក្រុម ខៀវ សំផន ទៀតហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

[១០:០០:០០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរខ្លីៗមួយចំនួនទៅលោក ខៀវ សំផន បន្តពីអ្វីដែលលោកបានបញ្ជាក់ពីខាងដើម ហើយបន្ទាប់មកមានសំណួរចុងក្រោយទៅមេធាវីការពារក្តី។ ខ្ញុំនឹងសួរសំណួរទៅលោក ខៀវ សំផន។ លោកបាននិយាយពីខាងដើមថា ក្នុងចំណោមការងារមួយចំនួនដែលលោកមានទំនាក់ទំនងរៀងរាល់ថ្ងៃជាមួយមេធាវីរបស់លោក។ សំណួររបស់ខ្ញុំ គឺសួរលោកពីបញ្ហានេះ គឺថាស្ទើរតែរៀងរាល់ថ្ងៃនោះ តើលោកបានជួបឬក៏ទាក់ទងជាមួយមេធាវីញឹកញាប់ប៉ុនណាក្នុងរយៈពេលពីរសប្តាហ៍ចុងក្រោយនេះ?

**លោក ខៀវ សំផន៖**

បាទ ខ្ញុំបានបញ្ជាក់មែន ថាខ្ញុំទាក់ទងតាមទូរស័ព្ទជាប់ជាមួយក្រុមការពារក្តីរបស់ខ្ញុំ មានលោកស្រី ជាតា នេះជាដើម។ ម៉្យាងទៀត លោកស្រី ម៉ារី ក៏បានទៅជាមួយលោកស្រី ជាតា ទៅបន្ទប់ខ្ញុំទៅសួរបញ្ជាក់លើចំណុចណាដែលគាត់មិនច្បាស់អំពីសំណុំរឿងរបស់ខ្ញុំ ដើម្បីគាត់រៀបចំសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំឱ្យបានពិស្តារ ពីព្រោះសារណានេះមានចំណុចជាច្រើនដែលត្រូវឆ្លើយតបទៅវិញ។ នេះខ្ញុំសូមបញ្ជាក់ឱ្យច្បាស់អ៊ីចឹង ហើយអញ្ជើញទៅឆែកមើលនៅបញ្ជី ទៅពិនិត្យ ទៅជួបខ្ញុំចុះ នៅមន្ទីរឃុំឃាំង លោកស្រីនឹងឃើញច្បាស់។ បាទ សូមជម្រាបប៉ុណ្ណឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំអាចពិនិត្យមើលបញ្ហានេះបាន។ ដើម្បីកំណត់ត្រាតុលាការ តើលោកអាចថាផ្តល់ជាគំនិតថាតើញឹកញាប់ប៉ុនណានៅក្នុងពីរសប្តាហ៍ចុងក្រោយនេះ ដែលលោកបានជួបសមាជិកក្រុមមេធាវីរបស់លោក ឬក៏លោកទំនាក់ទំនងតាមទូរស័ព្ទអីជាដើមនោះ?

[១០:០២:២១]

**លោក ខៀវ សំផន៖**

ពេលវេលាទូរស័ព្ទ ខ្ញុំត្រូវការទូរស័ព្ទរកឯកសារដែលមានយោងជាច្រើននៅក្នុងការកាត់ទោសរបស់ខ្ញុំនោះ។ អាហ្នឹងម៉្យាង ប៉ុនម៉្យាងទៀត ខ្ញុំសុំឱ្យគេមកយកអ្វីដែលមកចម្លង អ្វីដែលខ្ញុំបានវាយនៅ

ក្នុងសារណាឧទ្ទរណ៍របស់ខ្ញុំ យកទៅជូន ម៉ារី និងលោកស្រី ជាតា មើល អាន។ អាហ្នឹង ខ្ញុំសុំជម្រាប ជាខ្លឹមសារប៉ុណ្ណឹង។ ហើយរឿងទាក់ទងហ្នឹងសឹងតែរាល់ថ្ងៃ ទៅឆែកមើលបញ្ជីទូរស័ព្ទមើលចុះ។ ហើយលោកស្រី ម៉ារី ក៏ទៅបញ្ជាក់ទៀត ត្រូវការទៅបញ្ជាក់ទៀត ពីព្រោះអាន ខ្ញុំវាយកុំព្យូទ័រហើយវាមិនច្បាស់។ គាត់ត្រូវតែសុំបញ្ជាក់ទៀត។ រាល់អាទិត្យៗ ខ្ញុំបញ្ជាក់ថារាល់អាទិត្យបាទ។

**ចៅក្រម កាតា ហ្វេនស៍៖**

ខ្ញុំយល់ថាជាព័ត៌មានច្រើន គឺទាក់ទងនឹងបញ្ហាថ្ងៃនេះផងដែរ។ សំណួរបន្ទាប់របស់ខ្ញុំនោះ ខ្ញុំសួរទៅខាងមេធាវីការពារក្ដីរបស់លោក ខៀវ សំផន។

**លោក ខៀវ សំផន៖**

ខ្ញុំបានសុំឱ្យ ម៉ារី វាយការណ៍ទៅមេធាវីរបស់ខ្ញុំ គាត់នៅ ប៉ារីស។ ទោះបីមេធាវីខ្ញុំនៅប៉ារីសក៏ដោយ ក៏ទាក់ទងគ្នាជាប់ តាមដានរឿងរៀបចំហ្នឹងជាប់។ ខ្ញុំឃើញអ៊ីចឹងច្បាស់។

[១០:០៥:១៩]

**ចៅក្រម កាតា ហ្វេនស៍៖**

សំណួរខ្ញុំសួរទៅមេធាវីការពារក្ដី ប៉ុន្តែមុននឹងសួរសំណួរនេះ ខ្ញុំចង់ព្យាយាមសង្ខេបនូវអ្វីដែលបានបញ្ជាក់ក្នុងរយៈពេល ៣០នាទីចុងក្រោយនេះ។ ខ្ញុំព្យាយាមពិនិត្យឱ្យយល់ខ្លឹមសារដើម្បីយើងដឹងថាតើយើងដល់ដំណាក់កាលណា។ មុននឹងឈានដល់បញ្ហានោះ ខ្ញុំចង់រំឭកដល់ភាគីទាំងអស់ថា ជាពិសេសមេធាវីការពារក្ដី នេះមិនមែនអង្គជំនុំជម្រះនេះទេដែលជាអ្នកព្យាយាម មិនមែនតែអង្គជំនុំជម្រះម្នាក់ឯងទេដែលព្យាយាមចង់ដើរទៅមុខ ហើយអង្គជំនុំជម្រះសាលាកំពូលក៏បានជំរុញដែរក្នុងឆ្នាំចុងក្រោយនេះ គឺថារឿងក្ដី០០២/០២ ត្រូវតែចាប់ផ្ដើមឱ្យបានឆាប់បំផុតជាមួយអង្គជំនុំជម្រះដដែល ឬក៏អង្គជំនុំជម្រះតាមជម្រើសផ្សេងទៀត។ ជាពិសេសទាក់ទងទៅនឹងភាពចាំបាច់នៃការបន្តទៅមុខឱ្យបានលឿនតាមតែអាចធ្វើទៅបាន។ នេះគឺជាការបញ្ជាក់របស់សាលា អង្គជំនុំជម្រះសាលាកំពូល។ ហើយខ្ញុំចង់ដឹងពីមេធាវីការពារក្ដីថា តើមានកង្វះធនធានអ្វី ឬក៏ក្នុងឋានៈលោកស្រីជាមេធាវីការពារក្ដីមិនអាចធ្វើរឿងពីរក្នុងពេលតែមួយបាន។ ហើយតើឱកាសណាមួយដែលចាំបាច់សម្រាប់យើងត្រូវពិចារណា។ អ៊ីចឹងបញ្ហាជាក់ស្ដែងថាតើហេតុបានជាមេធាវីការពារក្ដី នួន ជា អាចធ្វើបាន ប៉ុន្តែលោកស្រីគឺថា បញ្ជាក់ថាគេមានយុត្តិសាស្ត្រផ្សេង ហើយខ្ញុំមិនឃើញថា នេះជាការឆ្លើយតបទៅនឹងការរៀបចំការងាររបស់លោកស្រី។ ហើយចំណុចទី១ ដែលលោកស្រីមេធាវីបញ្ជាក់ថា៖ “កូនក្ដីរបស់យើងខ្ញុំមិនអាចចូលរួមបានក្នុងការងារ

ពីរក្នុងពេលតែមួយ រៀបចំសារណាផង ចូលរួមសវនាការ”។ ដូច្នេះខ្ញុំចង់ស្ដាប់លោកស្រីមេធាវីនិយាយដោយខ្លី កុំនិយាយពីទឡ្ហីករណ៍វែង។ និយាយពីបញ្ហាធនធាន ឬក៏អលទ្ធភាពក្នុងវិជ្ជាជីវៈផ្ទាល់ខ្លួនមិនអាចធ្វើការងារពីរក្នុងពេលតែមួយ មួយក្នុងនាមលោកស្រីមេធាវី ហើយនិងកូនក្ដីរបស់លោកស្រីមេធាវី។ ដូច្នេះសូមបញ្ជាក់បែបនេះ។ សូមអរគុណ។

[១០:០៦:៣៧]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។

ខ្ញុំបាទ គង់ សំអុន សូមចូលរួមឆ្លើយនឹងសំណួររបស់លោកស្រីចៅក្រម។ បញ្ហាដែលយើងផ្ដោតទៅលើការការពារក្នុងការសរសេរបណ្ដឹងសាទុក្ខជាជាងការចូលរួមក្នុងសវនាការ ហើយដែលយើងបានជម្រាបជូនអង្គជំនុំជម្រះថា យើងមិនអាចធ្វើការងារពីរក្នុងពេលតែមួយបាននេះ វាជាបញ្ហាផលប្រយោជន៍របស់កូនក្ដីរបស់យើង។ ដោយសារយើងគិតទៅលើប្រសិទ្ធភាពនៃការការពារ។ មិនមែនមានន័យថាយើងមិនអាចធ្វើកិច្ចការទាំងពីរហ្នឹងបានទេ។ យើងអាចធ្វើបាន ប៉ុន្តែការធ្វើហ្នឹងវាក្លាយទៅជា គ្រាន់តែជានិមិត្តរូប គ្រាន់តែជាការបង្គ្រប់កិច្ច វាគ្មានប្រសិទ្ធភាពសម្រាប់ការការពារ។ នេះហើយជាចំណុចដែលយើងយល់ថាវាផ្ទុយនឹងវិជ្ជាជីវៈរបស់ខ្លួន ផ្ទុយនឹងសម្បជញ្ញៈជាមេធាវី។ វិជ្ជាជីវៈរបស់យើងមិនអនុញ្ញាតឲ្យយើងធ្វើកិច្ចការណាដែលជាគ្រាន់តែជាលំៗដែលឲ្យតែបានដើម្បីបង្គ្រប់កិច្ចទេ។ យើងត្រូវគិតពីផលប្រយោជន៍របស់កូនក្ដីរបស់ខ្លួន ហើយនិងផលប្រយោជន៍យុត្តិធម៌ផងដែរ។ បើសិនជាសិទ្ធិរបស់កូនរបស់យើងត្រូវប៉ះពាល់ ដូច្នេះបញ្ហាយុត្តិធម៌ក៏ត្រូវប៉ះពាល់ដូចគ្នាដែរ។ ដោយហេតុនេះហើយយើងយល់ឃើញថា យើងត្រូវការចាំបាច់ដើម្បីធ្វើការឲ្យបានល្អិតល្អន់ជាមួយនឹងក្រុមការងារ ជាមួយនឹងកូនក្ដីរបស់ខ្លួន។ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពតុលាការនេះឲ្យបានល្អ ដែលយើងជាទូទៅចាត់ទុកថា នឹងអាចផ្ដល់នូវដល់កេរដំណែលដល់កម្ពុជា ឬក៏ដល់សាកលលោកទាំងមូលផងនោះបាទ។ ដូច្នេះហើយបានជាយើងស្នើសុំឲ្យពន្យារពេលសវនាការជាច្រើនដង ក៏ប៉ុន្តែយើងត្រូវទទួលការបដិសេធចំពោះសំណើនេះ។

[១០:០៨:៣៦]

ទាក់ទងនឹងពេលវេលាដែលយើងធ្វើការជួបជាមួយនឹងកូនក្ដី ជាធម្មតា ខ្ញុំកំណត់ពេលវេលាជួបជាមួយលោក ខៀវ សំផន ក្នុងមួយសប្ដាហ៍ពីរដង។ ក៏ប៉ុន្តែពេលវេលានេះ មិនមែនតែខ្ញុំទេដែលត្រូវទៅ

ជួបលោក ខៀវ សំផន ក្រុមការងាររបស់ខ្ញុំ ក៏មានមេធាវីអន្តរជាតិទៀតដែលគាត់ត្រូវតែជួបផងដែរបាទ។ ដូច្នេះបញ្ហាវាអាចធ្វើឱ្យមានការយឺតយ៉ាវទៀត ពីព្រោះពេលដែលយើងទៅជួបមិនមែនថា យើងចង់ជួបពេលណាក៏បានទេ មានម៉ោង មានពេលកំណត់ ថ្ងៃបុណ្យ ថ្ងៃទាន អត់អាចចូលបានទេបាទ។ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ក៏អត់អាចចូលបានដែរ លើកលែងមានម្តងម្កាលដែលមានលក្ខណៈពិសេស សុំបានថ្ងៃសៅរ៍។

ហើយដោយឡែកខ្ញុំបានឮលោកចៅក្រម ឡាវេន៍ គាត់បានសួរសហភាតារបស់ខ្ញុំទាក់ទងនឹងពេលវេលាក្នុងការធ្វើការងាររបស់មេធាវី។ អម្បាញ់មិញលោកស្រី អង់តា គាត់បានឆ្លើយពីទំនាក់ទំនងការងាររបស់គាត់ ថាគាត់បានធ្វើកិច្ចការអ្វីខ្លះក្រៅពីតុលាការនេះ ក៏ប៉ុន្តែលោកកុំភ្លេចថានៅក្នុងតុលាការនេះយើងមានមេធាវីបីនាក់មែន ហើយការងារគឺមិនដូចគ្នាទេ។ យើងមិនមែននៅក្នុងអគារតែមួយទេ ទោះបីជាមានការិយាល័យជាមួយគ្នាក៏ដោយ។ សហមេធាវីរបស់ខ្ញុំគាត់នៅឯប៉ារីសភាគច្រើន។ ដូច្នេះការជួបប្រាស្រ័យគ្នាក៏មានការលំបាក ដែលត្រូវយើងត្រូវធ្វើការទំនាក់ទំនងជាលក្ខណៈតាមតិចណូឡូជីដែរ។ ហើយបញ្ហាទាំងអស់នេះ វាមិនមែនថាជាចំណោទទេ ក៏ប៉ុន្តែបើយើងនិយាយអំពីពេលវេលាវាអាចៗដោយសារមេធាវីម្នាក់ៗ គាត់មានការងារផ្សេងទៀតរបស់ដែរ ខ្ញុំក៏មានការងារផ្សេងទៀតក្រៅពីនៅតុលាការនេះដែរ ពីព្រោះការងារនៅតុលាការនេះមិនមែនជាការងារ *ហ្វូលថែមស៍* ការងារពេញម៉ោងរបស់ខ្ញុំទេ។ វាជាការងារធ្វើការតាមម៉ោង ម៉ោងណាដែលខ្ញុំធ្វើការបានគេចេញលុយឱ្យ បានគេចំណាយឱ្យ។ ដូច្នេះការរៀចំពេលវេលារបស់យើង វាសុទ្ធតែជាមានការលំបាកទាំងអស់បាទ។

[១០:១០:៤៧]

ខ្ញុំសូមជម្រាបជូនឡើងវិញថា ពេលវេលាដែលយើងត្រូវការជួបលោក ខៀវ សំផន ដើម្បីទទួលការផ្តល់យោបល់របស់គាត់ ហើយនិងអាចផ្តល់យោបល់ទៅគាត់វិញពីបញ្ហានីតិវិធីអីផ្សេងៗនោះ វាត្រូវការៗពេលវេលា ក្រៅពីសវនាការក៏ត្រូវយើងត្រូវការជួបគាត់។ អ៊ីចឹងបើយើងសិនជាអស់លោកកំណត់ពេលបីថ្ងៃក្នុងមួយសប្តាហ៍ មិនមែនមានន័យថាយើងធ្វើតែបីថ្ងៃនោះទេ។ នៅពេលមានបញ្ហាទាក់ទងរឿងនីតិវិធីអ្វីមួយ យើងត្រូវទៅពិភាក្សាជាមួយគាត់។ ការពិភាក្សាមិនមែនការពិភាក្សាហើយត្រូវចប់ទេ ពីព្រោះយើងត្រូវពិភាក្សាទាំងនៅក្នុងក្រុមទៀតផង មិនមែនយើងៗទៅពិភាក្សាជាមួយលោក ខៀវ សំផន ហើយ ត្រូវចប់សម្រេចទាំងអស់ មិនមែនទេ។ អ៊ីចឹងវាមានការងារជាលក្ខណៈជាក្រុមទៀត ដែលមានការលំបាកសម្រាប់កិច្ចការរបស់យើងដែលគេហៅថា ជា*ធីមវើក* មិនមែនតែម្នាក់ឯងទេបាទ។

អ៊ីចឹងខ្ញុំសូមជម្រាបខ្លីប៉ុណ្ណោះ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមអរគុណ។ ខ្ញុំយល់ថា លោកមេធាវីបានបញ្ជាក់ថា យើងមិនអាចធ្វើការងារពីរក្នុងពេលតែមួយទេ។ ដូច្នេះបញ្ហាសំខាន់ តើអាចទៅរួចដែរទេ ដោយមានភារកិច្ច ហើយអាចធ្វើបានទៅដែរឬទេ? ប៉ុន្តែលោកបានបញ្ជាក់ថា ហើយតាមទឡ្ហីករណ៍របស់លោកនោះគឺថាបញ្ជាក់ច្បាស់ហើយ ប៉ុន្តែខ្ញុំមានសំណួរមួយទៀត ដែលទាក់ទងទៅនឹងបញ្ហាដែលលោកបានលើកជាញឹកញាប់ គឺថាភាពខុសគ្នារវាងលោកនិងក្រុមមេធាវីការពារក្តី នួន ជា។ យើងក៏បានដឹងហើយថា សាលក្រមដែលនឹងពិនិត្យឃើញថាភាគីទាំងពីរបន្ទុកដល់របស់មេធាវីការពារក្តីទាំងពីរក្រុមនោះគឺថា ក្នុងការដាក់បណ្តឹងសាទុក្ខ ហើយនិងត្រៀមរៀបចំសម្រាប់វគ្គទី២ គឺដូចគ្នា ប៉ុន្តែខ្ញុំមិនយល់ៗពីការយោងទៅរកយុត្តិសាស្ត្ររបស់មេធាវីទាំងពីរក្រុមនោះទេ ប៉ុន្តែតើលោកអាចលើកឡើងពីភាពខុសគ្នាជាសារធាតុបានទេ ពីរឿងការត្រៀមរៀបចំចូលរួមសវនាការ ហើយនិងការយុត្តិសាស្ត្រនៃការដាក់បណ្តឹងសាទុក្ខជាដើម ហើយក្រុមមេធាវី នួន ជា វិញ គាត់មិនមានបញ្ហាក្នុងការត្រៀមរៀបចំក្នុងការចូលរួមទេ ប៉ុន្តែក្រុមរបស់លោកមានបញ្ហាក្នុងការត្រៀមរៀបចំចូលសវនាការបន្ទាប់នេះ។

[១០:១៣:២៦]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសង្កេតឃើញថា យើងទៅហួសអំពីគោលការណ៍ធំពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់លោក ខៀវ សំផន ក្នុងការផ្តោតទៅលើបណ្តឹងសាទុក្ខរបស់គាត់។ ខ្ញុំមិនអាចឆ្លើយទៅកាន់លោកស្រីពាក់ព័ន្ធទៅនឹងការរៀបចំរបស់ក្រុមមេធាវីខាង នួន ជា ទេ។ ពួកគាត់មានសេរីភាពក្នុងការរៀបចំតាមចិត្តគាត់ចង់ ពួកគាត់ជាមេធាវី គាត់ចង់ធ្វើយ៉ាងម៉េចក៏បាន។ អ៊ីចឹងបើមកសួរខ្ញុំថា វាខុសគ្នាយ៉ាងម៉េច ខ្ញុំមិនអាចឆ្លើយបានទេ ព្រោះពួកគាត់ៗធ្វើម៉េចជារឿងរបស់គាត់ ខាងយើងគឺយើងធ្វើយ៉ាងម៉េច យើងផ្តោតការងាររបស់យើងទៅលើបណ្តឹងសាទុក្ខ ហើយមកសួរខ្ញុំឱ្យផ្តល់យោបល់ទៅលើបញ្ហាការការពារក្តីរបស់ខាង នួន ជា ខ្ញុំមិនដឹងឆ្លើយយ៉ាងម៉េចទេ។ ខ្ញុំឆ្លើយតែខាងក្រុមរបស់ខ្ញុំ ខ្ញុំការពារកូនក្តីខ្ញុំ ខ្ញុំអាចឆ្លើយបាន ប៉ុន្តែរឿងខាងគាត់ ជារឿងរបស់គាត់។ ខ្ញុំឆ្លើយៗតែរឿងរបស់ខ្ញុំទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**លោក គង់ សំអុន៖**

ខ្ញុំសូមបន្ថែមទាក់ទងនឹងសំណួររបស់លោកស្រីចៅក្រមអម្បាញ់មិញ។ ខ្ញុំយល់ថា មិនមានអីពិបាកយល់ទេ។ បើយើងពិនិត្យមើលលោក ខៀវ សំផន ឈ្មោះរបស់គាត់គឺខុសពី នួន ជា។ បាទ អានេះយើងឃើញខុសហើយ។ បើនិយាយពីអង្គហេតុដែលជាប់ពាក់ព័ន្ធនៅក្នុងរបបដែលៗលោក លោកស្រីកំពុងតែបើកជំនុំជម្រះនេះ ក៏ខុសគ្នា និងការងាររបស់គាត់ផ្សេងៗ ក៏ខុសគ្នា។ អាហ្នឹងលោកអាចពិនិត្យពិចារណាទៅលើភាពខុសគ្នាហ្នឹងហើយ។ ហើយសូម្បីថ្ងៃនេះ យើងអាចឃើញគាត់ –លោក ខៀវ សំផន– គាត់អញ្ជើញចូលរួមសវនាការ ប៉ុន្តែលោក នួន ជា គាត់អត់បានអញ្ជើញចូលរួមទេ។ មូលហេតុរបស់គាត់មានផ្សេងពីលោក ខៀវ សំផន។

[១០:១៥:១៧]

អ៊ីចឹងយុទ្ធសាស្ត្រ ឬក៏ការលើកឡើងរបស់ក្រុម របស់លោក នួន ជា លោកអាចសួរលោក នួន ជា ទៅថាវាយ៉ាងម៉េចបានគាត់អាចធ្វើបាន ហើយយ៉ាងម៉េចបានក្រុមមេធាវីខាងលោក ខៀវ សំផន ធ្វើមិនបាន។ វាអត់ជាប់ពាក់ព័ន្ធគ្នាទេ ព្រោះរឿងដោយឡែកពីគ្នា។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

លោកចៅក្រម ហ្សង់ម៉ាក មានអ្វីចង់សួរទៀតដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមានការសូមបំភ្លឺមួយ ដើម្បីឲ្យខ្ញុំយល់ច្បាស់អំពីអ្វីដែលលើកឡើងដោយខាងមេធាវីការពារក្តី ខៀវ សំផន។ ខាង ខៀវ សំផន បានលើកឡើងថា ខ្លួនអាចដាក់សារណាបណ្តឹងសាទុក្ខជាភាសាបារាំងនៅថ្ងៃទី២៩ ខែធ្នូ ហើយត្រូវការពេលវេលាបកប្រែឲ្យបានទៅជាភាសាផ្សេងៗទៀត។

**កញ្ញា អង់តា ហ្គីសសេ៖**

ប្រហែលជាខ្ញុំច្រឡំ គឺថ្ងៃទី២៩ ធ្នូ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលបានឯកភាពហើយ គឺថ្ងៃទី២៩ ធ្នូ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការឆ្លើយតបរបស់លោក ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ហើយជាបន្តនេះ

អង្គជំនុំជម្រះសូមសួរទៅឯកឧត្តមប្រធាន និងលោកអនុប្រធានរដ្ឋបាល តើមានបញ្ហាអ្វីដែលលោកយល់ថា គួរតែជម្រាបដល់អង្គជំនុំជម្រះដែរឬទេ ពាក់ព័ន្ធនឹងបញ្ហាការឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន អម្បាញ់មិញនេះ ចំពោះបញ្ហាធនធាននេះ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

គឺសូមជម្រាបសួរលោក លោកស្រីចៅក្រម ដោយសារខ្ញុំនឹងព្យាយាមឆ្លើយ។ ខ្ញុំមិនបានឮពីអ្វីដែលខ្ញុំអាចចាត់វិធានការបានទេ ផ្អែកតាមការតទល់នេះ។ ខ្ញុំបានឮការអះអាងថា បញ្ហាភាសា ការបកប្រែ គឺស្ថិតនៅក្នុងការគ្រប់គ្រង ហើយស្ថានភាពកំពុងតែកែលម្អ។ ដូច្នេះ ខ្ញុំមិនមានអ្វីបន្ថែមជម្រាបជូនអង្គជំនុំជម្រះលើសពីហ្នឹងទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ចុះខាងសហព្រះរាជអាជ្ញាវិញ តើមានអ្វីអាចឆ្លើយតបទៅលើបញ្ហាទាំងឡាយដែលលើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ដែរឬទេ?

[១០:១៨:០៩]

**លោក នីកូឡាស គូមជែន៖**

អត់ទេ លោកប្រធានទាក់ទងនឹងបញ្ហានេះ។ ទាក់ទងនឹងសំណួរចម្លើយ ដែលបានបញ្ជាក់មកកន្លងនេះ យើងសហព្រះរាជអាជ្ញាមិនមានអ្វីបន្ថែមទេ។

**ប្រធានអង្គជំនុំ៖**

ខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើចង់មានមតិយោបល់អ្វីទេពាក់ព័ន្ធនឹងចម្លើយតបរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចំពោះសំណួរទាំងឡាយដែលសួរឡើងដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងអម្បាញ់មិញនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោក លោកស្រីចៅក្រម ខាងមេធាវីនាំមុខមិនមានសំណួរអីបន្ថែមទេ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងក្រុមមេធាវីការពារក្តីលោក នួន ជា អំមិញ ឮដំបូងថាមានបំណងចង់

លើកឡើងនូវបញ្ហាពាក់ព័ន្ធនឹងបញ្ហានេះ ឬក៏បញ្ហាដទៃទៀត តើលោកមានបំណងធ្វើដូច្នេះដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េះ**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី សហព្រះរាជអាជ្ញាទាំងអស់។ ខ្ញុំមិនគិតថា ខ្ញុំមានអ្វីត្រូវបន្ថែមទៅអ្វីដែលបានបញ្ជាក់ព្រឹកនេះទេ។ ខ្ញុំគិតថាជំហររបស់យើង គឺថាច្បាស់ដូចពីខាងដើម យើងត្រៀមខ្លួនជាស្រេចក្នុងការចាប់ផ្ដើមចូលរួមសវនាការនៅខែមីនា ឆ្នាំក្រោយនេះ។ ប៉ុន្តែមានចំណុចមួយដែលខ្ញុំចង់ជម្រាបជូន គឺថាពិនិត្យមើលទៅលើប្រធាននៃ -- ប្រធានខាងអង្គភាពគាំពារការពារក្ដី គឺថាអនុស្សរណៈនៅថ្ងៃទី០៧ ខែតុលា ដែលយើងបានស្នើសុំបន្ថែមធនធាន -- ធនធានបន្ថែមទាក់ទងទៅនឹងម៉ោងពេលដែលយើងបន្ថែមក្នុងការងារ ធ្វើការងារសម្រាប់សហមេធាវីទាំងពីររូប ហើយនិងអ្នកជំនាញការដែលជួយដល់ពួកយើងខ្ញុំនោះ ហើយក៏បានឮពីខាងរដ្ឋបាលផងដែរ ហើយយើងច្បាស់ហើយថា យើងនឹងមានការជំនុំជម្រះវគ្គទី២ យើងបានទាក់ទងទៅប្រធានអង្គភាពគាំពារការការពារក្ដីដើម្បីសុំធនធានបន្ថែម។ តាមពិត ព្រោះយើងដឹងទាំងអស់គ្នាថា នៅពេលដែលយើងធ្វើការពីរក្នុងពេលតែមួយ យើងនឹងត្រូវការធនធានបន្ថែម ទាំងហិរញ្ញវត្ថុ ទាំងធនធានមនុស្ស។

[១០:២០:៤៥]

យើងខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ពីខាងដើមហើយ យើងអាចនឹងត្រូវបានអនុញ្ញាតឲ្យបានស្នើសុំនូវធនធានអ្វីបាននៅក្នុងខណៈពេលដែលនឹងមានដីកាកំណត់កាលបរិច្ឆេទនៅក្នុងវគ្គទី២ -- សវនាការនៅវគ្គទី២ តែប៉ុណ្ណោះ។ ដូច្នេះការចាប់ផ្ដើមជាផ្លូវការនៃវគ្គទី២ នៅក្នុងសំណុំរឿង គឺថាអាចនឹង -- ដូចជានៅក្នុងខែមេសា នៅពេលមានការបំបែកនិតីវិធី យើងបានស្នើសុំនូវប្រធានអង្គភាព ឌី.អេស.អេស ដើម្បីមានលទ្ធភាពស្នើសុំបន្ថែមធនធាន ហើយគាត់ឆ្លើយថា មិនមានថវិកាបម្រុងណានៅក្នុងថវិកាសម្រាប់នោះទេ ប៉ុន្តែនៅក្នុងការចាប់ផ្ដើមនៃវគ្គទី២នេះ គឺថា យើងយល់ថាអាចនឹងមានលទ្ធភាពស្នើសុំធនធានបន្ថែម ប៉ុន្តែយើងទទួលដំណឹងថាយើងមិនអាចធ្វើបានទេ ប៉ុន្តែនៅពេលដែលមានសាលក្រមប្រកាសហើយ ហើយនិងយើងចាប់ផ្ដើមធ្វើការងារបណ្ដឹងសាទុក្ខ ហើយយើងបានស្នើម្ដងទៀត យើងបានទទួលចម្លើយថាយើងមិនអាចទទួលបានធនធានអ្វីបន្ថែមទេ រហូតទាល់តែខណៈពេលដែលមានដីកាកំណត់កាលបរិច្ឆេទសវនាការ ដែលយើងបានដឹងជាពេលមួយ ដែលថានេះជាពេលសមស្របដែលយើងអាចដាក់សំណើសុំធនធានបន្ថែម ដែលថាអាចយើងនឹងទទួលបានធនធានបន្ថែម។

អ៊ីចឹងហើយ *មេម៉ូ* ចុងក្រោយនោះគឺថា យើងមានទំហំការងារបន្ថែមទេ គឺថារហូតតាំងពីចាប់

ផ្តើមដំបូងនោះ គឺថាទាល់តែមានកាលៈទេសៈពិសេសមួយដែលយើងអាចនឹងស្នើនោះបាន។ មានបញ្ហាមួយ គឺដីកាកំណត់កាលវិភាគសវនាការ ពេលនោះហើយដែលយើងអាចដាក់សំណើដែលខាងរដ្ឋបាលអាចនឹងពិចារណាសំណើសុំបន្ថែមធនធានរបស់យើងខ្ញុំ។ តាមពិត គឺថាយើងមិនយល់ថាមិនមានអត្ថន័យទេ ពីព្រោះថាយើងនៅតុលាការនេះ នៅក្នុងសវនាការបញ្ហាមួយ ហើយការអាន ការត្រៀមរៀបចំខ្លួនដើម្បីពិនិត្យទៅលើចម្លើយសាក្សីហ្នឹង គឺថាការងារបន្ថែមច្រើនណាស់។ ការងារនោះក៏ច្រើនដូចដែលយើងវត្តមាននៅក្នុងសាលសវនាការនោះដែរ ហើយជាពិសេសទាក់ទងទៅនឹងការកែតម្រូវនូវការដាក់សំណើ ឬក៏ផ្តល់ឱកាសឲ្យយើងខ្ញុំដាក់សំណើសុំថវិកាបន្ថែមហ្នឹងទៅតាមអនុស្សរណៈនានានោះផងដែរ។ សូមអរគុណ។

[១០:២៣:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់ស្នើមតិយោបល់លោក កូប៉េ ដើម្បីបញ្ជាក់អំពីអ្វីដែលយើងត្រូវឆ្លើយតបហ្នឹង គឺថាទំនាក់ទំនងដែលធ្វើពីមុននោះ ជាក្រៅផ្លូវការ ឬក្នុងផ្លូវការ?

សូមអនុប្រធានរដ្ឋបាល!

**លោក ឃ្នុត វ៉ូសាន់ហោក៖**

សូមអរគុណលោកចៅក្រម លោកស្រីចៅក្រម ហើយខ្ញុំនឹង -- ហើយលោកប្រធានខាងអង្គភាពគាំពារការពារក្តីនោះ ក៏គាត់បានឆ្លើយហើយដែរ ប៉ុន្តែនៅក្នុងការប្រជុំរៀបចំសវនាការនៅខែធ្នូ។ អ្វីដែលខ្ញុំយល់នោះ គឺថាពីមេធាវីការពារក្តីនោះ គឺថាមិនត្រូវកាត់បន្ថយធនធានដែលមាននៅក្នុងថវិកាទេការពិភាក្សានោះ គឺនិយាយថាមិនឲ្យកាត់បន្ថយ។ ហើយក៏មិនមានការកាត់បន្ថយធនធានដែលមានសម្រាប់មេធាវីការពារក្តីដែរ តាំងពីខែមករា រហូតមកដល់ជិតចុងឆ្នាំនេះ។ ដូច្នេះ សំណើសុំអ្វីបន្ថែមលើនោះទៀត សម្រាប់បុគ្គលមួយរូបៗ ដែលមាននៅក្នុងក្រុមមេធាវីនោះ ខ្ញុំនឹងជូនវេទិកាទៅខាងប្រធានអង្គភាពឌី.អេស.អេស។

**លោក អ៊ីសាក់ អ៊ីនឌីលី៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា ហើយមេធាវីការពារក្តី ហើយ

ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ហើយនិងលោកប្រធាន។ លោក កូប៉េ ការចងចាំពីរឿងហេតុនោះគឺត្រឹមត្រូវល្អណាស់។ ហើយកញ្ញា អង់តា ហ្គីសសេ ក៏បានបញ្ជាក់ពីបញ្ហាត្រឹមត្រូវដូច ដែលលោកអនុប្រធានរដ្ឋបាលបានបញ្ជាក់នៅក្នុងការប្រជុំរៀបចំសវនាការនៅខែធ្នូនោះ គឺថាបញ្ហានេះបានលើកឡើង។ ម៉្យាងនោះគឺ មេធាវីការពារក្ដីត្រូវការធានាសម្រាប់ថវិកាឆ្នាំ២០១៤ មិនត្រូវកាត់បន្ថយទេ បើប្រៀបធៀបទៅនឹងថវិកា២០១៣។ ហើយលោកអនុប្រធានបានបញ្ជាក់ហើយនៅក្នុងការប្រជុំនោះ។ ខ្ញុំបានពិនិត្យមើលប្រតិចារឹកហើយ។ ជាបញ្ហាថា តើមានធនធានបន្ថែមឬអត់ បើសិនជាមានការពិនិត្យផ្ទៀងផ្ទាត់ហ្នឹងគឺថាអាចនឹងយកមកពិចារណា។

[១០:២៥:៥៥]

ដូចដែលគាត់បានបញ្ជាក់គឺថា យើងមានថវិកាជាក់លាក់នៅក្នុងកម្រិត។ ហើយពេលដែលថាយើងមានថវិកាកំណត់ហ្នឹងគឺថា យើងមិនអាចបន្ថែមអីបានទេ លុះត្រាណាតែមានដីកាសម្រេចកំណត់កាលបរិច្ឆេទដែលអាចនឹងពង្រីកការងារ ទើបបានយើងចាត់វិធានការអីទៅតាមនោះបាន។ ដូច្នេះ យើងយល់ច្បាស់ហើយអំពីការងារពីរក្នុងពេលតែមួយជាដើមនោះ។ ទាក់ទងទៅនឹងបញ្ហាប្រាក់បំណាច់បន្ថែមទៅលើសមាជិកមេធាវីការពារក្ដីនោះ។ ដូច្នេះហើយខ្ញុំជាអ្នកគាំទ្រ។ ហើយទាក់ទងក្រុមមេធាវីទាំងពីរទាំងរបស់លោក នួន ជា ទាំងរបស់លោកខៀវ សំផន ដើម្បីឲ្យដាក់សំណើ ដើម្បីឲ្យយើងអាចនឹងចាត់វិធានការ។ ដូច្នេះ អនុស្សរណៈដែលលោកបានទទួល គឺថាជាផលិតផលដែលទាក់ទងនឹងការពិគ្រោះយោបល់របស់យើងខ្ញុំទៅនឹងបញ្ហាដែលលើកឡើងខាងដើមនេះឯង។ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចប្រជុំរបស់យើងនៅមានពីរបញ្ហាទៀត ដែលមិនទាន់ចប់ ហើយទាំងបញ្ហាបន្ទាប់នេះក៏ត្រូវការវត្តមានអនុប្រធានការិយាល័យរដ្ឋបាល ហើយនិងមន្ត្រីពាក់ព័ន្ធដែរ ប៉ុន្តែឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញបាទ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៧ នាទី ដល់ម៉ោង ១០:៤៦ នាទី)*

[១០:៤៥:៤៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

យើងបន្តកិច្ចពិភាក្សាជាបន្តទៀត។ កិច្ចពិភាក្សាលើបញ្ហាធនធាននិងបញ្ហាពាក់ព័ន្ធផ្សេងទៀតបានបញ្ចប់ហើយ។ ជាកិច្ចបន្ត អង្គជំនុំជម្រះនឹងពិភាក្សាទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តីបម្រុង និងពន្លឿនកិច្ចដំណើរការនីតិវិធីតុលាការ។ ហើយអង្គជំនុំជម្រះអម្បាញ់មិញនេះ បានអញ្ជើញឯកឧត្តមប្រធាន លោកអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងប្រធានអង្គភាពគាំពារការពារក្តី និងអង្គភាពបកប្រែភាសា បន្តមានវត្តមាននៅក្នុងកិច្ចពិភាក្សាលើបញ្ហានេះ។

ហើយជាបន្តទៅទៀត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងបង្ហាញអំពីសំណើសុំចាត់តាំងក្រុមមេធាវីការពារក្តីបម្រុង និងពន្លឿនកិច្ចដំណើរការនីតិវិធីតុលាការនៅក្នុងសំណុំរឿង ០០២/០២។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ព័ត៌មានដែលយើងទទួលបាននៅព្រឹកនេះ គឺជាព័ត៌មានដ៏សំខាន់មួយ។ ហើយព័ត៌មាននេះជួយដល់យើងក្នុងការនិយាយទាក់ទងទៅសំណើរបស់យើង។ ខ្ញុំនិយាយអំពីសំណើមកពីខាង ខៀវ សំផន និងខាង នួន ជា។ អ្វីដែលលោក លោកស្រីចៅក្រមបានលើកឡើង គឺថាតុលាការបន្ទាប់ពីបានស្តាប់ភាគី ហើយបានពិចារណាទៅលើសារណាជាច្រើន ពេលនោះតុលាការនឹងធ្វើការសម្រេចទៅលើការដំណើរការនីតិវិធីក្នុងពេលដែលបណ្តឹងសាទុក្ខកំពុងតែបន្ត។ ដូចដែលចៅក្រម ឡាវ៉ែន៍ បានលើកឡើងនៅព្រឹកនេះ គឺថាវាចំណាយពេលប្រហែលជា ១៨ថ្ងៃដើម្បីធ្វើការសម្រេច។ ដូច្នេះ គឺរហូតទៅដល់ថ្ងៃ ២៤ គឺបានន័យថា បន្ទាប់ពីការរៀបចំសវនាការលើភស្តុតាងប្រហែលជា ២៤ថ្ងៃទៅ។

ខាងមេធាវីការពារក្តីបានសម្រេចចិត្តថា បានសម្រេចថា ពួកគេមិនយល់ស្របជាមួយនឹងការសម្រេចរបស់តុលាការ ហើយពួកគេនឹងមិនគោរពទៅតាមតុលាការទេ ដោយសារតែគេស្តាប់ការបង្គាប់បញ្ជារបស់កូនក្តីរបស់ពួកគេ។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមអំពីជំហររបស់ នួន ជា ដំបូងសិន។

[១០:៤៨:១៩]

គោលជំហររបស់ នួន ជា គឺថា ពួកគេនឹងមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីរហូតទៅ

ដល់ពេលបណ្តឹងជំទាស់បានបញ្ចប់ គឺនៅពេលដែលមានការសម្រេចលើបណ្តឹងជំទាស់។ ហើយខ្ញុំគិតថា វាជាការសំខាន់ដែលលោក នួន ជា មិនបង្ហាញ មិនបានបង្ហាញវត្តមាននៅទីនេះ ដោយសារតែជាការបង្ហាញថា ប្រសិនបើបណ្តឹងជំទាស់ហ្នឹងត្រូវបានបដិសេធ នៅពេលនោះ គឺថាការមិនចូលរបស់គាត់ គឺនឹងបានបញ្ចប់ ព្រោះថារយៈពេលនៃការពហិការគឺនឹងចប់នៅពេលដែលបណ្តឹងជំទាស់ចេញ។ ប៉ុន្តែចំណុចនេះ គឺបានបញ្ជាក់ថា នួន ជា បានសម្រេច ទោះបីថាគាត់បានទទួលការជម្រាបពីមេធាវីការពារក្តីរបស់គាត់ អំពីផលវិបាកនៃការមិនគោរពទៅតាមវិធាន គឺវិធាន៣៤ ដែលបាននិយាយថា ចៅក្រមអាចចូលរួមសវនាការបាន ទោះបីជាមានបណ្តឹងជំទាស់កំពុងតែធ្វើឡើងក៏ដោយ។ ហើយខ្ញុំគិតថា នៅក្នុងតុលាការ -- នៅក្នុងបណ្តឹងជំទាស់ជាច្រើនដែលបានធ្វើឡើងកន្លងមកតាំងពីពេលចាប់ផ្តើមសំណុំរឿងនៅឆ្នាំ២០១១ ពេលនោះមេធាវី នួន ជា បាននិយាយថា ខ្លួនមានបណ្តឹងជំទាស់ប្រឆាំងចៅក្រមមួយរូប។ ហើយបន្ទាប់មកទៀត មេធាវី នួន ជា បានធ្វើសេចក្តីថ្លែង។ នៅពេលនោះគឺមិនមានការធ្វើពហិការ ដោយសារតែមានការបណ្តឹងជំទាស់នោះឡើយ។

[១០:៥០:០៤]

សូម្បីតែនៅក្នុងដំណាក់កាលមុនបុរេជំនុំជម្រះ គឺថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ គឺមេធាវីការពារក្តី នួន ជា បានដាក់ឯកសារ C1124 ដែលពាក់ព័ន្ធទៅនឹងបណ្តឹងជំទាស់ទៅលើចៅក្រមអង្គបុរេ។ នៅក្នុងកថាខណ្ឌ២ នៃបណ្តឹងជំទាស់, នួន ជា បាននិយាយថា -- ដូចដែលខាងព្រះរាជអាជ្ញាបានដឹងគឺថា -- ហើយអនុលោមទៅតាមវិធាន៣៤(៥) ចៅក្រមអាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដែលរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ ឬក៏ចៅក្រមអាចសម្រេចចុះចេញពីតំណែងដោយស្ម័គ្រចិត្ត។ ដូច្នេះមេធាវីការពារក្តីបានទទួលស្គាល់ថា ច្បាប់របស់ អ.វ.ត.ក បានផ្តល់នូវជម្រើសដល់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឱ្យចៅក្រមដែលរងបណ្តឹងជំទាស់បន្តចូលរួមក្នុងសវនាការ ទោះបីជាគាត់មានបណ្តឹងជំទាស់ក៏ដោយ លើកលែងតែមានការបង្កព្យសនកម្មទៅលើការចូលរួមរបស់ នួន ជា។ ដូច្នេះហើយជាលទ្ធផលគឺថា សវនាការអាចបន្តទៅមុខរង់ចាំលទ្ធផលនៃបណ្តឹងជំទាស់។ ដូច្នេះ កាលដែល នួន ជា បង្គាប់មេធាវីការពារក្តីមិនឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី វាគ្រាន់តែជាការបដិសេធ ឬក៏ជាការមិនទទួលគោរពតាមដីកាបង្គាប់របស់អង្គជំនុំជម្រះតែប៉ុណ្ណោះ។ ឧទាហរណ៍ថា បើសិនបើនៅពេលខាងមុខ នួន ជា ឬក៏ ខៀវ សំផន គាត់មិនពេញចិត្ត ឬក៏គាត់មិនយល់ស្របទៅតាមសេចក្តីសម្រេច គាត់នឹងប្រើប្រាស់វិធីសាស្ត្រនេះ។ ដូច្នេះខ្ញុំគិតថា អ្វី -- គឺថាគាត់អាចនឹងធ្វើការលើកលែងមិនទទួលយក

មេធាវីការពារក្តី។

យើងក៏បានស្តាប់ឮនៅព្រឹកនេះថា វាមិនមានបញ្ហាអំពីធនធាន គឺការតវ៉ាអំពីធនធានទាំងខាង ក្រុម ខៀវ សំផន ហើយនិង នួន ជា។ ហើយខាងខៀវ សំផន បានបញ្ជាក់ច្បាស់ថា ខ្លួនមិនមែនធ្វើ ពហិការដោយសារតែបញ្ហាធនធាននោះឡើយ។ ដូច្នេះគឺថាយើងឃើញថា តុលាការបានគោរពទៅតាម គោលការណ៍ផ្តល់ធនធានគ្រប់គ្រាន់ទៅដល់មេធាវីទាំងពីរ ប៉ុន្តែមេធាវីទាំងពីរមិនប្រើប្រាស់ធនធាន។ ឥឡូវនេះយើងឃើញថាខាងរដ្ឋបាលក៏នៅទីនេះដែរ។ ហើយអ្វីដែលសំខាន់បំផុតគឺថា វាជាការពន្យារ យុត្តិធម៌ ព្រោះថាដំណើរការត្រូវបានពន្យារពេលអស់រយៈពេលយូរណាស់ទៅហើយ។

[១០:៥៣:០៨]

ដូច្នេះហើយគឺថា វាជាការពន្យារទាំងដំណើរការរបស់តុលាការ ក៏ដូចជាការពន្យារទៅដល់ការ ចំណាយឲ្យបានកាន់តែច្រើន។ ដូច្នេះប្រសិនបើយើងពន្យារបន្ថែមទៀតមួយខែ ថាតើយើងត្រូវចំណាយ ពេលប្រហែលប៉ុន្មានសម្រាប់រយៈពេលមួយខែដែលយើងត្រូវពន្យារសវនាការនេះ។ គឺខ្ញុំចង់និយាយអំពី ចំណាយសរុប។ ខាង ខៀវ សំផន បានប្រើប្រាស់វិធីសាស្ត្រ ក៏ដូចជាលេសផ្សេងពីគ្នា។ ពួកគាត់បាន សម្រេចចិត្តថា យើងអាចធ្វើការទៅលើសំណុំរឿងពីរក្នុងពេលជាមួយគ្នា។ ខ្ញុំគិតថានេះជារឿងគួរឲ្យ ចាប់អារម្មណ៍ព្រោះថាយើងមាន -- មេធាវីបាននិយាយថាយើងមានរឿងក្តីច្រើននៅខាងក្រៅ ប៉ុន្តែយើង ដឹងហើយថាក្នុងនាមជាមេធាវី វាមិនអាចនោះទេ។ កម្រណាស់ដែលថាមេធាវីគាត់ធ្វើការនៅលើរឿងក្តី តែមួយ។ ប៉ុន្តែចំពោះខាងព្រះរាជអាជ្ញា គឺយើងធ្វើការទាំងទៅលើសំណុំរឿង០០២/០២ យើងធ្វើការ ទាំងលើបណ្តឹងសាទុក ក៏ដូចជាយើងធ្វើការទៅលើសំណុំរឿង០៣, ០៤ ផងដែរ។ ហើយយើងមិនមែន ធ្វើការឆ្លើយតបតែបណ្តឹងសាទុក្ខតែមួយទេ គឺយើងធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខចំនួនពីរ។ ដូច្នេះ វាធ្វើឲ្យយើងត្រូវការប្រើប្រាស់ពេលវេលា ធនធានយ៉ាងច្រើន។ ដូច្នេះហើយគឺថា ខៀវ សំផន គាត់ធ្វើការសម្រេចមួយដែលថាមេធាវីការពារខៀវ សំផន គាត់លើកឡើងថាកូនក្តីខ្ញុំប្រាប់ថាកុំឲ្យធ្វើ។ ដូច្នេះ អានេះស្មើនឹងការដែលគាត់លះបង់សិទ្ធិមិនមានមេធាវី។ តុលាការផ្តល់មេធាវីឲ្យគាត់ ហើយគាត់ មានសិទ្ធិប្រើប្រាស់។ ដូច្នេះប្រសិនបើគាត់បដិសេធ គឺបានន័យថាតុលាការមានសិទ្ធិគ្រប់គ្រាន់ក្នុងការ បន្តកិច្ចដំណើការនីតិវិធីដោយមិនចាំបាច់មានមេធាវី ព្រោះថាជនជាប់ចោទគាត់បានប្រាប់មេធាវីគាត់ មិនឲ្យចូលរួម។ ប៉ុន្តែខ្ញុំគិតថាមានអ្វីដែលមួយដែលប្រសើរទៀតគឺ យើងប្រើប្រាស់មេធាវីបម្រុង គឺថា ជាមិត្តរបស់តុលាការ គឺជាមេធាវីដែលជាមិត្តរបស់តុលាការ ដើម្បីជួយការពារក្តី គឺដើម្បីការពារសិទ្ធិ

របស់ជនជាប់ចោទ។ ហើយខ្ញុំគិតថាមាននៅក្នុងករណីយុត្តិសាស្ត្រជាច្រើន ឧទាហរណ៍ដូចជារឿងក្តី ដែល មីឡូសីវិច ដែលតុលាការបានជ្រើសតាំងមេធាវីបម្រុង ឬក៏មេធាវីដែលជាមិត្តរបស់តុលាការ។ ប៉ុន្តចំពោះករណី មីឡូសីវិច គាត់អាចធ្វើជាមេធាវីដោយខ្លួនគាត់ផ្ទាល់។ ប៉ុន្តែចំពោះករណី ខៀវ សំផន និង នួន ជា គឺគាត់មិនមានមេធាវីទេ។ ដូច្នេះយើងអាចមានមេធាវីបម្រុងដើម្បីជាប្រយោជន៍របស់តុលាការ។ ប៉ុន្តែទោះបីថាមេធាវីនេះគាត់មិនអាចបំពេញការងារបានល្អឥតខ្ចោះក៏ដោយ ប៉ុន្តែសិទ្ធិមានមេធាវីរបស់ ខៀវ សំផន និង នួន ជា ត្រូវបានការពារ។

[១០:៥៦:០៧]

ដូច្នេះ ខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រម ធ្វើការប្រៀបធៀបចំណាយនៃការរើសមេធាវីបម្រុងធៀបទៅនឹងចំណាយនៃការពន្យារទៅនឹងដំណើរការនីតិវិធី។ ហើយខ្ញុំគិតថាការធ្វើពហិការមិនគួរទទួលបានការលើកទឹកចិត្តនោះឡើយ ប៉ុន្តែខ្ញុំមិនច្បាស់នៅក្នុងចិត្តថាតើមេធាវី -- ដូចដែលពួកគេបាននិយាយថា យើងមិនអាចរៀបចំទឡ្ហីករណ៍ទាំងអស់សម្រាប់បណ្តឹងសាទុក្ខក្នុងពេលជាមួយគ្នា ដែលយើងធ្វើការប្តឹងជិតចិត្ត -- ប្តឹងសាទុក្ខផង យើងធ្វើការជំនុំជម្រះផងនោះទេ។ យើងជឿជាក់ថាស្ថានភាពដែលអាក្រក់បែបនេះ គឺអាស្រ័យទៅលើជម្រើសរបស់ខៀវ សំផន និង នួន ជា តែប៉ុណ្ណោះ។ គឺថាបន្ទាប់ពីពួកគាត់ប្រឹក្សាជាមួយមេធាវី គឺគាត់សម្រេចថាមិនគោរព ហើយនិងបដិសេធទៅលើសេចក្តីសម្រេចរបស់តុលាការ។ ដូច្នេះខ្ញុំសូមស្នើថាឲ្យតុលាការបន្តកិច្ចដំណើរការទៅមុខ ហើយការជ្រើសតាំងមេធាវីបម្រុង ឬក៏ជាមេធាវីមិត្តរបស់តុលាការគឺជាការល្អ ដើម្បីដំណើរការនីតិវិធី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញាអន្តរជាតិ។ ជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ពាក់ព័ន្ធនឹងបញ្ហានេះ តើលោក លោកស្រីមានមតិយោបល់យ៉ាងម៉េចដែរ អំពីសំណើសុំចាត់តាំងក្រុមមេធាវីការពារបម្រុង និងពន្លឿនកិច្ចដំណើរការនីតិវិធីនៃតុលាការនេះ?

[១០:៥៧:៣៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីៗទេ ដើម្បីគាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញា ដែលត្រូវតែងតាំងមេធាវីមិត្តរបស់តុលាការដើម្បីជួយតំណាងឲ្យ លោក នួន ជា ហើយ

លោក ខៀវ សំផន។

កាលពីម្សិលមិញយើងបានដាក់សារណាមួយគាំទ្រសំណើរបស់គាត់។ ខ្ញុំចង់និយាយតែពីរម៉ាត់ទេ។ ជាបឋម ខ្ញុំបាននិយាយរួចហើយ ហើយឥឡូវថ្ងៃនេះខ្ញុំនិយាយម្តងទៀត ពីព្រោះថាសហភាតារបស់ខ្ញុំនេះដែលមានវត្តមាននៅទីនេះ។ យើងយល់ពីច្បាប់ជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការចូលរួមយ៉ាងសកម្មក្នុងការការពារខ្លួន។ យើងយល់ព្រោះថាយើងជាមេធាវីដែរ ហើយយើងជាអ្នកជំនួយការយុត្តិធម៌ យើងយល់ព្រោះថាវាជាផលប្រយោជន៍ដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលជនជាប់ចោទចូលរួមយ៉ាងសកម្មនៅក្នុងការការពារខ្លួនរបស់ខ្លួន។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ សារណារបស់សហព្រះរាជអាជ្ញា សំណើរបស់សហព្រះរាជអាជ្ញាអាចធ្វើឱ្យយើងគោរពសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលការពារខ្លួន ហើយនិងរបស់បុគ្គលជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពីព្រោះថានៅពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាដែលយើងគាំទ្រនោះ គឺថាយើងសូមជម្រាបជូនថា យើងមិនតំណាងឱ្យផលប្រយោជន៍សង្គម ឬក៏សាធារណៈទេ យើងតំណាងឱ្យផលប្រយោជន៍រួមមួយ ជាឯកជនគឺផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីជាង ៣.០០០នាក់ ជិត ៤.០០០នាក់ នៃរបបកម្ពុជាប្រជាធិប-តេយ្យ ដែល អង្គពេជ ហើយខ្ញុំទាំងពីរនាក់ហ្នឹង យើងខំធ្វើយ៉ាងណាដើម្បីការពារផលប្រយោជន៍របស់ពួកគាត់។ យើងការពារផលប្រយោជន៍ផ្ទាល់របស់គាត់ យើងធ្វើយ៉ាងណាឱ្យការជម្រះសេចក្តីបន្តទៅមុខឱ្យលឿនបំផុតដោយមូលហេតុដូចខាងក្រោម៖

[១០:៥៩:៥៨]

អ្នកដែលយើងតំណាងឱ្យទាំងអស់សុទ្ធតែចាស់ៗអស់ហើយ។ គាត់មានបញ្ហាសុខភាពហើយនិងការចងចាំជាច្រើន។ ពួកគាត់ទាំងអស់ហ្នឹងកាន់តែខកចិត្តហើយ ព្រោះថាការពិភាក្សាគ្នាមិនចេះចប់មិនចេះហើយ។

ឧទាហរណ៍ ដូចជាប៉ុន្មានថ្ងៃចុងក្រោយនេះគឺ ដើមបណ្តឹងរដ្ឋប្បវេណីគាត់និយាយថាគាត់ខកចិត្ត យើងក៏ខកចិត្តដែរ ព្រោះយើងតំណាងផលប្រយោជន៍ឱ្យគាត់ យើងត្រូវ -- ហើយអ៊ីចឹងយើងត្រូវធ្វើយ៉ាងណាគាំទ្រផលប្រយោជន៍របស់គាត់ដែលស្ថិតនៅក្រោមអាណត្តិរបស់ អ.វ.ត.ក យើងនេះត្រូវតំណាង ត្រូវការពារគោលការណ៍មូលដ្ឋាន គឺធ្វើយ៉ាងណាដើម្បីឱ្យមានតុល្យភាពរវាងសិទ្ធិជាមូលដ្ឋានរបស់ខាងការពារក្តី ហើយនិងសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះដែលតម្រូវឱ្យការជម្រះសេចក្តីនេះ ទៅ

មុខ។ ដូច្នេះ បន្ទាប់ពីការពិភាក្សាហើយនេះ យើងសូមគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាពីព្រោះថា យើងយល់ឃើញថា នេះគឺជាការសម្របសម្រួលរវាងផលប្រយោជន៍ គឺថាក្នុងការគោរពផលប្រយោជន៍ភាគីទាំងអស់គ្នានៅពេលដែលអស់លោក លោកស្រីចៅក្រមចេញសេចក្ដីសម្រេច។ ហើយអស់លោក លោកស្រីចៅក្រមដែលមានច្បាប់ជាមូលដ្ឋាន មានវិធាន អស់លោក លោកស្រីចៅក្រមអាចបង្ខំគាត់ឲ្យមកសវនាការបាន ហើយក៏ត្រូវគិតពីផលប្រយោជន៍ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ ហើយកាលណាជនជាប់ចោទមានមេធាវីការពារ គឺសិទ្ធិរបស់គាត់ត្រូវបានការពារហើយ។ ដូច្នេះសូមអស់លោក លោកស្រីចៅក្រមពិចារណាអំពីតុល្យភាពនេះឲ្យបានល្អិតល្អន់។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ អរគុណលោកស្រីមេធាវី។

ចុះខាងក្រុមមេធាវីការពារក្ដី នួន ជា មានមតិយោបល់យ៉ាងម៉េចដែរលើបញ្ហានេះ?

[១១:០២:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងមានបញ្ហាបឋមចំនួនពីរដែលខ្ញុំចង់លើកឡើងនៅទីនេះ។ ហើយប្រហែលជាអាចឆ្លើយតបទៅនឹងសារណាដែលលើកឡើងដោយខាងព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី។ បញ្ហាទី១ គឺពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសគឺចំពោះមេធាវី ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅពីក្រោយ – អ៊ូ! អត់ឃើញមានអីអ៊ីចឹង ខ្ញុំច្រឡំ។

ថ្ងៃនេះខ្ញុំបានអានអត្ថបទមួយនៅក្នុងកាសែត ខេមបូឌា ដេលី ដែលមានចំណងជើងថា “អ.វ.ត.ក ធ្វើការព្រមានដល់មេធាវីការពារក្ដីទាក់ទងទៅនឹងការប្រព្រឹត្តមិនសមរម្យ”។ ហើយនៅក្នុងរបាយការណ៍របស់ ខេមបូឌា ដេលីនេះ ខ្ញុំសូមអានដូចតទៅនេះ៖ “ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន ស៊ូ ដែលជាសមាជិកនៃសមាគមជនរងគ្រោះបានទាមទារនូវ អ.វ.ត.ក ថា គាត់គាំទ្រការធ្វើពហិការរបស់មេធាវីការពារក្ដី។ យើងមិនខឹងហើយក៏យើងមិនប្រតិកម្មអ្វីអាក្រក់ចំពោះមេធាវីការពារក្ដីដែរ ហើយយើងគិតថាពួកគាត់ធ្វើត្រូវ”។ ឥឡូវនេះ យើងចង់សួរថា តើអ្នកណាជាលោក ប៉ែន សួន នោះ? របាយការណ៍មួយទៀតនៅក្នុងកាសែត ខេមបូឌា ដេលី គឺថ្ងៃ ២៥ ខែតុលា, លោក ប៉ែន សួន បាននិយាយទាក់ទងទៅនឹងសកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលថ្លែងបើករបស់សវនាការដំបូង។ ហើយការតវ៉ារបស់គាត់ត្រូវបានគាំទ្រដោយមេធាវី ឡោ ជុនធី។ ហើយកាសែត ខេមបូឌា ដេលី បានដកស្រង់នូវការ --

ប្រហែលដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជា ១.១០០នាក់។ ហើយខ្ញុំចង់សួរថា តើសហមេធាវីនាំមុខហ្នឹងតំណាងឲ្យអ្នកណា? តំណាងឲ្យតែប៉ុន្មាននាក់ហ្នឹង? ឬមួយក៏តំណាងឲ្យទាំងអស់គ្នានេះ? នេះគឺជាបញ្ហាគឺជាមតិទី១ ដែលខ្ញុំចង់លើកឡើង។ ចំពោះមតិទី២ របស់ខ្ញុំគឺចង់និយាយអំពីស្ថានភាពនៃសវនាការនេះ ហើយសួរថា ហេតុអីបានជាចាំបាច់នៅពេលដែលយើងយកច្បាប់កម្ពុជាមកប្រើប្រាស់នៅពេលដែលយើងនិយាយទៅដល់ខាងព្រះរាជអាជ្ញា។

[១១:០៤:៥២]

ខ្ញុំចង់ជម្រាបដល់សហព្រះរាជអាជ្ញាអន្តរជាតិអំពីមាត្រា១២នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា១២បានចែងថា "នីតិវិធីត្រូវស្របទៅតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា"។ មាត្រា៣១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់ដែលអនុម័តដោយសភា ហើយចុះឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រនោះ គឺថាជាច្បាប់ដែលផ្ទុយទៅនឹងវិធាននីតិ -- ផ្ទុយទៅនឹងវិធានផ្ទៃក្នុង គឺថាសវនាការត្រូវធ្វើជាសាធារណៈ ប៉ុន្តែតុលាការអាចបង្គាប់ឲ្យធ្វើជាអសាធារណៈជាផ្នែកឬក៏ទាំងមូលនៅពេលដែលគិតថាសវនាការអាចបង្កឲ្យមានផលប៉ះពាល់ទៅដល់សាធារណៈ ឬក៏ជាសីលធម៌។ ហើយសាលក្រមអាចដកស្រង់ទៅលើផ្នែកពិសេសណាមួយបាន។

បទប្បញ្ញត្តិដដែល ដែលយើងអាចរកឃើញនៅក្នុងវិធានផ្ទៃក្នុង គឺថាសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើជាសាធារណៈ។ នៅពេលដែលខ្ញុំពិនិត្យមើលទៅលើវិធានផ្ទៃក្នុងដែលទាក់ទងច្បាស់ទៅនឹងការរៀបចំសវនាការ គឺវិធាន៣៩ វិធាន៧៩ កថាខណ្ឌ៧ ដែលថាអង្គជំនុំជម្រះអាចបញ្ជាក់ជាមួយភាគីនានា អំពីការចូលរួមបានដោយធ្វើការរៀបចំកិច្ចប្រជុំរៀបចំសវនាការធ្វើជាអសាធារណៈ ឬក៏សារធារណៈ។ ហើយគោលដៅនៃកិច្ចប្រជុំរៀបចំសវនាការ គឺដើម្បីឲ្យភាគីអាចចែករំលែកព័ត៌មានក៏ដូចជាសម្របសម្រួលទៅលើកាលបរិច្ឆេទនៃការចូលរួមក៏ដូចជាទស្សនៈរបស់ភាគីទៅលើសវនាការហើយភាគីអាចបញ្ជាក់អំពីស្ថានភាពនានា រួមទាំងស្ថានភាពផ្លូវកាយនិងផ្លូវចិត្តរបស់គាត់ផង។

នៅពេលដែលយើងពិនិត្យទៅលើបញ្ហាទាំងអស់នេះ គឺបញ្ហាខ្ញុំនៅតែជាបញ្ហាបឋម ហើយវាជាបញ្ហាមូលដ្ឋានមួយ ថាតើយើងគួរតែមានមេធាវីបម្រុងសម្រាប់តុលាការនេះឬក៏អត់? តើយើងគួរតែយើងធ្វើសវនាការអសាធារណៈ ឬក៏ហេតុអ្វីបានជាខ្ញុំពាក់ឬក៏មិនពាក់អាវមេធាវីរបស់ខ្ញុំ។ នេះគឺជាបញ្ហាដែលយើងត្រូវឆ្លើយ មុនពេលដែលយើងធ្វើការឆ្លើយទៅលើអង្គសេចក្តីនៃសារណារបស់សហព្រះរាជអាជ្ញា។ សូមអរគុណ។

[១១:០៨:០៧]

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូម១--

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគ្រាន់តែសុំគាំទ្រសហភាតារបស់ខ្ញុំ លោក កូប៉េ។ យើងម្សិលមិញក៏បានលើកឡើងដែរតាមរយៈផ្ញើអ៊ីម៉ែលមួយទៅអង្គជំនុំជម្រះថា សារៈសំខាន់នៃប្រធានបទពិភាក្សានៅថ្ងៃនេះ។ អ៊ីចឹងខ្ញុំគិតថា ដោយសារសំខាន់យ៉ាងនេះ យើងមិនត្រូវធ្វើកិច្ចប្រជុំសម្ងាត់នេះទេ ហើយមិនត្រូវលំបាកបិទបាំងយ៉ាងដូច្នេះទេ ហើយទៅមិនភ័យៗរឿងបង្ហាញអំពីអត្តសញ្ញាណអីទេ ត្រូវបើកសវនាការជាសាធារណៈ។

**ប្រធានអង្គជំនុំ៖**

មានមតិយោបល់អ្វីទេពាក់ព័ន្ធនឹងបញ្ហាប្រធានបទអំមិញទេ?

សូមអញ្ជើញបាទ!

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ ខ្ញុំមិនបានលើក មិនលើកអំពីរឿងសំណើធ្វើសវនាការជាអសាធារណៈអីទេ ខ្ញុំសូមឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។

អម្បាញ់មិញនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកអំពីសំណើរបស់លោកដែលបានស្នើសុំឱ្យមាន លោកហៅថាមេធាវីបម្រុង ឬក៏ជាមិត្តរបស់តុលាការដែលខ្ញុំខ្លួនឯងក៏មិនយល់ថា ជាតួនាទីអ្វីនៅក្នុងនីតិវិធីរបស់កម្ពុជាយើងនេះដែរ។ នៅក្នុងច្បាប់កម្ពុជាយើងអត់មានទេ ហើយខ្ញុំក៏អត់យល់ដែរ។ ក៏ប៉ុន្តែខ្ញុំអាចជម្រាបជូនទៅលើអ្វីដែលជាច្បាប់របស់កម្ពុជា ដែលជាក្រមសីលធម៌របស់មេធាវី ទាក់ទងទៅនឹងការទទួលយកមេធាវីរបស់ជនជាប់ចោទនៅក្នុងនីតិវិធីព្រហ្មទណ្ឌ។ ជារួម ជាគោលការណ៍សកលយើងដឹងហើយថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានទទួលស្គាល់ទាំងនៅក្នុងកម្ពុជា ហើយទាំងនៅក្នុងតុលាការនេះ ជាពិសេសខ្ញុំសូមលោកចៅក្រមមេត្តាពិនិត្យទៅលើមាត្រា១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដែលបានចែងអំពីសិទ្ធិរបស់ជនជាប់ចោទយ៉ាងលម្អិតនៅក្នុងចំណុចនេះផងដែរ។ ហើយនោះ ខ្ញុំសូមផ្តោតទៅលើបញ្ហាពីរ ព្រោះសិទ្ធិវាមានច្រើនតែខ្ញុំសូមលើកពីរទេ។

[១១:១០:៤៦]

ទី១ ទាក់ទងនឹងសិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង។ បាទ ចំណុចនេះសំខាន់ណាស់ ដែលជាប់ពាក់ព័ន្ធទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ ហើយបច្ចុប្បន្ននេះ យើងឃើញថា ទាំងលោក ខៀវ សំផន ទាំងលោក នួន ជា គាត់មេធាវីរបស់គាត់ហើយ ហើយខ្ញុំកំពុងតែការពារនៅក្នុងរឿងក្តីរបស់គាត់នេះ ហើយខ្ញុំសូមប្រកាសជូនអង្គជំនុំជម្រះ សាធារណៈ និងភាគីទាំងអស់ថា ខ្ញុំក្នុងនាមជាមេធាវីរបស់លោក ខៀវ សំផន ខ្ញុំអត់បានបោះបង់ក្តីការពារលោក ខៀវ សំផន នេះទេ។ ខ្ញុំនៅតែការពារលោក ខៀវ សំផន ដដែល។ ដូច្នេះខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន ក្នុងពេលបច្ចុប្បន្ននេះ ហើយនិងមានសហការី សហភាតាដែលជាសហមេធាវីបរទេសទៀត។ ទី២ ទាក់ទងទៅនឹងសិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន។ នេះជាសិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៣ នៃកិច្ចព្រមព្រៀងនេះផងដែរ។

ដូច្នេះបញ្ហាទាំងពីរនេះ ការលើកឡើងរបស់សហព្រះរាជអាជ្ញា វាជាប់ទាក់ទងគ្នាទៅលើសិទ្ធិពីរចំណុចនេះ។ បើសិនជាលោកបង្ខំឲ្យលោក ខៀវ សំផន ទទួលយកមេធាវីណាមួយដែលលោកមិនព្រមទទួលយក អានេះវាប្រឆាំងទៅនឹងគោលការណ៍នៃសិទ្ធិមនុស្សរបស់លោក ខៀវ សំផន ក្នុងការទទួលយកមេធាវីដែលលោក ខៀវ សំផន មិនពេញចិត្ត មិនទទួលយក។ នេះជាការបង្ខំមួយដែលជាការរំលោភនូវសិទ្ធិមនុស្សទៀត។

អ៊ីចឹងទី២ ទាក់ទងទៅនឹងក្រមសីលធម៌របស់មេធាវី សម្រាប់មេធាវីកម្ពុជា ខ្ញុំសូមឲ្យលោកពិនិត្យមាត្រា៤៥ ក្រមសីលធម៌វិជ្ជាជីវៈមេធាវី គឺថាទាក់ទងនឹងការប្តូរមេធាវី និងការបន្ថែមមេធាវី។ បើខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន ខ្ញុំអត់បានបោះបង់គាត់ទេ។ អ៊ីចឹងសួរថា តើមានមេធាវីថ្មីណាដែលអាចមកទទួលយកមេធាវីបន្ទាប់ នៅពេលដែលខ្ញុំកំពុងតែកាន់ក្តីនេះបានទេ? បើធ្វើបែបនេះ វាខុសនឹងក្រមសីលធម៌ ខុសនឹងវិជ្ជាជីវៈមេធាវីហើយ វាហាក់ដូចជាមេធាវីរូបនោះកំពុងតែទៅដណ្តើមកូនក្តីពីមេធាវីដែលគេកំពុងតែកាន់ក្តីអ៊ីចឹង។ ដូច្នេះបញ្ហានេះ ខ្ញុំជឿថាមិនអាចអនុវត្តបានទេ ប៉ុន្តែដូចខ្ញុំជម្រាបជូនខាងដើមអ៊ីចឹងថា ខ្ញុំមិនយល់ពីពាក្យថាមេធាវីបម្រុង ឬក៏មេធាវីជាមិត្តរបស់តុលាការនោះមានន័យយ៉ាងដូចម្តេចដែរ។ ក៏ប៉ុន្តែបើក្នុងករណីនៃការបន្ថែមទៅលើមេធាវីដោយការជំទាស់ មិនមានយល់ព្រមពីខ្ញុំជាមេធាវីដែលមានស្រាប់ ពីលោក ខៀវ សំផន ដែលជាជនជាប់ចោទនៅតុលាការនេះ ខ្ញុំយល់ថានេះជាការរំលោភសិទ្ធិមនុស្សរបស់លោក ខៀវ សំផន ហើយ។

[១១:១៣:៤១]

អ៊ីចឹង សរុបសេចក្ដីមក ខ្ញុំសូមបញ្ជាក់ទៅលើបញ្ហាពេលវេលា។ យើងបានធ្វើការទាមទារជាច្រើនលើកច្រើនសា ដូចបានពិភាក្សានៅប្រធានបទមុន ហើយដែលតំណាងអយ្យការបានលើកថា បើសិនជាការសម្រេចណាមួយរបស់អង្គជំនុំជម្រះ ដែលលោក ខៀវ សំផន ឬជនជាប់ចោទនៅទីនេះមិនពេញចិត្ត គាត់អាចរកលេសថា គាត់មិនឱ្យមេធាវីរបស់គាត់ចូល អ៊ីចឹងវាធ្វើឱ្យប៉ះពាល់ដល់ពេលវេលានៃការដំណើរការនីតិវិធីរបស់តុលាការនេះ។ ខ្ញុំយល់ថា វាមិនមានករណីបែបនោះអ៊ីចឹងទេ។ វាលើកលែងតែការប៉ះពាល់ដល់ការអនុវត្តសិទ្ធិរបស់លោក ខៀវ សំផន ដែលជាជនជាប់ចោទនៅទីនេះ បានលោកត្រូវធ្វើការទាមទារ។ មិនមានន័យថា ឱ្យតែសេចក្ដីសម្រេចណាដែលតុលាការសម្រេចទៅ លោក ខៀវ សំផន មិនពេញចិត្ត គាត់ជំទាស់នោះទេ គាត់មិនឱ្យចូលរួមទេ។ បើធ្វើបែបនេះ វាអត់មានអ្វីជាមូលដ្ឋានសម្រាប់សំអាងពីការដែលខ្លួនមិនបានចូលរួមនៅក្នុងនីតិវិធីនេះ។ វាអត់មានមូលដ្ឋានផ្លូវច្បាប់ណាមួយដើម្បីការពារទេ មិនមែនថាឱ្យតុលាការសម្រេចអ្វីដែលខ្លួនមិនពេញចិត្ត ខ្លួនមិនចូលរួមមិនមែនទេ។ វាទាល់តែមានមូលដ្ឋានផ្លូវច្បាប់ណាមួយ ដែលធ្វើឱ្យយើងអាចលើកមកជាសំអាង ដើម្បីផលប្រយោជន៍ពីការការពារសិទ្ធិរបស់ជនជាប់ចោទផងដែរ បានជាយើងអាចធ្វើការពហិការមិនចូលរួម ឬក៏មានបញ្ហាដូចករណីដែលយើងអនុវត្តកន្លងមកនេះ មិនមែនជាពហិការមិនចូលរួមទេ។ យើងបានជម្រាបហើយ គឺដោយសារពេលវេលាដែលយើងមិនអាចធ្វើកិច្ចការពីរក្នុងពេលតែមួយបាន។ បាទ ដូច្នេះសូមឱ្យយល់។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។

ចុះខាងប្រធានអង្គភាពគាំពារការពារក្ដី តើមាន ចង់មានរួមមតិយោបល់អ្វីដែរឬទេ លើការតែងតាំងមេធាវីបម្រុង ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី?

បាទសូមទោស សូមអញ្ជើញ! សូមអញ្ជើញលោកស្រីមេធាវី!

[១១:១៥:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមិនដឹងថាត្រូវឆ្លើយឥឡូវនេះ ឬក៏យ៉ាងម៉េចទេ ក៏ប៉ុន្តែខ្ញុំចង់បន្ថែមបន្តិចទេ បន្ថែមលើអ្វីដែលលោក គង់ សំអុន បានលើកឡើងអម្បាញ់មិញនេះ។ ដោយខ្លីៗ ដើម្បីបន្ថែមលើអ្វីដែលគាត់

បានលើកឡើងអម្បាញ់មិញនេះ មានចំណុចជាច្រើនដែលមានលើកឡើងនៅក្នុងសារណា សំណើរបស់សហព្រះរាជអាជ្ញា។ ខ្ញុំសូមលើកយកបញ្ហាដែលនិយាយថា យើងកំពុងតែ -- មេធាវីការពារក្ដីកំពុងតែមិនគោរពបញ្ហា ការបង្គាប់របស់អង្គជំនុំជម្រះ។ ខ្ញុំគិតថា ទី១ មានការមិនយល់គ្នាផ្នែករប្បធម៌ច្បាប់រវាងព្រះរាជអាជ្ញា ហើយនិងខាងការពារក្ដី។ នៅក្នុងសារណារបស់ពួកគាត់ នៅក្នុងសារណា E321 គាត់និយាយអំពីទស្សនទានមួយដែលយើងអត់យល់ដែរ នៅក្នុងខាងសហព្រះរាជអាជ្ញា -- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញ គាត់និយាយថា យើងជាអ្នកជំនួយការជួយរកយុត្តិធម៌។ អ៊ីចឹងយើងជួយរកយុត្តិធម៌ យើងមិនមែននៅទីនោះដើម្បីជួយទេ។ ដូចខ្ញុំបានលើកឡើងអម្បាញ់មិញហ្នឹងដែរនោះបញ្ហា គឺថាមិនមែនធ្វើឲ្យជាប់គាំងនីតិវិធីទេ គឺថាយើងដឹងតាំងពីដើមមកហើយ បើសិនជាយើង -- បើសិនជាអស់លោកចង់បន្តនីតិវិធី បើចង់បង្ខំលោក ខៀវ សំផន ឲ្យធ្វើ មកចូលសវនាការនេះមានសិទ្ធិអំណាចធ្វើបាន។ ក៏ប៉ុន្តែបញ្ហាពិតនោះ វានៅត្រង់ថា ដើម្បីគោរពសិទ្ធិរបស់គាត់ តើធ្វើហ្នឹងដើម្បីគោរពសិទ្ធិគាត់ ឬក៏ដើម្បីរកយុត្តិធម៌ ឬក៏ដើម្បីអ្វី?

[១១:១៧:៥៦]

តាមពិតទៅខាងព្រះរាជអាជ្ញា គេលើកធ្វើសំណើចេញមក សំណើ ក្នុងសំណើរបស់គេនោះគឺថាមិនមែនសុំឲ្យអស់លោកចៅក្រមនោះ ការពារសិទ្ធិរក្សា ការពារសិទ្ធិលោក ខៀវ សំផន ឬក៏ នួន ជា ទេ។ តាមពិតទៅគ្រាន់តែធ្វើទៅឧបកិច្ចថាជាការការពារសិទ្ធិរបស់គាត់។ សហព្រះរាជអាជ្ញាគាត់និយាយផងដែរ ថ្ងៃនេះតែម្ដងនោះ ត្រូវរកមេធាវីបម្រុងជាមិត្តរបស់តុលាការហ្នឹង។ ហើយនៅក្នុងសារណា E314/7 ដែលគាត់សុំ -- ដែលយើង នៅក្នុងសុំសរសេរបន្ត -- ទំព័រថែម។ កាលនោះគេពន្យល់ថា ការបណ្ដឹងដិតចិត្តនេះសំខាន់ណាស់ ហើយមិនអាចធ្វើទៅបានទេ ពីព្រោះថាអាចអនុញ្ញាតឲ្យ -- ព្រោះថា ធ្វើទៅនោះស៊ីពេលយូរទម្រាំតែចៅក្រមថ្មីមកក្ដាប់សំណុំរឿងបាននោះៗយូរណាស់ ហើយថ្ងៃនេះ ខាងព្រះរាជអាជ្ញាដដែលហ្នឹងមកនិយាយថា ត្រូវ ដើម្បីគោរពសិទ្ធិរបស់ជនជាប់ចោទនោះ ត្រូវរើសមេធាវីបម្រុង មេធាវីរបស់មិត្តភក្តិរបស់តុលាការ ដើម្បីមកការពារពួកគាត់។ អ៊ីចឹងខ្ញុំមើលទៅឃើញដូចជានិយាយម្ដងអ៊ីចេះ ម្ដងអ៊ីចុះ ចម្រូងចម្រាសគ្នា។ បើសិនជាថា សម្រាប់ចៅក្រមនោះ ដើម្បីក្ដាប់សំណុំរឿងនេះបានណែន សំណុំរឿងដ៏មហាធំធេងនេះ ត្រូវការពេលវេលាច្រើន ហើយហៅមេធាវីបម្រុងមកហ្នឹងក៏ត្រូវការពេលវេលាច្រើនដូចគ្នាអ៊ីចឹងដែរ។ មកធ្វើយ៉ាងម៉េចដើម្បីក្ដាប់រឿងឲ្យណែន។

ដូច្នេះ អ៊ីចឹងសំណើសុំមេធាវីបម្រុងនោះ ខ្ញុំគិតថាមិនត្រឹមត្រូវទេ។ ហើយបើសិនជាគាត់មិន

បានការពារទទួលការអនុញ្ញាតពីលោក ខៀវ សំផន ផងនោះ ឬក៏លោក នួន ជា ផងនោះ តើមានការធានាសិទ្ធិរបស់ ខៀវ សំផន ឬក៏សិទ្ធិការពារក្ដីយ៉ាងម៉េចទៅកើត។ វានេះគ្រាន់តែជាបង្ហាញអាការៈខាងក្រៅ ឧបកិច្ចថាគោរពការពារសិទ្ធិគាត់នោះទេ។ អាស្រ័យហេតុដូច្នេះហើយ បានជាយើងគិតថានៅក្នុងសំណុំរឿងយើងនេះ ដែលថាយើងកំពុងតែមានសវនាការ -- កំពុងតែជិតធ្វើសវនាការអង្គសេចក្ដីផង ហើយយើងកំពុងប្ដឹងឧទ្ធរណ៍ផង។ អ៊ីចឹងយើងសូមផ្ដោតការប្រឹងប្រែងរបស់យើងទៅលើសារណាបណ្ដឹងឧទ្ធរណ៍ ហើយធ្វើនេះដើម្បីឲ្យការពារ -- ការការពាររបស់គាត់ហ្នឹងត្រូវបានគោរពនិងធ្វើដោយមានប្រសិទ្ធភាព។

[១១:២០:៤៧]

នៅកថាខណ្ឌ៥ នៃសារណាដដែលហ្នឹង របស់សហព្រះរាជអាជ្ញា គឺថាបើសិនជាយើងៗ ជ្រើស -- ធ្វើជម្រើសណាមួយ គឺថាដូចថា តាមតែងចិត្តយើង។ ក៏ប៉ុន្តែតាមពិតទៅ ខាងការពារក្ដីនេះ មិនមែនធ្វើអីតាមតែចិត្តទេ គឺថាយើងធ្វើយ៉ាងណាដើម្បីរក្សាសិទ្ធិរបស់លោក ខៀវ សំផន ហើយនិងការពារផលប្រយោជន៍ឲ្យគាត់ឲ្យបានប្រសើរ ជាការជម្រើសមួយដែលបង្ខំទេ ហើយជាការប្រថុយប្រថានផងដែរ ក៏ប៉ុន្តែត្រូវតែធ្វើការប្រថុយប្រថានយ៉ាងដូច្នេះ។

នៅក្នុងថាខណ្ឌបន្ទាប់ទៀត របស់លោកសហចៅព្រះរាជអាជ្ញាដដែល គឺថា អនុលោមតាមវិធាន២២/៤ “យើងត្រូវតែលើកស្ទួយយុត្តិធម៌ ហើយនិងធ្វើយ៉ាងណាឲ្យនីតិវិធីហ្នឹងដំណើរការត្រឹមត្រូវ ហើយមានប្រសិទ្ធភាព”។ អ៊ីចឹង ចុះបើយើងនិយាយតែអំពីរឿងអាការៈ គ្រាន់តែឧបកិច្ចថា ឲ្យមានយុត្តិធម៌ទេ ដូចជាមិនល្អទេចំពោះខាងការពារក្ដី។

[១១:២១:៥៥]

ហើយកថាខណ្ឌបន្ទាប់ទៀត គាត់និយាយថាធ្វើយ៉ាងម៉េចកាត់ក្ដីឲ្យបានដល់ចប់។ ខាងការពារក្ដីយើងនេះ គឺថាយើងគ្រាន់តែចង់និយាយថា ដោយសារឥឡូវ យើងត្រូវការសរសេរសារណាឧទ្ធរណ៍ផង ហើយពេលវេលាការងារជាន់គ្នាផង ហើយយើងធ្វើយ៉ាងណាសរសេរសារណាហ្នឹងឲ្យបានចប់តែប៉ុណ្ណោះ ហើយត្រូវការជ្រើសរើសយ៉ាងដូច្នេះហើយ មិនមែនថាយើងគេចវេសមិនព្រមការពារក្ដីគាត់ឲ្យដល់ចប់នោះទេ។ ហើយការដែលលើកឡើងថា គោលជំហររបស់យើងនោះធ្វើអូសបន្លាយពេលវេលា ហើយត្រូវចាត់ទុកថាជាការប្រមាថមើលងាយតុលាការ នេះត្រឹមត្រូវទាល់តែសោះការលើកឡើងយ៉ាងដូច្នេះ។ ហើយខ្ញុំមិនដឹងថា ពាក្យថា “សមហេតុ សមផល” នោះមានន័យយ៉ាងដូចម្ដេចនោះទេ ក៏ប៉ុន្តែ

បើសិនជាលោក ខៀវ សំផន គាត់មិនមានលទ្ធភាពការពារខ្លួនគាត់ឲ្យបានមានប្រសិទ្ធភាព។ ខ្ញុំគិតថា មិនដឹងជាខាងព្រះរាជអាជ្ញាគិតយ៉ាងម៉េចទេអំពីពាក្យថា “សមហេតុ សមផល” នោះ។

លោក ខៀវ សំផន គាត់មិនដែលលើកឡើង -- គាត់មិនដែលប្រាប់ឲ្យមេធាវីរបស់គាត់ឈប់ការពារគាត់ទេ ផ្ទុយទៅវិញ គាត់សុំឲ្យយើងការពារគាត់ឲ្យបានមានប្រសិទ្ធភាពក្នុងដំណាក់កាលដ៏សំខាន់នេះ។ ដោយហេតុថា មាននៅក្នុង -- ព្រះរាជអាជ្ញា គេលើកឡើងពីក្រមសីលធម៌វិជ្ជាជីវៈអីដែរ នៅក្នុងសារណារបស់គេ ហើយខ្ញុំក៏អាចដកស្រង់បានដែរ និយាយពីក្រមសីលធម៌វិជ្ជាជីវៈនេះ។

[១១:២៣:៤០]

ឥឡូវនេះ យើងក្នុងតុលាការមួយដែលទទួលជំនួយអំពីអង្គការសហប្រជាជាតិ។ ហើយ -- កថាខណ្ឌ១៤ “នៅពេលដែលការពារក្តីរបស់កូនខ្លួន ហើយនិងការលើកស្ទួយយុត្តិធម៌ មេធាវីត្រូវតែធ្វើយ៉ាងណា១ ធ្វើការដោយមានសេរីភាពគ្រប់គ្រាន់ ហើយនិងគោរពតាមច្បាប់ ហើយនិងស្តង់ដារដែលមានចែងអំពីវិជ្ជាជីវៈរបស់មេធាវី”។ ឧទាហរណ៍ មេធាវីត្រូវតែបម្រើសិទ្ធិ បម្រើកូនក្តីរបស់ខ្លួនឲ្យបានស្មោះត្រង់។ នៅថ្ងៃនេះ សហព្រះរាជអាជ្ញាសុំឲ្យតុលាការជ្រើសរើសមេធាវីបម្រុងមួយទៀត។ នេះគឺថាវាមិនត្រឹមតែប្រឆាំងនឹងឆន្ទៈរបស់កូនក្តីទេ ក៏ប៉ុន្តែលើសពីហ្នឹងទៅទៀតហ្នឹង គឺថាត្រូវការពេលវេលាច្រើន មេធាវីថ្មីមកនោះ ត្រូវការពេលវេលាច្រើនដើម្បីក្តាប់រឿងឲ្យបានមូល។ ដូច្នេះ ជាការរំលោភបំពានទាំងស្រុងហើយ។

មានអត្ថបទទាក់ទងនឹងក្រមសីលធម៌វិជ្ជាជីវៈផ្សេងទៀត ខ្ញុំសូមដកស្រង់ នេះចេញពីគណៈមេធាវីនៅទីក្រុងប៉ារីស។ នៅមាត្រា២១ នេះគឺ -- ព្រះរាជអាជ្ញាក៏បានដកស្រង់ពីកថាខណ្ឌហ្នឹងដែរ ក៏ប៉ុន្តែគេធ្វើការបកស្រាយដោយផ្អែកតែប៉ុណ្ណោះ។ ឥឡូវ ខ្ញុំសូមដកស្រង់ទាំងស្រុងតែម្តង។

កថាខណ្ឌ ២១/២.១.១ “ការងារជាច្រើនរបស់មេធាវីតម្រូវឲ្យគាត់មានឯករាជ្យភាពដាច់ខាត ហើយមិនត្រូវទទួលសម្ពាធណាមួយទេ ពី -- ជាពិសេស កើតចេញពីផលប្រយោជន៍ផ្ទាល់ខ្លួន ឬក៏ពីឥទ្ធិពលខាងក្រៅ។ ធ្វើយ៉ាងណា១ឲ្យគេចឲ្យផុតពីការទទួលសម្ពាធ ធ្វើយ៉ាងណាកុំឲ្យគិតតែពីខាងធ្វើឲ្យចៅក្រមពេញចិត្ត ឬក៏ភាគីណាពេញចិត្ត ឬកូនក្តីពេញចិត្ត”។

[១១:២៦:០៣]

នៅក្នុងសារណាសហព្រះរាជអាជ្ញាដដែលនោះគឺថា យើងក្នុងខណៈជាមេធាវី យើងបានធ្វើការសម្រេចចិត្ត មិនមែនដើម្បីតែប្រយោជន៍យើងទេ គឺមិនមែនឲ្យចៅក្រមសប្បាយចិត្ត ឬក៏ឲ្យអ្នកណា

សប្បាយចិត្តទេ គឺដើម្បីការពារផលប្រយោជន៍របស់កូនក្ដីយើង។ ការឯករាជ្យភាពរបស់យើងនេះ សំខាន់ណាស់ចំពោះយើង។ ការផ្ដល់ប្រឹក្សារបស់មេធាវីមិនមានប្រយោជន៍អីទេ បើសិនជាផ្ដល់ប្រឹក្សាដល់កូនក្ដីដើម្បីតែឲ្យគេពេញចិត្ត ហើយមិនមានលក្ខណៈច្បាប់។ ហើយបើសិនជាចង់រើសមេធាវីបម្រុងណាមួយដែលកូនក្ដីមិនបានពេញចិត្ត ហើយគាត់ក៏មិនអនុញ្ញាតឲ្យធ្វើ ហើយគឺគ្រាន់តែជាមេធាវី គេហៅថា មេធាវីឧបកិច្ចតែប៉ុននុ៎ងនោះ វាមិនល្អទេ។

នៅក្នុងផលប្រយោជន៍កូនក្ដីដដែល មេធាវីមានសិទ្ធិការពារផលប្រយោជន៍កូនក្ដីរបស់ខ្លួន ត្រូវតែធ្វើយ៉ាងណាឲ្យគោរពសិទ្ធិរបស់គាត់គឺជា មិនត្រូវគោរព -- ធ្វើម៉េចយើងបានគិតតែពីប្រយោជន៍របស់ខ្លួន ឬប្រយោជន៍របស់សហភាតារបស់ខ្លួនទេ។ ហើយយើងនៅទីនេះលើកឡើងថា យើងនៅទីនេះកំពុងតែធ្វើឲ្យនីតិវិធីគាំងស្ទះដោយសារយើងជាមេធាវីអសមត្ថភាពអីចឹងជាដើមនេះ ខ្ញុំសូមលើកកថា-ខណ្ឌមួយទាក់ទងនឹងការគោរពចៅក្រម៖ “យើងត្រូវគោរពចៅក្រម តុលាការ មេធាវីត្រូវតែការពារកូនក្ដីរបស់ខ្លួននិងពោរពេញទៅដោយសតិសម្បជញ្ញៈ ហើយនិងកុំឲ្យភ័យខ្លាចក្រែងអ្វីទាំងអស់ ហើយត្រូវតែគិតតែពីប្រយោជន៍របស់កូនក្ដីតែប៉ុណ្ណោះ”។

នៅពេលដែលយើងលើកឡើងថា នៅក្នុងក្រមសីលធម៌វិជ្ជាជីវៈ កថាខណ្ឌ៤-៥ -- មាត្រា៤-៥ *(ស៊ីក)* ទាក់ទងទៅនឹងការគាំពារសិទ្ធិមនុស្ស សេរីភាព ហើយនិងឯករាជ្យភាពនៅក្នុងមាត្រា៣៧ នៃក្រមសីលធម៌ហ្នឹងដែរ គឺថាមេធាវីអាចបង្ហាញវត្ថុតាងអ្វីទាំងអស់គ្រប់ទាំងអស់ ដើម្បីផលប្រយោជន៍របស់កូនក្ដីរបស់ខ្លួន។ មាត្រាមួយទៀត មេធាវីមួយទៀតត្រូវតែធ្វើយ៉ាងណាដើម្បីឲ្យមានការជម្រះសេចក្ដីដោយយុត្តិធម៌ក្នុងស្មារតីគោរពច្បាប់ ហើយនិងយុត្តិធម៌។

[១១:២៩:២៤]

ហើយឥឡូវនេះ យើងបែរមកចង់ជ្រើសតាំង -- ជ្រើសរើសមេធាវីបម្រុងមួយដែលមិត្តភក្ដិតុលាការ ដែលកូនក្ដីខ្ញុំមិននឹងចង់បានផង ហើយដែលមកអាចការពារក្ដីគាត់បានទេ ពីព្រោះថាគ្រាន់តែមកបង្ហាញមុខ មកឧបកិច្ច ពីព្រោះថា សារណារបស់សហព្រះរាជអាជ្ញានេះដែលគាំទ្រដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនេះគ្មានមូលដ្ឋានអ្វីទេ។ ចំពោះក្រុមការពារក្ដីយើងគឺថា បើដើម្បីឲ្យការពារក្ដីគាត់ឲ្យមានប្រសិទ្ធភាព យើងត្រូវតែការពារក្ដីគាត់ឲ្យបានពេញលេញ។ ហើយឥឡូវនេះ ត្រូវការពារគាត់នៅចំពោះមុខតុលាការកំពូលទៀត។ អីចឹង -- ហើយនៅពេលដែលខាងសហព្រះរាជអាជ្ញានិយាយថា យើងមិនអាចធ្វើអីចឹងបានទេ ពីព្រោះអីថ្ងៃក្រោយទៅគេយកទៅជាយុត្តិសាស្ត្រអីហ្នឹងមិនល្អទេ។

យើញថា ឲ្យតែមានបញ្ហាអី ពហិការមិនកើតទេ។ អ៊ីចឹង ខ្ញុំគិតថា មានតែ -- ខ្ញុំសួរថាតើនៅពេលដែលយើងកំពុងរង់ចាំសាលដីកានេះ នៅពេលដែលយើងមិនទាន់ទាំងដឹងថា ទឡ្ហីករណ៍នោះយ៉ាងម៉េច លោក ខៀវ សំផន និងបដិសេធទឡ្ហីករណ៍ណាខ្លះរបស់តុលាការកំពូលអីជាដើមនេះ តើយើងបន្តនីតិវិធីអីយ៉ាងម៉េច? ហើយតើអាចនិយាយថា លោក ខៀវ សំផន ហ្នឹង សិទ្ធិរបស់លោក ខៀវ សំផន ហ្នឹងត្រូវបានការពារយ៉ាងម៉េចកើត? អានេះគ្រាន់តែជាការបោកបញ្ឆោតគាត់ទេ។ ហើយបើតាមការកំណត់ដូចដែលយើងបានលើកឡើងកាលពីព្រឹកមិញនេះ នេះយើងនិយាយអ៊ីចឹងដោយសារយើងចង់ពន្លឿននីតិវិធីទេ។ ខ្ញុំគិតថា យើងគួរតែដឹងទាំងអស់គ្នាថា យើងមានការលំបាកណាស់ក្នុងការទទួលយកសំណើរបស់សហព្រះរាជអាជ្ញានេះ។ ខ្ញុំគ្រាន់តែចង់និយាយថា សំណើរបស់ព្រះរាជអាជ្ញាទាក់ទងទៅនឹងការកំណត់ពេលវេលានេះមិនត្រឹមត្រូវទាល់តែសោះ ព្រោះថា ការស្នើយ៉ាងដូច្នេះរំលោភសិទ្ធិការពារក្តីទាំងស្រុងហើយ។

អ្នកដែលពាក់ព័ន្ធមុនគេ គឺថា លោក ខៀវ សំផន ហ្នឹង តាំងព្រឹកមិញ គាត់ចង់ឆ្លើយទៅនឹងសំណើសហព្រះរាជអាជ្ញានេះ តាំងពីព្រឹកមកគាត់ចង់ឆ្លើយតប។ ដូច្នេះ ខ្ញុំសូមឲ្យតុលាការអនុញ្ញាតឲ្យគាត់ឆ្លើយតប លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ខៀវ សំផន។

[១១:៣២:៣៨]

**លោក ខៀវ សំផន៖**

បាទ សូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំឡើងនិយាយ។

ខ្ញុំបានអានលិខិតរបស់សហព្រះរាជអាជ្ញាចុះថ្ងៃ២២ តុលា ឆ្នាំ២០១៤។ ខ្ញុំមានការសង្ស័យថានឹងមានកើតរឿងអីមួយសំខាន់ទាក់ទងដល់មេធាវីជាតិការពារក្តីខ្ញុំ និងសិទ្ធិរបស់ខ្ញុំហើយ។ អ៊ីចឹងបានថ្ងៃនេះ ខ្ញុំមកនេះ ខ្ញុំសូមមកនេះ។ ហើយដល់ខ្ញុំស្តាប់ការណ៍ទៅ ឥឡូវវាចូលក្នុងការដែលខ្ញុំស្មានអ៊ីចឹងមែន។ សហព្រះរាជអាជ្ញាលើកអំពីការចាត់តាំងមេធាវីបម្រុង ឬហៅថាមេធាវីមិត្តរបស់តុលាការ។ ខ្ញុំសូមជម្រាបថា ការស្នើនេះវាឈានទៅច្បាស់ណាស់ ឈានទៅបណ្តេញមេធាវីខ្ញុំហើយ។ ហើយខ្ញុំសូមជម្រាបថា ជាហូរហែមក ខ្ញុំមិនដែល -- ខ្ញុំតែងតែខំព្យាយាមមកចូលស្តាប់សវនាការ។ ហើយមេធាវីខ្ញុំមកបណ្តាក់គ្នាមកចូលជាប់ មេធាវីខ្មែរជាតិខ្ញុំក៏មកជាប់។ ដូច្នេះ មិនមានគោលបំណងអីទៅឲ្យធ្វើរាំងស្ទះទេ។ ហើយខ្ញុំធ្វើឲ្យរាំងស្ទះម៉េចកើត បើខ្ញុំនៅក្រៅឃុំឯណោះ ទុកថាខ្ញុំចង់ធ្វើឲ្យរាំងស្ទះ ពន្យារ

ពេលអ៊ីចេះ អ៊ីចុះ ក្រែងកុំឲ្យតុលាការកាត់ទោស ខ្ញុំទាន់។ ប៉ុន្តែអានេះខ្ញុំជាប់គុកទៅហើយ ខ្ញុំមានផលប្រយោជន៍អីនឹងពន្យារពេល។ ដូច្នេះការអះអាងរបស់មេធាវី របស់លោកសហព្រះរាជអាជ្ញាមិនត្រឹមត្រូវទេ។ មិនដែលពេលណាដែលខ្ញុំនិយាយ សុំឲ្យមេធាវីខ្ញុំធ្វើពហិការទេ។ ហើយមេធាវី ខ្ញុំមិនដែលនិយាយពីធ្វើពហិការទេ។ ដូច្នេះ អត់ត្រូវមានអីដេញគាត់ទេ។

[១១:៣៥:០០]

ម៉្យាងទៀត មេធាវីបម្រុងអីគេនោះមិនដឹងមកពីណា អត់យល់សំណុំរឿងខ្ញុំផង។ ដូច្នេះ មេធាវីការពារខ្ញុំម៉េចកើត បើអត់យល់សំណុំរឿងខ្ញុំសោះ។ មេធាវីខ្ញុំធ្វើការជាមួយខ្ញុំមកដល់ខែនេះ បីឆ្នាំហើយ នៅតែមានគាត់មកសួរចំណុចល្អិតខ្លះអ៊ីចឹងថែមទៀត។ ហើយធ្វើក្នុងការបីឆ្នាំនេះ គឺធ្វើការញឹកញាប់ឯខ្ញុំនៅតែជាមុខ -- នៃ*(ឮមិនច្បាស់)* របស់ខ្ញុំទេ។ អាហ្នឹងខ្ញុំសូមជម្រាបច្បាស់អ៊ីចឹង។ ប៉ុណ្ណឹងហើយ នៅតែមិនទាន់ដឹងសំណុំរឿងឲ្យបានល្អិតគ្រប់គ្រាន់ទៀត នៅតែមកសួរបញ្ជាក់ខ្ញុំជាប់ទៀត។ ចុះមេធាវីថ្មីមកអត់ដឹងអីសោះអ៊ីចឹងឲ្យខ្ញុំទទួលយកមកធ្វើអី បើគ្រាន់តែមកឧបកិច្ច ហើយមកការពារអត់កើត។ គ្រាន់តែមកធ្វើរាកល្ហែនហ្នឹង! ដូច្នេះខ្ញុំសូមជម្រាបប្រកាសឲ្យច្បាស់ ជូនអង្គជំនុំជម្រះថា ខ្ញុំដាច់ខាតមិនទទួលយកមេធាវីថ្មីណាទេ។ ខ្ញុំសូមជម្រាបអ៊ីចឹងបាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះជាការប៉ុនប៉ងដើម្បីពិនិត្យមើលការប្រជុំថ្ងៃនេះ។ ជម្រាបជូនមេធាវីការពារក្តី នួន ជា អ្វីដែលលោកបាននិយាយ ខ្ញុំបានកត់សម្គាល់ គឺថាទាក់ទងទៅនឹងបញ្ហាមួយចំនួនគឺទាក់ទងទៅនឹងសុំឲ្យការប្រជុំថ្ងៃនេះជាសាធារណៈ ហើយនិងធានាថាឲ្យនឹងមានការប្រជុំបែបនោះមែន។ សំណួររបស់ខ្ញុំគឺថាតើមតិយោបល់អ្វីទៅលើនឹងបញ្ហាសារធាតុខ្លឹមសារដែរទេ ពីព្រោះលោកមិនទាន់បានបញ្ជាក់នៅឡើយ។

[១១:៣៧:០៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណចៅក្រម ហ្វេនស៍។

សូមអភ័យទោសនូវសំណើរបស់ខ្ញុំ ខ្ញុំមិនបានយល់ច្បាស់កាលពីដើមនោះ។ ប៉ុន្តែខ្ញុំគិតថា ខ្ញុំជឿជាក់ថាការប្រជុំនេះនឹងត្រូវធ្វើឡើងជាសាធារណៈដែលយើងគប្បីមានអាវមេធាវី ហើយការពិភាក្សា

ហ្នឹងជាសាធារណៈលើបញ្ហាខ្លឹមសារជាមូលដ្ឋាន។ ការបោះពុម្ពផ្សាយនូវវីដេអូនៃការប្រជុំ ឬក៏សវនាការនៅពេលក្រោយនោះ គឺមិនមែនជានីតិវិធីដែលយើងត្រូវធ្វើនោះទេ។ នេះជាបញ្ហាពិភាក្សាតទល់ដ៏ជាក់ស្តែង គឺវាមិនមែនទាក់ទងទៅនឹងការប្រជុំរៀបចំសវនាការដូចដែលយើងធ្វើពីដើមទេ ពីព្រោះដែលយើងនិយាយពេលនេះគឺភាពយុត្តិធម៌នៃដំណើរការនីតិវិធី សំណើរបស់ខ្ញុំគឺថាសូមឲ្យផ្អាកត្រឹមនេះ គឺថាឲ្យបើកប្រជុំឡើងវិញដោយសារវាផ្ទុយទៅនឹងគោលការណ៍សាធារណៈ។ នេះជាសំណើរបស់ខ្ញុំគឺថា ធ្វើបែបនេះ។ សូមអរគុណ។

[១១:៣៨:០៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៩:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ មុននឹងលោកប្រធានចេញសេចក្តីសម្រេចលើសវនាការជាសាធារណៈនេះ ខ្ញុំសូមឆ្លើយតបទៅនឹងការកត់សម្គាល់របស់លោកមេធាវីការពារក្តីដែលនិយាយសួរខ្ញុំ អម្បាញ់មិញថាតើយើងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះ? ខ្ញុំសូមរំឭកអំពីវិធានផ្ទៃក្នុង វិធាន១២ស្ទួនពីរ (៥) ដែលយើងតំណាងឲ្យក្រុមមូល ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុងទាំងអស់។ មេធាវីការពារក្តីនេះមិនត្រូវមកនិយាយអំពីរឿងគឺថាយើងតំណាងថា នៅតែមានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននោះលែងចង់ចូលរួមក្នុងសវនាការទៀតហើយ។ អ៊ីចឹងយើងត្រូវមើលវិធានផ្ទៃក្នុងយើងគឺថា អង្គ ពេជ ហើយនិងខ្ញុំនេះ ត្រូវតែការពារផលប្រយោជន៍រួមរបស់មេធាវីទាំង ៣.០០០ – ជិត ៤.០០០នាក់នេះ។ ហើយយើងធ្វើការដ៏លំបាកយើងត្រូវការធ្វើសំយោគរាល់ថ្ងៃពេលដែល ពេជ អង្គ ហើយនិងខ្ញុំនិយាយជាសាធារណៈ ឬក៏កាន់គោលជំហរណាមួយ យើងត្រូវតែពិភាក្សាជាមួយក្រុម -- ជាមួយនឹងមេធាវីទាំងអស់ ហើយនិងកូនក្តីទាំងអស់។ អ៊ីចឹងៗ ខ្ញុំគិតថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដែលសាលក្រមនៅថ្ងៃទី២៧ ខែសីហា រួចមកហើយ ហើយឃើញមានការ -- ឃើញថាមិនមានការចោទជាបញ្ហាអីក្នុងការតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ។

[១១:៤១:០៤]

ខ្ញុំមានពីរចំណុច។ លោកមេធាវីរបស់ នួន ជា បាននិយាយអំពីរឿងកំប៉ិកកំប៉ុក ដែលខ្ញុំនិយាយអម្បាញ់មិញនេះដូចជាសវនាការដូចជាល្បែង។ បើសិនជាគោលបំណងរបស់គាត់នោះគ្រាន់តែចង់លើកឡើងអំពីការលំបាករបស់ក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើសំយោគជាប្រចាំថ្ងៃព្រោះកូនក្ដីច្រើន ខ្ញុំគិតថានេះជាបញ្ហាប្រឈមរបស់យើងរាល់ថ្ងៃ។ អ៊ីចឹងបើសិនជាគាត់និយាយអម្បាញ់មិញនេះដើម្បីគ្រាន់តែបញ្ជាក់ថាការងារពួកយើងនេះលំបាកណាស់ ព្រោះថាជាការពិភាក្សាគ្នានៅពេលយើងឡើងនិយាយនៅទីនេះរាល់ដងនោះ គឺមានខាងការពារក្ដីមកនិយាយជំទាស់យើងនោះ ក្នុងឋានៈយើងជាអ្នកតំណាងឲ្យកូនក្ដីជាង ៣.០០០នាក់។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះបង្គាប់ទៅឲ្យខាងការពារក្ដីពន្យល់ឲ្យច្បាស់ថាចង់និយាយយ៉ាងម៉េច ពីព្រោះថាយើងតំណាងឲ្យកូនក្ដីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់តែម្ដងក្នុងសវនាការនេះជាក្រុមតែមួយ រួមតែមួយទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោក លោកស្រីចៅក្រម។ ដើម្បីចាប់ផ្ដើមខ្ញុំឃើញថាជិតម៉ោងដប់ពីរហើយហើយខ្វះដប់ប្រាំនាទី។ ហើយដើម្បីចាប់ផ្ដើមខ្ញុំសូមបញ្ជាក់ថា ដូចដែលខ្ញុំបានបញ្ជាក់នៅការប្រជុំរៀបចំសវនាការចុងក្រោយនោះគឺថាលោកមេធាវីការពារក្ដីទាំងពីររូបមិនចូលរួមនោះ ខ្ញុំពិនិត្យឃើញបញ្ហាដែលពិភាក្សាអំពីការធ្វើពហិការរបស់មេធាវីការពារក្ដីនោះគប្បីតែធ្វើសាធារណៈ។ ហើយក៏ខ្ញុំនឹងគាំទ្រទៅនឹងសំណើដែលថា អ្វីដែលវាខុសពីអ្វីដែលបានយើងសរសេរនោះក្ដី ឥឡូវនេះខ្ញុំស្នើឲ្យអង្គជំនុំជម្រះសម្រេចថាបើកជាសាធារណៈវិញ ហើយបើសិនជាមិនចង់ធ្វើបែបនោះទេ ខ្ញុំនឹងបន្ថែមលើមតិយោបល់សំណើ។ ហើយខ្ញុំស្នើអង្គជំនុំជម្រះពិចារណា ហើយខ្ញុំនឹងសុំបន្ថែមមតិយោបល់ជាចុងក្រោយបន្ថែមតទៅទៀតនោះ។

[១១:៤៣:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៦:៣០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកចៅក្រម ហ្វេនស៍ ដើម្បីឆ្លើយតបទៅនឹងការលើកឡើង

របស់មេធាវីការពារក្តី នួន ជា ក៏ដូចជាសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះកត់សម្គាល់ថា ការប្រជុំរៀបចំសវនាការមានគោលបំណងរបស់ខ្លួន។ គោលបំណងខ្លះគឺថាធ្វើឲ្យអង្គជំនុំជម្រះជាអ្នកសម្រេចថាពេលខ្លះត្រូវអសាធារណៈ ហើយវគ្គខ្លះអាចសាធារណៈ។ ដូចដែលខ្ញុំបញ្ជាក់ថាអង្គជំនុំជម្រះយល់ស្របថាការពិភាក្សាលើបញ្ហាទាក់ទងទៅនឹងមេធាវីជាមិត្តរបស់តុលាការគប្បីជាសាធារណៈ។ ប៉ុន្តែមានគោលបំណងច្រើនដើម្បីសម្រេចបាន អង្គជំនុំជម្រះបានច្រានចោលក្នុងការផ្អាកដើម្បីបើកសវនាការសាធារណៈនៅពេលល្ងាច ប៉ុន្តែខ្លួននឹងបោះពុម្ពផ្សាយនូវខ្លឹមសារឬក៏ខ្សែវីដេអូនៃការពិភាក្សានៅក្នុងការប្រជុំរៀបចំនៅក្នុងសវនាការនេះ។

យើងសូមជម្រាបថា ការពិភាក្សានេះគឺគប្បីតែធ្វើជាលាយលក្ខណ៍អក្សរ ហើយមិនមានភាពចាំបាច់ទាំងស្រុងនឹងធ្វើការជាផ្លូវការ យើងសម្រេចធ្វើបែបហ្នឹងដើម្បីឲ្យមានភាពឆាប់រហ័ស។ ហេតុដូច្នេះ ពេលវេលាក្នុងការលើកឡើងនូវខ្លឹមសារជាសារធាតុគឺមានតែពេលនេះតែប៉ុណ្ណោះ។

ខ្ញុំគិតថាឲ្យសហព្រះរាជអាជ្ញាឆ្លើយតបនៅពេលដែលយើងបានស្តាប់ពីមេធាវីការពារក្តី។ ដូច្នេះខ្ញុំសុំស្នើឲ្យលោក កូប៉េ បើលោកមានមតិយោបល់ទៅលើខ្លឹមសារសារធាតុ លោកអាចលើកឡើងបាន។

[១១:៤៨:៤៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម ហើយនិងសមាជិកអង្គជំនុំជម្រះសាលាដំបូង។ ដូចដែលបានបញ្ជាក់ដោយខ្ញុំពីខាងដើមដែរ។ នេះជាបញ្ហាគោលការណ៍សំខាន់មួយ យើងបានទទួលសារណារបស់សហព្រះរាជអាជ្ញាពីរបីថ្ងៃមុនតែប៉ុណ្ណោះ។ យើងមានលទ្ធភាពក្នុងការពិនិត្យមើលៗពាក្យពេចន៍ហើយនិងខ្លឹមសារ ហើយយើងៗបានឆ្លៀតពិភាក្សាខ្លឹមសារបន្តិចបន្តួចជាមួយកូនក្តីរបស់យើងខ្ញុំពីម្សិលមិញ។ ជំហររបស់កូនក្តីខ្ញុំទាក់ទងទៅនឹងសំណើនេះ ត្រូវបានធ្វើយ៉ាងច្បាស់ហើយ គឺថានៅក្នុងលិខិតផ្ទាល់ខ្លួនរបស់គាត់កាលពីម្សិលមិញ ដែលជូនទៅលោក អ៊ីនដឺលី ជាប្រធានអង្គភាពគាំពារការពារក្តីនោះ។ លោក នួន ជា នឹងបដិសេធចោលនូវទម្រង់ណាមួយនៃមេធាវីបម្រុងណាមួយដែលបង្ខំឲ្យគាត់ទទួលយកនោះ គាត់នឹងបដិសេធទាំងស្រុង។ នេះជាជំហរបឋមរបស់យើងខ្ញុំ។ បញ្ហានោះ ថាតើយើងដោះ

ស្រាយបញ្ហានេះយ៉ាងដូចម្ដេច។

ជាថ្មីម្ដងទៀត យើងនឹងធ្វើសវនាការជាសាធារណៈ ប៉ុន្តែបើមានការសម្រេចដោយអង្គជំនុំជម្រះថា យើងធ្វើបែបនេះ យើងធ្វើបែបនេះតទៅទៀត។ ប៉ុនដូចដែលយើងសង្កេតឃើញ ដូចជាសហព្រះរាជអាជ្ញានិងភាគីបានពិនិត្យឃើញថា បញ្ហាទាំងអស់នេះ គឺវាខុសពីបញ្ហាដែលលើកឡើងដោយមេធាវី ខៀវ សំផន។ យើងមានការជឿជាក់យ៉ាងរឹងមាំថា តាមច្បាប់កម្ពុជា ហើយមានការតឹងតែង ថាតើចៅក្រមត្រូវធ្វើដូចម្ដេចនៅក្នុងបញ្ហាដែលមានសំណើចំពោះរឿងករណីបណ្ដឹងជិតចិត្តនេះ។

[១១:៥០:៤៥]

ដូចដែលខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង អំពីវិធីដែលយើងត្រូវបកស្រាយក្របខ័ណ្ឌច្បាប់នៅក្នុងដំណើរការនីតិវិធីរបស់អ.វ.ត.ក នោះ។ មាត្រា ៥១៦, ៥៩០ *(ស៊ីក)* នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃកម្ពុជា បាននិយាយយ៉ាងច្បាស់ថា ចៅក្រមនឹងត្រូវចាកចេញនៅពេលដែលមានបណ្ដឹងជិតចិត្តនេះ បើអាចនឹងបន្តសវនាការលើករណីដែលក្នុងបញ្ហា បើយើងត្រូវគោរពទៅតាមច្បាប់របស់ប្រទេសដែលថាវិធានផ្ទៃក្នុងវាផ្ទុយទៅនឹងច្បាប់កម្ពុជានោះ។ នេះជាការពិតដែលថា សហព្រះរាជអាជ្ញានិយាយថា នៅក្នុងអតីត-កាលយើងបានសម្រេចចិត្តថានឹងមិនបន្តបញ្ហា ប៉ុន្តែបណ្ដឹងជិតចិត្តនៅពេលនេះ គឺយើងសរសេរ ៤៥ ទំព័របន្ទាប់ពីសាលក្រម ដែលកាត់ទោសឲ្យកូនក្ដីរបស់ខ្ញុំជាប់ពន្ធនាគារមួយជីវិត គឺជាគោលការណ៍ដ៏ចម្បងណាស់ គ្រឹះណាស់ ដែលថាឲ្យលោក នួន ជា គាត់យល់ច្បាស់។ ហើយបើសិនអង្គជំនុំជម្រះសម្រេចបន្ត ហើយបានចេញដីកាកំណត់កាលបរិច្ឆេទសវនាការដោយដឹងថា យើងខ្ញុំនឹងដាក់បណ្ដឹងជិតចិត្តនោះហើយក៏ដោយ។ នេះជាបញ្ហាដែលកើតមានឡើងជាក់ស្ដែង គឺបែបនេះ។

ដូច្នេះនៅក្នុងរបាយការណ៍បញ្ចប់សវនាការពីមុននោះ គឺថាបានចង្អុលបង្ហាញថា -- ហើយបើមានការងារបញ្ហាបែបនេះ គឺមានការពន្យារពេលសវនាការពីរ ឬបីខែ។ ប៉ុន្តែ ការងារដែលមិនបានអនុវត្តទៅតាមបែបនោះ គឺថាអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញដែលយើងចង់ពិនិត្យមើលដែលថាទាក់ទងទៅនឹងច្បាប់កម្ពុជាទៅនឹងសេចក្ដីសម្រេចនោះ គឺថាសេចក្ដីសម្រេចមិនធម្មតាសម្រាប់លោក នួន ជា ជាសេចក្ដីសម្រេចដែលមិនធ្លាប់មានពីមុន ហើយជានិច្ចកាល គឺត្រូវគោរពទៅតាមនីតិវិធី វិធានផ្ទៃក្នុងនៅក្នុងរឿងក្ដី០០១។ ពេលខ្លះយើងថា ពេលណាវាគ្រប់គ្រាន់ គឺវាគ្រប់គ្រាន់បែបនេះ។ ដូច្នេះក៏សុំឲ្យមានការបំភ្លឺ បំភ្លឺពីគោលជំហរ ពីជំហររបស់កូនក្ដីរបស់ខ្ញុំដែរ។ ប៉ុន្តែមានរឿងជាច្រើនដែលខ្ញុំអាចជម្រាបជូនអំពីៗលក្ខណៈឱកាសនិយមនៃការលើកឡើងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្ប-

វេណី ដោយបានស្នើសុំឲ្យមានការតែងតាំងមេធាវីបម្រុង ឬក៏ថាជាមិត្តរបស់តុលាការនោះ វាហាក់ដូចជាកុមារនៅសាលាដែលថាតវ៉ាទៅគ្រូទៀតថា ក្មេងម្នាក់ទៀតបានបន្លំនៅក្នុងការប្រលងហើយ។ ដូច្នេះកាយវិការបែបនេះមិនសមស្របទៅនឹងជំហារនិងសំណើរបស់សហព្រះរាជអាជ្ញានោះដែរ។ ហើយគឺថាមិនអាចនឹងគាំទ្រទៅលើជំហររបស់ឱកាសនិយម ឱកាសនិយមរបស់សហព្រះរាជអាជ្ញា ថាត្រូវតែចាត់តាំងមេធាវីបម្រុង ដើម្បីបន្តកិច្ចដំណើរការនីតិវិធីនោះទេ។ ដូច្នេះប្រធានអង្គភាពគាំពារការពារក្ដីគឺថាអាចនឹងជម្រាបជូនអង្គប្រជុំពេលនេះថា បញ្ហាដែលធ្វើបែបនេះគឺមិនអាចធ្វើទៅបានទេ។ ដូច្នេះគឺថាពាក្យពេចន៍ចុងក្រោយរបស់គាត់នៅក្នុងសវនាការកាលពីសប្ដាហ៍មុនហ្នឹង គឺថាបន្ទាប់ គឺថាយ៉ាងហោចណាស់តែបួនខែដើម្បីនឹងស្វែងរកមេធាវីសមស្របណាមួយបាន។ ដូច្នេះខ្ញុំគិតថា បើសិនខ្ញុំនិយាយខុសនឹងកែខ្ញុំផង។ ខ្ញុំគិតថា ដូច្នេះគឺថាគុណវុឌ្ឍិរបស់មេធាវីបម្រុងហ្នឹង គឺថាដូចគ្នានឹងមេធាវីផ្សេងទៀតដែរ ដើម្បីមកៗវត្តមានការពារបាននោះ គឺថាអាចនឹងត្រូវប្រើពេលប្រាំមួយខែ ដើម្បីឲ្យមេធាវីបម្រុងណា ឬក៏មិត្តតុលាការណាអាចនឹងមកអានសំណុំរឿង ដូចដែលយើងបានធ្វើបីឆ្នាំរួចមកហើយនោះ។ ដូចនេះជាបញ្ហាទាក់ទងទៅនឹងបញ្ហាអនុវត្តហ្នឹង គឺថាលោក អ៊ីនដឺលី គឺថាអាចនឹងជម្រាបជូនពីបញ្ហានេះជាក់ស្ដែងជូនអង្គជំនុំជម្រះ ឬក៏កិច្ចប្រជុំថ្ងៃនេះបាន។

[១១:៥៥:៣៤]

ចំណុចមួយផ្សេងទៀតដែលខ្ញុំចង់ជម្រាបដែរនោះ យើងពិនិត្យមើលទាំងស្រុងនៃដំណើរការនីតិវិធីនៅក្នុងវិធានផ្ទៃក្នុង ខ្ញុំមិនឃើញបទប្បញ្ញត្តិណាមួយក្នុងវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងចាប់តាំងមេធាវីបម្រុង ឬក៏មិត្តរបស់តុលាការនេះទេ។

យើងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ រីឯមេធាវីបម្រុង ឬក៏មិត្តរបស់តុលាការនោះ គឺជាបាតុភាពមួយដែលមានកើតឡើងនៅទៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូទេ។ ខ្ញុំខ្លួនឯងមកពីប្រព័ន្ធថ្នាក់ជាតិ ហើយនៅក្នុងប្រព័ន្ធស៊ីវិលឡូ ជាប្រព័ន្ធស្រដៀងនឹងបារាំង ខ្ញុំធានាថាមិនដែលមានសេចក្ដីសម្រេចណាមួយទេប្រហែលជានៅក្នុងរយៈពេលប្រវត្តិ៦០០ឆ្នាំ នៃប្រទេសនៃតុលាការហូឡង់មិនដែលមានសេចក្ដីសម្រេចណាមួយ ដែលថាឲ្យចាត់តាំងមេធាវីបម្រុងពេលដែលមានករណីដូចយើងនេះទេ។ ហើយក៏មាន -- នៅក្នុងនីតិវិធីរបស់ជាតិកម្ពុជាហ្នឹង ក៏មិនមានឲ្យមានចាត់តាំងមេធាវីបម្រុងណាបែបនេះដែរទេ។ ដូច្នេះការចោទប្រកាន់ថាយើងខ្ញុំប្រើតាក់ទិក មកប្រើឧបាយ វិធីសាស្ត្រដើម្បីពន្យារពេលអូសបន្លាយអីនេះ។ ដូច្នេះការដែលប្រើពាក្យថា ប្រើយុត្តិសាស្ត្រ ឬក៏វិធីដើម្បីពន្យារពេលដោយសហព្រះរាជអាជ្ញានោះ គឺថា

មិនមែនជាការត្រឹមត្រូវទេ។ ជំហររបស់កូនក្តីខ្ញុំ គឺនៅតែច្បាស់ដដែល យើងនៅរង់ចាំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេសទាក់ទងទៅនឹងបណ្តឹងដិតចិត្ត ហើយយើងមិនដឹងថា សេចក្តីសម្រេចហ្នឹងចេញនៅពេលណាទេ។

នៅក្នុងនីតិវិធីជាតិរបស់ខ្ញុំ គឺថាជួនការគឺគេប្រើពេលតែបីបួនថ្ងៃទេ ក្នុងករណីមានបណ្តឹងដិតចិត្ត។ ប៉ុន្តែខ្ញុំមិនប្រាកដថាត្រូវប្រើពេលយូរនៅទីនេះនោះ ដោយសារមូលហេតុអ្វីទេ ដែលថាកូនក្តីរបស់ខ្ញុំហ្នឹងបានដកស្រង់អំពីអ្នកនាំពាក្យសាលាក្តី គឺថាអាចនឹងត្រូវប្រើពេលបីខែ ទើបបានមានការសម្រេចលើបណ្តឹងដិតចិត្តដែរ។ ក្នុងករណីនេះ ខ្ញុំមិនទាន់ច្បាស់រឿងហ្នឹងទេ ប៉ុន្តែខ្ញុំអាចនឹងគិតឃើញថា ប្រសិនបើយើងទទួលបានសេចក្តីសម្រេចឆាប់ៗនោះ ដែលជាសេចក្តីសម្រេចហ្នឹង គឺថាមិនទាន់មានសំអាងហេតុនោះទេ គឺថាជាសេចក្តីសម្រេចសង្ខេបមុខ ប៉ុន្តែខ្ញុំមិនដឹងថាសេចក្តីសម្រេចសង្ខេបហ្នឹងនឹងឆ្លើយតបទៅនឹងគោលជំហររបស់លោក នួន ជា នោះទេ។

[១១:៥៨:២៣]

ប៉ុន្តែជំហររបស់យើងខ្ញុំហ្នឹងគឺថា គឺនឹងដើរទៅតាមវិធីសាស្ត្រមួយជំហានៗនៅក្នុងករណីនេះ។ ជាពិសេសនៅក្នុងបរិបទដែលថាបញ្ហាដែលយើងលើកឡើងនៅក្នុងបណ្តឹងដិតចិត្ត ដែលថាវាទាក់ទងផ្ទាល់ទៅនឹងភាពឯករាជ្យនៃចៅក្រមជាតិទាំងអស់នោះ។ ដូច្នេះ ដែលអាចមានលទ្ធភាពថា យើងមានសេចក្តីសម្រេចខ្វែងមតិគ្នានៅក្នុងអង្គជំនុំជម្រះពិសេសនោះ គឺថាអាចនឹងមតិចៅក្រមអន្តរជាតិផ្សេងជាតិផ្សេង ឬក៏មិនដឹង ឬក៏ថាអាចយើងពិនិត្យមើលទាំងអស់នោះ ប៉ុន្តែមុននឹងឆ្លងទៅដល់ណោះ គឺថាជំហររបស់យើងខ្ញុំពេលនេះ គឺច្បាប់ហើយ កូនក្តីរបស់ខ្ញុំបានណែនាំពួកខ្ញុំថា មិនឲ្យចូលរួមនៅក្នុងសវនាការស្តាប់ភស្តុតាងអង្គសេចក្តីទេ បើមិនទាន់មានសេចក្តីសម្រេចលើបណ្តឹងដិតចិត្តនោះជាមុនទេ។

រីឯការចាត់តាំងមេធាវីបម្រុង ឬក៏មិត្តរបស់តុលាការនោះ ក៏មិនៗអាចជាការចំណេញពេលវេលាអ្វីនោះទេ ប៉ុន្តែវាជាការបំពានទៅលើគោលការណ៍នៃការយុត្តិធម៌ ការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងករណីនេះផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញលោកស្រីចៅក្រម ហ្វែនស៍!

**ចៅក្រម ក្លូឌា ហ្វែនស៍៖**

ខ្ញុំមានសំណួរពីរបន្ថែមទាក់ទងទៅនឹងអ្វីដែលលោកបានលើកឡើងអម្បាញ់មិញ លោកមេធាវី។

តើខ្ញុំយល់លោកត្រូវទេ ខ្ញុំមិនបានឮអំពីសេចក្តីសម្រេចសង្ខេប ហើយសេចក្តីសំអាងហេតុតាមក្រោយ។ បើសិនជាមានសេចក្តីសង្ខេបចេញសម្រេចសង្ខេប ហើយមានសំអាងហេតុចេញតាមក្រោយ តើលោកអាចគិតថា លោកនឹងមិនបន្តដែរឬទេ? នេះគឺទាក់ទងទៅនឹងសំណួរចុងក្រោយ តើថានឹងមានៗបញ្ហាអ្វីបើសិនសេចក្តីសម្រេចចេញនោះមក ហើយលោកមិនពេញចិត្តជាសេចក្តីដែលមានសំអាងហេតុផង ប៉ុន្តែលោកមិនពេញចិត្តដដែល។ តើលោកនឹងធ្វើដូចម្តេច?

[១២:០០:៣៥]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណចៅក្រម ហ្វេនស៍។ ដើម្បីនិយាយឲ្យច្បាស់ គឺថាអ្នកដែលអាចឆ្លើយសំណួរនេះបាន គឺមានតែម្នាក់ទេ ហើយគាត់មិននៅក្នុងទីនេះទៀតផង។ យើងធ្វើការទៅតាមការបង្គាប់បញ្ជារបស់គាត់តែម្នាក់គត់។ ប្រសិនបើគាត់មិនពេញចិត្ត ប្រហែលជាយើងជាមេធាវីតាមប្រព័ន្ធស៊ីវិលឡូ គឺយើងនឹងគោរពទៅតាមការបង្គាប់បញ្ជារបស់គាត់។ យើងមិនមែនជាមន្ត្រីរបស់តុលាការនេះទ។ ខ្ញុំបញ្ជាក់ម្តងហើយម្តងទៀតអ៊ីចឹង។ គឺថាប្រសិនបើមានការអ្វីគឺយើងអាចនឹងមិនចូលរួម។ ខ្ញុំមិននិយាយថា កូនក្តីខ្ញុំបង្គាប់ឲ្យខ្ញុំ ដូចដែលខ្ញុំនិយាយនោះទេ ហើយខ្ញុំក៏មិនចង់និយាយថា ទោះបីថាសេចក្តីសម្រេចមានហេតុផល -- មិនមានសំអាងហេតុ ឬក៏មិនមានសំអាងហេតុល្អដោយ ឬមិនល្អក៏ដោយ គឺវាអាស្រ័យទៅលើ -- ហើយខ្ញុំក៏មិនគិតថា គាត់នឹងបង្គាប់ខ្ញុំមិនឲ្យចូលដែរ។ ប៉ុន្តែវាអាស្រ័យទៅលើគាត់ជាអ្នកសម្រេច។

**ប្រធានអង្គជំនុំ៖**

ចុះខាងលោកប្រធាន អង្គភាពគាំពារការពារក្តីវិញ តើលោកមាន ចង់មានមតិយោបល់អ្វីទេលើបញ្ហានៃការស្នើសុំតែងតាំងក្រុមប្រឹក្សា -- អ៎! ក្រុមមេធាវីការពារក្តីបម្រុង ហើយដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីនេះ?

[១២:០២:១៨]

**លោក អ៊ីសាក់ អ៊ីនដីលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការសង្កេតមួយចំនួន។ ទី១ ខ្ញុំគិតថា កញ្ញា អង់តា ហ្គីសសេ និង កូប៉េ បាននិយាយត្រឹមត្រូវអំពីគោលជំហររបស់មេធាវីការពារក្តី ហើយខាងអង្គភាពការពារក្តីគាំទ្រពួកគេ១០០ភាគរយ ចំពោះស្ថានភាពបច្ចុប្បន្ន គឺថាខាង ឌី.អេស.អេស គាំទ្រទាំងស្រុង។ ខ្ញុំនឹងនិយាយលម្អិតទៅលើអ្វីដែលគេបញ្ជាក់។

អ្វីដែលខ្ញុំចង់បញ្ជាក់ដំបូង គឺថាបន្ថែមពីលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការចូលរួមការពារក្ដី ពួកគេក៏មានសិទ្ធិផងដែរ ក្នុងការទទួលបានការតំណាងដោយមេធាវីដែលពួកគេបានជ្រើសរើស។ នេះគឺជាសិទ្ធិជាសារវន្តដែលបានអនុវត្តនៅទូទាំងប្រទេសក្នុងពិភពលោក។ ដូច្នេះ ការដែលយើងមានមេធាវីដែលជនជាប់ដែលមិនយល់ស្រប ឬក៏មិនអាចពិភាក្សាជាមួយជនជាប់ចោទ ឬក៏មិនមានការគាំទ្រពីការជនជាប់ចោទ គឺពួកគាត់មិនអាចការពារក្នុងផលប្រយោជន៍របស់ជនជាប់ចោទនោះឡើយ។

កាលពីម្សិលមិញ ដូចដែលលោក កូប៉េ បានបញ្ជាក់រួចទៅហើយ ខ្ញុំបានទទួល គឺនៅថ្ងៃទី២៧ តុលា គឺលិខិតមួយមកពីលោក នួន ជា ហើយខ្ញុំគិតថា នេះគឺជាលិខិតខ្លីទេ។ ហើយខ្ញុំសូមអាននូវផ្នែកសន្និដ្ឋាន ហើយខ្ញុំគិតថាវាជាការបកប្រែពីខ្មែរទៅអង់គ្លេសទេ។

[១២:០៣:៤៥]

“ថ្ងៃនេះ ខ្ញុំត្រូវបានគេជូនដំណឹងថា ខាងព្រះរាជអាជ្ញាចង់ឲ្យ អ.វ.ត.ក ជ្រើសរើសនូវមេធាវីមួយទៀត។ ហើយខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ចំពោះលោកថា គោលជំហរពិតប្រាកដរបស់ខ្ញុំ គឺខ្ញុំមិនទទួលយក ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយនូវមេធាវីថ្មី។ ខ្ញុំមានការជឿជាក់ពិតប្រាកដ១០០ភាគរយទៅលើលោក សុន អរុណ និងលោក កូប៉េ។ ប្រសិនបើតុលាការជ្រើសរើសសម្រេចជ្រើសតាំងមេធាវីថ្មី ខ្ញុំសម្រេចថាខ្ញុំមិនទទួលយក ហើយខ្ញុំនឹងបដិសេធមិនត្រឡប់មកតុលាការនេះទេ លុះត្រាតែមានការប្រើប្រាស់កម្លាំង។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ ឲ្យលោកបានដឹងអំពីគោលជំហររបស់ខ្ញុំ”។

លោក លោកស្រីចៅក្រម! កាតព្វកិច្ចរបស់ ឌី.អេស.អេស គឺការពារជនជាប់ចោទ។ ដូច្នេះ ប្រសិនបើ -- គឺយើងធានាថាជនជាប់ចោទទទួលបាននូវសម្ភារៈក៏ដូចជាមធ្យោបាយទាំងអស់ ដើម្បីការពារតាមច្បាប់។ ការដែលផ្ដល់នូវមេធាវីដែលជនជាប់ចោទមិនបានជ្រើសរើស គឺបានន័យថាមិនបានការពារសិទ្ធិរបស់ពួកគេឡើយ ហើយវាជាការរំលោភទៅលើសិទ្ធិរបស់ពួកគេ។ ដូច្នេះ ខាងអង្គភាពគាំពារការពារក្ដីមានការលំបាកយ៉ាងខ្លាំងក្នុងការគាំទ្រទៅដល់មេធាវីដែលមិនបានជ្រើសរើស និងមិនបានគាំទ្រដោយជនជាប់ចោទ គឺជាមេធាវីដែលដាក់ដោយតុលាការបែបនេះ។

ខ្ញុំគិតថា ខ្ញុំគួរតែផ្អាកនៅពេលនេះ ប៉ុន្តែបើសិនជាមានការចាំបាច់ ខ្ញុំនឹងបញ្ជាក់បន្ថែមទៀត។

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចចុងក្រោយ ខ្ញុំប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំមានសំណួរតែមួយទេ សួរទៅលោក អ៊ីនជីលី។ តើខ្ញុំអាចសួរបានដែរឬទេ? តើខ្ញុំអាចសួរទៅប្រធានអង្គភាពគាំពារការពារក្តីបានដែរឬទេ?

តាមការយល់ឃើញរបស់លោក តើមេធាវីការពារក្តីដែលលោកបានជ្រើសតាំងទៅតាមការជ្រើសរើសរបស់ជនជាប់ចោទ ដែលការិយាល័យរបស់លោកជាអ្នកផ្តល់ធនធាន តើពួកគេការពារសិទ្ធិជនជាប់ចោទដោយរបៀបណា ប្រសិនបើពួកគាត់មិនមកចូលរួមនៅក្នុងសាលសវនាការនេះ?

[១២:០៦:០៩]

**លោក អ៊ីសាក់ អ៊ីនជីលី៖**

ខ្ញុំអាចឆ្លើយបានទេលោកប្រធាន? សូមអរគុណលោកប្រធាន។

ខ្ញុំគិតថា មេធាវីការពារក្តីមួយរូបកន្លងមកទៀតដែលបានដកស្រង់កាលពីឆ្នាំទៅ ដែលលោកចៅក្រម ឡាវ៉ែន៍ គឺថាការងាររបស់មេធាវី និងការងារការពារ គឺមិនមែនត្រឹមតែមកចូលរួមសវនាការនោះទេ។ គឺថាខាង ឌី.អេស.អេស ទទួលបានរបាយការណ៍ការងារប្រចាំខែ ហើយយើងក៏មិនដឹងច្បាស់ថា តើពួកគេធ្វើការនៅទីណា ហើយនិងតុលាការដំណើរដល់ពេលណា។ ដូចដែលលោកបានដឹងរួចទៅហើយ ខ្ញុំបានឆ្លើយតបទៅនឹងសារណារបស់ភាគី ហើយពួកគេធ្វើសារណាដោយខ្លួនឯង ហើយគេធ្វើការពិភាក្សាដេញដោលទៅលើសារណារបស់សាក្សីជាដើម។ ដូច្នេះ ការតំណាងរបស់គាត់ ថាតើនេះគឺជាការតំណាងរបស់មេធាវី ទោះបីគាត់ចូលរួម ឬមិនចូលរួមក៏ដោយ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថាប្រហែលជាសំណួរខ្ញុំគាត់យល់ខុសហើយ ប៉ុន្តែខ្ញុំគិតថាប្រហែលជាខ្ញុំអាចនឹងនិយាយបន្ថែមម្តងទៀត។ ដូច្នេះ ខ្ញុំគិតថា វាគឺជាការយល់ខុសជាមូលដ្ឋានដោយមេធាវីការពារក្តីដែលយើងនិយាយជាមួយ ហើយជាពិសេសចំពោះខាង នួន ជា និង ខៀវ សំផន ចំពោះអ្វីដែលបានស្នើឡើងដោយព្រះរាជអាជ្ញានោះ។ យើងមិនមែនស្នើថា ក្នុងពេលនេះ គឺយើងចង់ឲ្យមានមេធាវីមកជំនួសនោះឡើយ គឺថាយើងគ្រាន់តែចង់បញ្ជាក់ថា ប្រសិនបើពួកគាត់អាចមានមេធាវីតាមការជ្រើសរើសរបស់គាត់។ គឺថានៅពេលដែលមានការរារាំងដល់តុលាការ គឺថាគាត់អាចជ្រើសរើសមេធាវីដោយខ្លួនរបស់គាត់ ព្រោះថាតុលាការបានចំណាយរាប់លានដុល្លា ហើយមេធាវីមកទីនេះគឺមិនអាចចូលរួម ហើយមិនចង់ចូលរួម ហើយវាជាការគោរពទៅតាមការបង្គាប់បញ្ជារបស់កូនក្តី។ ដូច្នេះ មានន័យថាគេមានមេធាវី

តុលាការបានផ្តល់មេធាវីដល់ពួកគេ ប៉ុន្តែពួកគេមិនប្រើប្រាស់មេធាវីទាំងអស់នោះ។

[១២:០៨:២០]

ដូច្នេះ អ្វីដែលយើងចង់ស្នើឡើង គឺថាមិនមែនជាការតែងតាំងមេធាវីនោះឡើយ។ ប៉ុន្តែគឺពួកគេមានមេធាវីរួចហើយ ប្រសិនបើពួកគេបង្គាប់ឲ្យលោក កូប៉េ មកចូលរួម នោះគឺជារឿងល្អ។ ប៉ុន្តែប្រសិនបើពួកគេអង្គុយនៅខាងក្រៅតុលាការ អង្គុយនៅខាងក្រៅសាលសវនាការ គេមិនអាចធ្វើការពិភាក្សាដេញដោល គេមិនអាចជំទាស់ទៅលើការលើកឡើងរបស់ព្រះរាជអាជ្ញានោះឡើយ។ ដូច្នេះហើយ ខ្ញុំគិតថា តុលាការអាច -- មិនអាចបន្តទៅមុខបានទេ បើសិនបើគ្មានមេធាវីការពារក្តីមកចូលរួម។ ដូច្នេះ ដើម្បីធានាដល់សុច្ចរិតភាពរបស់តុលាការ ដូច្នេះហើយយើងត្រូវជ្រើសតាំងមេធាវីបម្រុងមួយទៀត ដែលមេធាវីបម្រុងហ្នឹង គឺធានាថាសិទ្ធិរបស់ជនជាប់ចោទត្រូវបានការពារ។ គឺពួកគាត់អាចធ្វើការដាក់សារណាសួរដេញដោល និងលើកជាទឡ្ហីករណ៍ផ្សេងៗ។ ដូច្នេះ គឺខ្ញុំគិតថាមេធាវីបម្រុងនេះ គឺដើម្បីធានាអំពីសុច្ចរិតរបស់តុលាការ ដើម្បីការពារផលប្រយោជន៍របស់តុលាការ ហើយនិងដើម្បីការពារផងដែរ។ ពួកគេមិនមែនជាមេធាវីរបស់ជនជាប់ចោទទេ គឺមិនចាំបាច់មានការជ្រើសរើសពីជនជាប់ចោទទេ ហើយជនជាប់ចោទអាចគាំទ្រក៏បាន មិនគាំទ្រមិនបាន គឺថាជាមេធាវីដែលការពារ។ ដូច្នេះ ខ្ញុំចង់លើកឡើងផងដែរអំពីចំណុចរបស់ នួន ជា ក៏ដូចជាសំណួរ និងអ្វីដែលលោក កូប៉េ បានលើកឡើង។ ខ្ញុំចង់និយាយអំពីវិធាន៣៨ និងច្បាប់កម្ពុជា នៅពេលដែលមានបណ្តឹងជិតចិត្ត--

**ប្រធានអង្គជំនុំ៖**

ឈប់សិនអស់ៗឌីវីឌីហើយ។ សូមផ្លាស់ឲ្យលឿន រាយការណ៍ឲ្យខ្ញុំវិញណា!

*(សម្រាករយៈពេលខ្លី)*

[១២:១១:១៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ដូច្នេះ ចំណុចដែលមេធាវីការពារក្តីលើកឡើងថា វិធាន៣៨ មិនស៊ីសង្វាក់គ្នាជាមួយច្បាប់កម្ពុជា គឺថាបញ្ហានេះមិនបានលើកឡើងកន្លងមក ហើយយើងបានសម្រេចរួចទៅហើយ ព្រោះថាច្បាប់ ហើយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងរួចទៅហើយថា នៅពេលដែល

មានបញ្ហាក្នុងការអនុវត្តច្បាប់កម្ពុជានៅក្នុងបរិបទរបស់ អ.វ.ត.ក នោះ ពេលនោះតុលាការអាចពិនិត្យទៅលើបទដ្ឋានអន្តរជាតិបាន។ ការជំទាស់ទៅលើវិធានរបស់តុលាការគឺជាសិទ្ធិរបស់តុលាការ។ ប្រសិនបើសាលាដំបូងមិនសម្រេចត្រូវប្ដឹងទៅតុលាការកំពូល ចំពោះវិធី -- ប៉ុន្តែចំពោះបញ្ហានេះទៀតគឺថា គេមិនបានលើកឡើងជាការជំទាស់នៅក្នុងពេលកន្លងមកនោះឡើយ។ ទាក់ទងទៅនឹងបណ្ដឹងជិតជិតដែលកំពុងតែបន្ត ពួកគេមិនដែលធ្វើនោះទេ ហើយវិធានក៏អនុញ្ញាតឱ្យ ឌី.អេស.អេស ក៏ដូចជាមេធាវីការពារក្ដីផងដែរ ធ្វើការ -- ធ្វើសំណើទៅលើការកែវិសោធនកម្មវិធានផ្ទៃ។ ប៉ុន្តែខ្ញុំជឿជាក់ថា កន្លងមកមិនដែលមានការព្យាយាម ឬក៏មិនដែលមានការស្នើសុំឱ្យធ្វើការវិសោធនកម្មវិធាន៣៨ នោះឡើយ។

ដូច្នេះ ខ្ញុំគិតថាតាមការលើកឡើងរបស់ខ្ញុំ គឺថា អ្វីដែលយើងអាចគិតគឺថា ច្បាប់កម្ពុជាផ្ដល់ប្រយោជន៍ដល់ខាងជនជាប់ចោទ។ ហើយខ្ញុំគិតថា លោកប្រធានជាចៅក្រមជាតិ លោកប្រហែលជាដឹងច្បាស់ជាងខ្ញុំ។ គឺថាចៅក្រមដែលសម្រេចនៅពេលបន្តទៀតគួរតែចៅក្រមនៅក្នុងអង្គជំនុំជម្រះ បន្ទាប់គឺអង្គជំនុំជម្រះតុលាការកំពូល ហើយគួរជាអ្នកសម្រេចទៅលើបញ្ហានេះ ប៉ុន្តែមិនដែលមានការសម្រេចក្នុងពេលកន្លងមកនោះឡើយ។ ដូច្នេះ បញ្ហាគឺថា១តើមេធាវីការពារក្ដីយល់ស្រប ឬក៏មិនយល់ស្របជាមួយនឹងការសម្រេចនោះឡើយ។ មិនមែនជាបញ្ហានោះទេ។ គាត់មានសិទ្ធិមិនយល់ស្រប ប៉ុន្តែបញ្ហាគឺថាតើគាត់មានសិទ្ធិរារាំងតុលាការដែរឬទេ? តើគាត់មានសិទ្ធិក្នុងការនិយាយថា គាត់មិនពេញចិត្តជាមួយសេចក្ដីសម្រេច ហើយមិនឱ្យមេធាវីចូលរួមក្នុងសវនាការបានដែរឬទេ? ដូច្នេះ បញ្ហាខ្ញុំដែលត្រូវសួរទៅពួកគាត់គឺថា ហេតុអ្វីដែលបានជាលោកជឿថាលោកមានសិទ្ធិរារាំងដល់ការងារតុលាការ ប្រសិនបើលោកមិនពេញចិត្តជាមួយសេចក្ដីសម្រេចរបស់តុលាការដូច្នេះ។

[១២:១៤:០៤]

ប្រសិនបើយើងយល់ស្របដូច្នេះវិញ វាបង្កឱ្យមានភាពរញ៉េរញ៉ៃ ហើយពេលនោះ មេធាវីគាត់អាចនឹងដើរចេញពីតុលាការ។ ឧទាហរណ៍ ដូចជាទៅថ្ងៃអនាគត មេធាវីគាត់មិនពេញចិត្ត គាត់មានសិទ្ធិធ្វើដូច្នេះបាន គាត់មិនចូលរួម។ ដូច្នេះ ខ្ញុំគិតថាជាមូលដ្ឋានគឺថា មេធាវីការពារក្ដីមានសិទ្ធិមិនយល់ស្របជាមួយនឹងអង្គជំនុំជម្រះ ប៉ុន្តែពួកគាត់មិនមានសិទ្ធិក្នុងការរារាំងដល់ការងារតុលាការនោះឡើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញប្រធានអង្គភាពគាំពារការពារក្ដី។ សូមអញ្ជើញ!

**លោក អ៊ីសាក់ អ៊ីនដឺលី៖**

សូមអរគុណលោក លោកស្រីចៅក្រម ខ្ញុំចង់បន្ថែមបន្តិចទៅលើអ្វីដែលខ្ញុំលើកឡើង ប្រសិនបើយើងចាំមិនខុសទេនៅក្នុងកិច្ចប្រជុំរៀបចំសវនាការសប្តាហ៍មុន ខ្ញុំបានបញ្ជាក់ថា ខ្ញុំព្យាយាមដើម្បីស្វែងរកចៅក្រម -- ស្វែងរកមេធាវីដែលមានសមត្ថភាព។ ប៉ុន្តែអានេះគឺជាពេលវេលាផងដែរ ដែលខ្ញុំគិតថាដើម្បីឱ្យពួកគាត់ត្រូវការពេលវេលា គឺពួកគាត់ប្រហែលជាត្រូវការពេលវេលាច្រើនប្រហែលជា បួន ឬប្រាំខែ។ ដូច្នេះហើយខ្ញុំក៏ចង់បញ្ជាក់ផងដែរថា មុនពេលដែលមេធាវីបម្រុងមិនចូលដំណើរការសវនាការបាន គាត់ចាំបាច់ត្រូវដឹងព័ត៌មាន ត្រូវដឹងអំពីសំណុំរឿងជាមុន។ ដូច្នេះហើយទាល់តែពួកគាត់មានព័ត៌មានទើបអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី។ ដូច្នេះយើងត្រូវការបុគ្គលដែលដឹងអំពីរឿងក្តីដែលដឹងអំពីព័ត៌មាន ហើយមានការឯកភាពនឹងការយល់ស្របពីជនជាប់ចោទដើម្បីអាចតំណាងឱ្យជនជាប់ចោទបានដោយត្រឹមត្រូវ។ ដូច្នេះហើយខ្ញុំគិតថា គឺជាសិទ្ធិរបស់ជនជាប់ចោទដែលត្រូវបានគេដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត ដែលត្រូវធ្វើការសម្រេច។ ប្រសិនបើគាត់និយាយថា គាត់មិនយល់ព្រមសហការជាមួយមេធាវីក្រៅពីលោក សុន អរុណ និងលោក កូប៉េ នោះ។ ហើយប្រសិនបើលោក ខៀវ សំផន គឺគាត់បញ្ជាក់ច្បាស់រួចទៅហើយគឺគាត់នឹងមិនទទួលយកមេធាវីណាផ្សេងដែលក្រៅពីមេធាវីដែលគាត់បានជ្រើសរើសនោះឡើយ។ ដូច្នេះហើយ ក្រៅពីបញ្ហាពេលវេលាដែលមេធាវីបម្រុងត្រូវសិក្សាសំណុំរឿង ក៏នៅមានបញ្ហាផងទៀត ដែលត្រូវទៅនឹងការជ្រើសរើសរបស់ជនជាប់ចោទនៅពេលដែលយើងគិតទៅដល់បញ្ហាមេធាវីដែលជ្រើសតាំងដោយតុលាការ។

សូមអរគុណ លោកប្រធាន លោក លោកស្រីចៅក្រម។

[១២:១៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម ភាគី។ សូមគោរព ឯកឧត្តមប្រធានស្តីទី លោកអនុប្រធាន និងបុគ្គលិកនៃការិយាល័យរដ្ឋបាលទាំងអស់។ ខ្ញុំសូមលើកចំណុចបន្តិចបន្តួចពាក់ព័ន្ធទៅនឹងអ្វីដែលបានលើកពាក់ព័ន្ធទៅនឹងការចាត់តាំងមេធាវី ដែលជាមិត្តរបស់តុលាការនេះ ដែលជាមេធាវីជំនួយ។ ខ្ញុំមិននិយាយឡើងវិញ អំពីអ្វីដែលជាសញ្ញាណនៃកិច្ចការរបស់មេធាវីជាមិត្តរបស់

តុលាការនេះ ដោយសារការិយាល័យសហព្រះរាជអាជ្ញា គាត់បាននិយាយអំពីទំហំនៃការងារដែលផ្តោតទៅលើបញ្ហានីតិវិធី និងការការពារសិទ្ធិទៅលើសិទ្ធិរបស់ជនជាប់ចោទ ហើយមិនផ្តោតទៅលើបញ្ហាខ្លឹមសារនៃកិច្ចការភស្តុតាងទេ។ ដូច្នេះ នេះមិនមែនជាបញ្ហាដែលខ្ញុំចង់លើកទេ។ ប៉ុន្តែអ្វីដែលខ្ញុំចង់លើកគឺថា សហមេធាវីរបស់ជនជាប់ចោទបាននិយាយថា ការចាត់តាំងឲ្យមានមេធាវីមិត្តរបស់តុលាការនេះគឺវាផ្ទុយទៅនឹងវិធានរបស់ផ្ទៃក្នុង ហើយមិនមានការអនុញ្ញាតដោយវិធានផ្ទៃក្នុង ឬក៏ច្បាប់របស់តុលាការ -- អ៎! ច្បាប់របស់កម្ពុជានីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ។ កន្លែងនេះ ខ្ញុំគ្រាន់តែចង់ជម្រាបថា ជាការពិតមិនមានការនិយាយជាក់ច្បាស់អំពីវិធានផ្ទៃក្នុង ហើយនិងច្បាប់នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ តែទោះជាយ៉ាងណាក៏ដោយវិធានផ្ទៃក្នុងរបស់តុលាការ ក៏អនុញ្ញាតឲ្យមានវិធីដោះស្រាយនៅក្នុងករណីដែលមិនមានការចែងនៅក្នុងបញ្ហាណាមួយដែលបានលើកឡើងចំពោះមុខតុលាការនេះដែរ។ ជាក់ស្តែងនៅក្នុងវិធាន២ នៃវិធានផ្ទៃក្នុងបាននិយាយអំពីបញ្ហានេះ ហើយបាននិយាយថា -- ខ្ញុំសូមអាន៖ "នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះ ប្រសិនបើមានបញ្ហាណាមួយកើតមាន ដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្តដោយស្របទៅតាមវិធាន១២(១) នៃកិច្ចព្រមព្រៀង នៅមាត្រា ២០ថ្មី, មាត្រា២៣ថ្មី, មាត្រា៣៣ថ្មី ឬមាត្រា៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ និងដោយផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងនៅក្នុងវិធាន២១នៃវិធានផ្ទៃក្នុង និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។ កន្លែងនេះ ខ្ញុំយល់ថា វាជាផ្លូវមួយដែលបើកឲ្យអង្គជំនុំជម្រះមានលទ្ធភាពនៅក្នុងការចាត់តាំងឲ្យមានមេធាវីដែលជាមិត្តរបស់តុលាការ។ ទោះថាជនជាប់ចោទគាត់បដិសេធនៅក្នុងការទទួលមេធាវីនេះ ដើម្បីបំពេញភារកិច្ចការពារសិទ្ធិជូនគាត់ក៏ដោយ។ ទន្ទឹមនឹងនេះ ខ្ញុំចង់លើកសំណួរមួយជូនលោកប្រធានអង្គភាពគាំពារជនជាប់ចោទដើម្បីឆ្លើយ អម្បាញ់មិញហាក់ដូចជាបានឆ្លើយហើយ ប៉ុន្តែខ្ញុំហាក់ដូចជាមិនទាន់ច្បាស់លាស់អំពីបញ្ហានេះ។

[១២:១៩:៥៤]

ខ្ញុំចង់សួរទៅលោក អ៊ីនដីលី ថានៅក្នុងករណីដែលអង្គជំនុំជម្រះបញ្ជា ឬក៏ណែនាំទៅដល់អង្គភាពគាំពារជនជាប់ចោទឲ្យចាត់តាំងឲ្យមានមេធាវីមិត្តរបស់តុលាការសម្រាប់ជនជាប់ចោទទាំងពីររូបនេះ ថាតើអង្គភាពរបស់លោកនៅតែបដិសេធមិនព្រមធ្វើតាមការណែនាំ ឬក៏ចាត់ការចាត់តាំងរបស់តុលាការឬយ៉ាងណា? បាទសូមអរគុណលោកប្រធាន នេះសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

លោកប្រធានអង្គភាពគាំពារការពារក្ដី អាចឆ្លើយនឹងសំណួរនេះបាន។ សូមអញ្ជើញ!

**លោក អ៊ីសាក់ អ៊ីនដីលី៖**

សូមអរគុណលោកប្រធាន សូមអរគុណមេធាវី។ ទាក់ទងទៅនឹងសំណួរនេះ ខ្ញុំគិតថាមិន យើងមិនមែនជាមេធាវីការពារក្ដីនោះទេ ដូច្នេះយើងគោរពទៅតាមការបង្គាប់បញ្ជារបស់តុលាការ ដូចដែលខាងការិយាល័យរដ្ឋបាលបានជម្រាបរួចហើយកាលពីសប្ដាហ៍មុន គឺថាទោះបីថា យើងគឺជាផ្នែកមួយនៃតុលាការ យើងនឹងជួយទៅដល់តុលាការ។ ហើយខ្ញុំគិតថាវាជាលក្ខណៈទូទៅនៅពេលដែលមានការបង្គាប់តុលាការ យើងនឹងគោរពតាម។ ប្រសិនបើមានការបង្គាប់បញ្ជាពីតុលាការ ទោះបីជាការបង្គាប់បញ្ជាមានលក្ខណៈយ៉ាងណាក៏ដោយ ក៏យើងនឹងអនុវត្តទៅតាមការបញ្ជារបស់តុលាការនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មានបញ្ហាអីទៀតទៅ? សូមអញ្ជើញចុងក្រោយណ៎ះ! ខ្លីបានហើយ។

[១២:២១:៤៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមនិយាយដោយខ្លីទេ។ ពាក់ព័ន្ធនឹងប្រវេឡង់នៃប្រព័ន្ធ ស៊ីវិលឡនៅក្នុងសាលសវនាការយើងនេះ ហើយនិងចំណុចដែលថាប្រព័ន្ធ មិនមែនជាប្រព័ន្ធស៊ីវិលឡទាំងស្រុងទេ គឺជាប្រព័ន្ធយើងគឺជាប្រព័ន្ធចម្រុះ ជាពិសេសយោងតាមវិធាន២២(៤) នេះជាចំណុចដែលខ្ញុំចង់ឆ្លើយតបទៅនឹងប្រធានអង្គភាពគាំពារការពារក្ដី។ វិធាន២២(៤)បានបញ្ជាក់ថា "មេធាវីមានគោលដៅលើកស្ទួយយុត្តិធម៌និងនីតិវិធី"។ នេះជាបញ្ហាដូចជាឆោតល្ងង់ ដែលខ្ញុំសួរទៅលោក តើលោកមានយល់ថាវិធាននេះវាកែប្រែរឿងរ៉ាវទេ? ព្រោះថាយើងធ្វើទៅតាមការណែនាំរបស់កូនក្ដី ក៏ប៉ុន្តែមេធាវីនៅក្នុងសាលសវនាការនេះ គឺយើងមានកាតព្វកិច្ចហួសពីអាណត្តិដែលផ្ដល់ជូនដល់កូនក្ដីនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក អ៊ីសាក់ អ៊ីនដីលី៖**

សូមអរគុណលោកស្រីមេធាវី។ ខ្ញុំគិតថាលោកស្រីមេធាវី អង់តា ហ្គីសសេ បាឆ្លើយពាក់ព័ន្ធនឹង

កាតព្វកិច្ចវិជ្ជាជីវៈនេះហើយ លោក កូប៉េ ក៏បានបញ្ជាក់ហើយ។ ខ្ញុំផ្ទាល់ ខ្ញុំមិនឆ្លើយឲ្យលើសពីហ្នឹងទៀតទេ ពីព្រោះថាខាងមេធាវីការពារក្ដីទាំងពីរគាត់បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ជូនហើយពាក់ព័ន្ធទៅនឹងសីលធម៌ និងកាតព្វកិច្ចវិជ្ជាជីវៈមេធាវីនោះ។

[១២:២៣:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវកិច្ចពិភាក្សាលើលទ្ធភាពស្ដីពីការចាត់តាំងក្រុមមេធាវីការពារក្ដីបម្រុង និងពន្លឿនកិច្ចដំណើរការនីតិវិធីបានចប់ហើយ។ អង្គជំនុំជម្រះសូមថ្លែងអំណរគុណឯកឧត្ដមប្រធានការិយាល័យរដ្ឋបាល លោកអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងប្រធានគាំពារការពារក្ដី និងអង្គភាពបកប្រែភាសា និងសហការីដែលបានផ្ដល់មតិយោបល់ចូលរួមចំណែកលើបញ្ហានេះ។ ហើយនៅពេលនេះ ឯកឧត្ដមប្រធាន លោកអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងប្រធានគាំពារការពារក្ដី និងអង្គភាពបកប្រែភាសា និងសហការី អាចចាកចេញពីកិច្ចប្រជុំរៀបចំសវនាការនេះបានហើយ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគីពាក់ព័ន្ធរឿងក្ដីថា យើងនៅមួយប្រធានបទទៀត ដែលនៅពិភាក្សានៅរសៀលនេះ គឺលើសំណើរបស់សហព្រះរាជអាជ្ញាអន្ដរជាតិស្នើសុំនីតិវិធីសម្រាប់ប្រើប្រាស់សក្ខីកម្មរបស់សាក្សីពីក្នុងសំណុំរឿង០០៣ ហើយនិង០០៤។

បាទ ហេតុដូច្នេះ ដោយសារដល់ពេលវេលាលើសម៉ោងផង អ៊ីចឹងយើងសម្រេចផ្អាកកិច្ចប្រជុំពិភាក្សានៅព្រឹកនេះត្រឹមនេះ ហើយកិច្ចប្រជុំពិភាក្សាលើបញ្ហាប្រធានបទចុងក្រោយនេះនឹងលើកបន្ដនៅរសៀលចាប់ផ្ដើមពីម៉ោងមួយនិងសាមសិបនាទី ហើយសូមអញ្ជើញភាគីពាក់ព័ន្ធ ហើយនិងមន្ដ្រីពាក់ព័ន្ធសូមអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅបន្ទប់សម្រាកនៅខាងក្រោម ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមកិច្ចប្រជុំពិភាក្សានេះវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។

សម្រាកចុះ៕

*(សវនាការសម្រាកពីម៉ោង ១២:២៣ នាទី)*